សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តសិទ្ធិទទួលបានការអប់រំរបស់កុមារកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ពន សុវណ្ណារ័ត្ន**

ណែនាំដោយ
លោក **សៀង ចាន់ពិសិដ្ឋ**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំ **ពន សុវណ្ណារ័ត្ន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២២-២០២៣ សូមគោរពថ្វាយបង្គំ និងសម្ដែងនូវកតញ្ញូតាធម៌ចំពោះលោកឪពុកឈ្មោះ **ណុប ម៉ិន** និងអ្នកម្ដាយឈ្មោះ **គុំ សារ៉ាន់** ដែលលោកទាំងពីរជាអ្នកមានគុណរកអ្វីប្រៀបផ្ទឹមពុំបាន ដោយលោកទាំងពីបានខិតខំចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីក្នុងផ្ទៃរហូតពេលបច្ចុប្បន្ន និងបានប្រឹងប្រែងប្រៀនប្រដៅកូនដោយយកចិត្តទុកដាក់ ដើម្បីឱ្យកូនក្លាយទៅជាពលរដ្ឋល្អរស់នៅក្នុងសង្គម ព្រមទាំងខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការផ្គត់ផ្គង់ ដើម្បីផ្ដល់ការសិក្សាចាប់ពីថ្នាក់បឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សានេះ។ កូនសូមគោរពថ្លែងអំណរគុណ ចំពោះលោកទាំងពីរយ៉ាងជ្រាលជ្រៅនូវគុណបការៈដែលលោកអ្នកមានគុណទាំងពីរដែលមានមកលើរូបកូនគឺពិតជាមិនអាចកាត់ថ្លៃបាន។

សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ** គ្រប់រូបទាំងអស់នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ឱកាសឱ្យនាងខ្ញុំទទួលបានការសិក្សាបានយ៉ាងល្អ តាមរយៈការខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយ កម្លាំងចិត្ត។

នាងខ្ញុំសូមថ្លែងអំណរគុណជាពិសេសជូនលោកសាស្ត្រាចារ្យ **សៀង ចាន់ពិសិដ្ឋ** ដែលជាសាស្ត្រាចារ្យណែនាំសារណា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ពន្យល់ ត្រួតពិនិត្យ និងកែតម្រូវ ដើម្បីជួយបង្ហាត់បង្ហាញផ្លូវនៃការសរសេរអត្ថបទសារណាមួយនេះឡើងតាំងពីដើម រហូតដល់បានបញ្ចប់ជាស្ថាពរ។

ជាទីបញ្ចប់ នាងខ្ញុំសូមថ្លែងអំណរគុណសារជាថ្មីម្ដងទៀត និងសូមជូនពរសាធុការជូនចំពោះ **លោកឪពុក អ្នកម្ដាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ** ព្រមទាំងក្រុមគ្រួសារឱ្យទទួលបានសុខភាពល្អ សុខសុវត្ថិភាព និងទទួលបានជោគជ័យលើគ្រប់ភារកិច្ចទាំងពួង និងសូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀតឃ្លាតឡើយ។ នាងខ្ញុំក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលបានកើតមាននូវប្រការណាមួយ ដោយអចេតនាក្នុងសារណារបស់នាងខ្ញុំផងដែរ។

## **អារម្ភកថា**

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រអស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៣ ក្រុម L4A3 នាងខ្ញុំបានទទួលនូវចំណេះដឹងទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្ត រួមទាំងបទពិសោធន៍ជាច្រើនដែលទាក់ទងនឹងការរស់នៅក្នុងសង្គមពីសំណាក់លោក/លោកស្រីសាស្ត្រចារ្យទាំងអស់ដែលបានធ្វើការបង្ហាត់បង្ហាញនាងខ្ញុំអស់ពីកម្លាំងកាយកម្លាំងចិត្តហូតមកដល់សព្វថ្ងៃនេះ។ ដូច្នេះដើម្បីទទួលបានចំណេះដឹង ក៏ដូចជាការចែករំលែកចំណេះពាក់ព័ន្ធនឹងការទទួលបានការអប់រំ នាងខ្ញុំសូមជ្រើសរើសយកនូវប្រធានបទមួយស្តីពី "**ការអនុវត្តសិទ្ធិទទួលបានការអប់រំរបស់កុមារកម្ពុជាក្នុងបរិបទជម្ងឺកូវីដ-១៩**" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់នាងខ្ញុំ។

មូលហេតុដែលដែលនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រដោយសារតែនាងខ្ញុំមើលឃើញពីកត្តាបញ្ហានៃជំងឺរាតត្បាតកូវីដ-១៩ បានជះផលប៉ះពាល់ទៅលើការសិក្សា ដូចជាការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដែលជាផលរំខានដល់ការសិក្សានៅគ្រប់សាលាទូទាំងប្រទេសកម្ពុជា ព្រមទាំងមានការផ្លាស់ប្តូរយ៉ាងគួរឱ្យកក់សម្គាល់ជាពិសេសសម្រាប់កុមារដែលកំពុងបន្តការសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា។

តាមរយៈការសិក្សាស្រាវជ្រាវនេះ នាងខ្ញុំសង្ឃឹមថាអត្ថបទសារណាមួយនេះនឹងផ្តល់អត្ថប្រយោជន៍ ជាឯកសារដើម្បីពង្រីកនូវចំណេះដឹង ចំពោះមិត្តអ្នកអាន ក៏ដូចជាសិស្សនិស្សិតដែលត្រូវការឯកសារជំនួយស្មារតី ព្រមទាំងស្វែងយល់បន្ថែមទៅលើការឆ្លើយតបរបស់ក្រសួង អប់រំ យុវជន និងកីឡា ក្រុមការងារវិស័យអប់រំ អង្គការក្រៅរដ្ឋាភិបាល និងជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការអនុវត្តសិទ្ធិទទួលបានការអប់រំរបស់កុមារកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩។

ជាចុងក្រោយនាងខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំង ប្រសិនបើឯកសារនេះអាចជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់មិត្តអ្នកអាន និងនិស្សិតបាន។ ទន្ទឹមនឹងនេះដែរ រាល់ការលើកយកមកបង្ហាញ ការបញ្ចេញជាទស្សនៈ ក៏ដូចជាទិន្នន័យនៃលទ្ធផលស្រាវជ្រាវរបស់ស្ថាប័នណាមួយនៅក្នុងឯកសារនេះ ប្រសិនបើមានការខ្វះចន្លោះនៅត្រង់ចំណុចណាមួយ នាងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុន និងស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រី បណ្ឌិត សាស្ត្រាចារ្យបញ្ញវន្ត និងមិត្តអ្នកអាន ដើម្បីទុកជាបទពិសោធន៍ព្រមទាំងព្យាយាមកែប្រែនូវចំណុចខ្វះខាតទាំងប៉ុន្មានឱ្យបានល្អប្រសើរឡើងវិញ។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅអំពីសិទ្ធិកុមារ**

**អំពីកុមារ** ........ ៥

១.១.១. សិទ្ធិ និងកុមារ ........ ៥

១.១.១.១. សិទ្ធិជាមូលដ្ឋានរបស់កុមារ ........ ៦

១.១.១.២. សិទ្ធិរស់រានមានជីវិត ........ ៦

១.១.១.៣.សិទ្ធិទទួលបានការការពារ ........ ៨

១.១.១.៤. សិទ្ធិក្នុងការចូលរួម ........ ៩

១.១.១.៥. ការទទួលបានការអប់រំ ........ ១១

១.១.២. អនុសញ្ញាស្ដីពីសិទ្ធិកុមារ ........ ១២

១.១.២.១. ប្រវត្តិនៃការបង្កើត ........ ១២

១.១.២.២. សិទ្ធិពិសេស ........ ១៤

**ជំពូកទី២**

**វិស័យអប់រំក្នុងប្រទេសកម្ពុជា**

**២.១. សិទ្ធិទទួលបានការអប់រំនៅកម្ពុជា** ........ ១៧

២.១.១. ការអប់រំទូទៅនៅប្រទេសកម្ពុជា ........ ១៧

២.១.១.១. ប្រវត្តិនៃការអប់រំ ........ ១៧

២.១.១.២. អំពីក្រសួងអប់រំ យុវជន និងកីឡា ........ ២០

២.១.១.៣. ការអប់រំសាធារណៈ (ការអប់រំតាមបែបប្រពៃណី) ........ ២១

២.១.១.៤. ការអប់រំឯកជន (ការអប់រំតាមបែបប្រពៃណី) ........ ២៣

២.១.២. ការអប់រំក្នុងបរិបទជំងឺកូវីដ-១៩ ........ ២៥

២.១.២.១. ជំងឺកូវីដ ១៩ និងប្រព័ន្ធអប់រំកម្ពុជា ........ ២៥
២.១.២.២. ផលប៉ះពាល់ចម្រុះនៃជំងឺកូវីដ-១៩ មកលើប្រព័ន្ធអប់រំ ........ ២៧
២.១.២.៣. បញ្ហាដែលកុមារជួបប្រទះក្នុងការសិក្សាពីចម្ងាយ ........ ៣០
២.១.២.៤. ការឆ្លើយតបចំពោះជំងឺកូវីដ-១៩ នៅក្នុងវិស័យអប់រំ ........ ៣២
២.១.២.៥. បរិវត្តកម្មឌីជីថលនៃការអប់រំ ........ ៣៥
២.២.កត្តាដែលជំរុញនិងផលវិបាកនៃការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ(អនឡាញ) ........ ៣៨
២.២.១. លទ្ធភាពរកឃើញ និងការវាយតម្លៃ ........ ៣៨
២.២.១.១. លទ្ធភាពចូលរួមនិងការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ ៣៨
២.២.១.២. ការគាំទ្រដល់ការសិក្សាពីចម្ងាយ ........ ៣៩
២.២.១.៣. ការចូលរួមរបស់ឪពុកម្តាយក្នុងការជួយឱ្យកូនបានបន្តការសិក្សា ........ ៤០
២.២.២. ផលវិបាកនៃការចូលរួមក្នុងវិធីសិក្សាពីចម្ងាយ (អនឡាញ) ........ ៤១
២.២.២.១. ផលវិបាកដល់ការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ ៤១
២.២.២.២. ផលវិបាកដល់ការចូលរួមរបស់អាណាព្យាបាលក្នុងកម្មវិធីសិក្សាពីចម្ងាយ ........ ៤២
**២.៣. គោលនយោបាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ** ........ ៤៣
២.៣.១. ការអភិវឌ្ឍដើម្បីការអប់រំប្រកបដោយនិរន្តភាព ........ ៤៣
២.៣.២. ទស្សនវិស័យនៃការអភិវឌ្ឍធនធានមនុស្ស និងគោលនយោបាយអប់រំ ........ ៤៤
**សេចក្តីសន្និដ្ឋាន** ........ ៤៨
**អនុសាសន៍** ........ ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាគឺជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ស្របពេលដែលកំពុងទទួលការលូតលាស់ស្មើរលើគ្រប់វិស័យទាំងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចជាតិ ហើយការរីកចម្រើននៃប្រទេសជាតិមួយទៅបាន គឺត្រូវមានកត្តាសំខាន់មិនអាចខ្វះបាននៅក្នុងការចូលរួមជាកម្លាំងចលករនៃភាពរីកចម្រើននោះគឺធនធានមនុស្ស។ ការអប់រំ គឺជាធាតុចាំបាច់នៅក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ពោរពេញដោយចំណេះដឹង ជំនាញច្បាស់លាស់ព្រមទាំងមាន សេចក្តីថ្លៃថ្នូរ ចរិតលក្ខណៈល្អចេះចែករំលែក និងមានស្មារតីចូលរួមអភិវឌ្ឍន៍ជាតិ។ ការអប់រំនេះត្រូវបានអនុណោមទៅតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា រដ្ឋត្រូវយកចិត្តទុកដាក់ដល់វិស័យអប់រំ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ នៅក្នុងការរីកចម្រើនឥតឈប់ឈររបស់សង្គមជាតិ គឺយើងមិនអាចមើលរំលងបានទេអំពីការអភិវឌ្ឍរបស់កុមារ ព្រោះកុមារគឺជាធនធានមនុស្សដ៏សំខាន់ ក៏ដូចជាសសរទ្រូងនៃប្រទេសជាតិនាពេលខាងមុខផងដែរ។ កុមារ គឺសំដៅទៅលើមនុស្សគ្រប់រូបដែលស្ថិតក្រោមអាយុ ១៨ឆ្នាំ លើកលែងតែអាយុពេលវ័យត្រូវបានកំណត់ហ័សជាងនេះនៅក្នុងច្បាប់នៃប្រទេសនីមួយៗ។

ទន្ទឹមនឹងនេះការអភិវឌ្ឍប្រទេសទៅលើគ្រប់វិស័យ ជាពិសេសលើវិស័យអប់រំនេះផងដែរ ប្រទេសកម្ពុជាព្រមទាំងពិភពលោកទាំងមូល បានទទួលនៅការគំរាមកំហែងពីរោគរាតត្បាតនៃជំងឺកូវីដ-១៩។ ការរាតត្បាតនៃជំងឺកូវីដ-១៩ បានបង្កការប៉ះទង្គិចយ៉ាងដំណាំទៅលើខឿនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដោយក្នុងរួមមានវិស័យទេសចរណ៍ វិស័យឧស្សាហកម្មនាំចេញ និងប្រព័ន្ធអប់រំផងដែរ។ ដើម្បីបង្ការការឆ្លងរីករាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តបិទគ្រឹះស្ថានសិក្សា សាលារៀនគ្រប់ប្រភេទ និងគ្រប់កម្រិតសិក្សាទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ស្ថានភាពនេះបានជះផលពិបាកយ៉ាងខ្លាំងទៅដល់សុខុមាលភាពរបស់កុមារ និងការសម្រេចបាននូវសិទ្ធិរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។

ដើម្បីឆ្លើយតបនឹងស្ថានភាពដ៏លំបាកលំបិននេះ រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំយុវជន និងកីឡា ជាមួយនឹងដៃគូអភិវឌ្ឍន៍ បានធ្វើការតាមដាន ស្រាវជ្រាវ ស្វែងរកដំណោះស្រាយ និងការអនុវត្តយុទ្ធការបង្ការនានាទូទាំងប្រទេស ដែលធ្វើឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ ដោយកុមារទូទាំងប្រទេសតម្រូវឱ្យធ្វើការសិក្សាពីចម្ងាយ (អនឡាញ) ពោលគឺការអប់រំឌីជីថលក្នុងបរិបទឧស្សាហកម្ម៤.0 ដើម្បីជៀសវាងការរីកត្បាតនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ហើយនៅក្នុងនោះយើងសង្កេតឃើញមានផលវិបាកមួយចំនួនដែលអាចប៉ះពាល់ទៅលើការអភិវឌ្ឍរបស់កុមារក្នុងការទទួលបានការអប់រំ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសង្កេតឃើញថារាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការប្រើប្រាស់វិធីបង្រៀននៃការសិក្សាពីចម្ងាយ (អនឡាញ) ដើម្បីជួយសម្រួលការសិក្សារបស់កុមារក្នុងបរិបទនៃជំងឺកូវីដ-១៩ ព្រមទាំងសម្រេចឱ្យបានតាមស្តង់ដារកម្មវិធីសិក្សារបស់ក្រសួង ហើយការអប់រំឌីជីថលនេះ ត្រូវបានឆ្លើយតបទៅនឹងយុគសម័យបច្ចេកវិទ្យា ដោយការធ្វើកំណែទម្រង់សាលារៀន កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្កើតបរិស្ថានឌីជីថល។ ដូចនេះការស្រាវជ្រាវលើប្រធានបទ៖ **ការអនុវត្តសិទ្ធិទទួលបានការអប់រំរបស់កុមារកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩** នេះមកសិក្សាគឺដើម្បីធ្វើការស្វែងយល់ និងឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

- តើកុមារកម្ពុជាមានសិទ្ធិទទួលបានការអប់រំយ៉ាងដូចម្តេចខ្លះ?
- តើមានបញ្ហាអ្វីខ្លះដែលកុមារកម្ពុជាបានជួបប្រទះក្នុងការសិក្សាពីចម្ងាយ (អនឡាញ)?
- តើមានកត្តាអ្វីខ្លះដែលជំរុញ និងផលវិបាកនៃកម្មវិធីសិក្សាពីចម្ងាយ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវខាងលើនេះ គឺមានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងសម្រាប់សិស្ស និស្សិតជំនាន់ក្រោយ ក៏ដូចជាធ្វើការស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីការអនុវត្តសិទ្ធិទទួលបានការអប់រំរបស់កុមារកម្ពុជានៃបរិបទជំងឺកូវីដ-១៩ ដែលស្ថានភាពក្នុងការកំណត់នៃកំណែទម្រង់នៃការសិក្សាដែលជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ដោយស្វែងយល់ពីផលវិបាក កម្រិតនៃការទទួលបានការអប់រំ ផលរំខាននានាដែលគួរឱ្យព្រួយបារម្ភនាពេលអនាគត ក៏ដូចជាការរីកចម្រើននៃការអប់រំបែបឌីជីថលក្នុងប្រទេសកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវសារណានៃប្រធានបទខាងលើ គឺពិតជាមានសារៈប្រយោជន៍ចំពោះសិស្សានុសិស្ស និស្សិតក្នុងការស្វែងយល់បន្ថែមពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើវិស័យអប់រំ និងការអនុវត្តសិទ្ធិកុមារ រួមជាមួយនឹងដំណោះស្រាយដែលឆ្លើយតបទៅនឹងសម័យកាលឌីជីថល។ ទំហំនៃការស្រាវជ្រាវនេះគឺបានផ្តោតសំខាន់ទៅលើកំណែរទម្រង់ក្នុងវិស័យអប់រំក្នុងឆ្នាំ២០២០ រហូតដល់ឆ្នាំ២០២១ ព្រមទាំងលម្អិតទៅលើកុមារដែលមានអាយុចាប់ពី ៥ឆ្នាំ រហូតដល់ ១៧ឆ្នាំ តែប៉ុណ្ណោះ ពុំមានវិសាលភាពធំធេងទៅលើសិស្សានុសិស្ស និងនិស្សិតទូទាំងប្រទេសកម្ពុជានោះទេ។ ចំពោះការស្រាវជ្រាវនៃសារណានេះ គឺបានសិក្សាប្រមូលឯកសារ លិខិតបទដ្ឋានគតិយុត្ត ទិន្នន័យនៃការស្រាវជ្រាវរបស់ក្រសួងអប់រំ យុវជន និងកីឡា និងប្រព័ន្ធផ្សព្វផ្សាយដែលមានប្រភពច្បាស់លាស់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះដោយយកចិត្តទុកដាក់ រួមមានសារៈសំខាន់ណាស់សម្រាប់សិស្ស និស្សិត បានធ្វើការស្វែងយល់អំពីការទទួលបានការអប់រំរបស់កុមារដែលប្រទេសកំពុងស្ថិតក្នុងគ្រាលំបាក ព្រមទាំងផលលំបាកដែលកុមារបានជួបប្រទះ និងបញ្ហាប្រឈមនាពេលខាងមុខដែលបានពីផលរំខានពីជំងឺកូវីដ-១៩។ លើសពីនេះ មានការសិក្សាពីដំណោះស្រាយរបស់រដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ទៅលើបញ្ហានេះក៏ដូចជាបញ្ហាប្រឈមនានា ដែលជាទុននិងបទពិសោធន៍ដ៏ល្អមួយសម្រាប់ប្រទេសកម្ពុជាធ្វើការដោះស្រាយ និងវិវឌ្ឍន៍ខ្លួនក្នុងវិស័យអប់រំ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺបានស្រង់យកទិន្នន័យដែលពាក់ព័ន្ធពីការស្រាវជ្រាវរបស់អង្គការក្រៅរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងទទួលបានការចង្អុលបង្ហាញពីសំណាក់ **លោកសាស្ត្រចារ្យសៀង ចាន់ពិសិដ្ឋ** ហើយរួមទាំងឯកសារពាក់ព័ន្ធនានាក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះបានបែងចែកចេញជា ២ ជំពូក គឺ៖

- **ជំពូកទី១ "សញ្ញាណទូទៅអំពីសិទ្ធិកុមារ"** ៖ ដែលនៅក្នុងជំពូកនេះ ផ្តោតសំខាន់ទៅសិទ្ធិទូទៅដែលជាសិទ្ធិមូលដ្ឋានកុមារទទួលបាន សិទ្ធិពិសេស និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- **ជំពូកទី២ "វិស័យអប់រំក្នុងប្រទេសកម្ពុជា"** ៖ ដែលនៅក្នុងជំពូកនេះ ផ្តោតសំខាន់ទៅការទទួលបានសិទ្ធិទទួលបានការអប់រំរបស់កុមារក្នុងប្រទេសកម្ពុជាការអប់រំក្នុងបរិបទជំងឺកូវីដ-១៩ ក៏ដូចជាផលវិបាកដែលមានក្នុងការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ ព្រមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាលទៅលើវិស័យអប់រំ។

# ជំពូកទី១

# សញ្ញាណទូទៅអំពីសិទ្ធិកុមារ

# ជំពូកទី១

# សញ្ញាណទូទៅអំពីសិទ្ធិកុមារ

## អំពីកុមារ

### ១.១.១. សិទ្ធិ និងកុមារ

**ក. សិទ្ធិ**

**សិទ្ធិ** គឺសេចក្តីសម្រេចផល ការសម្រេចប្រយោជន៍ សេចក្តីសម្រេចតាមអំណាចច្បាប់ អំណាច មុខការដែលត្រូវសម្រេចលើខ្លួន។[1]

**សិទ្ធិ** គឺជាការទាមទារ ឬជាការប្រគល់ឱ្យនូវអំណាចដែលបុគ្គលឬក៏មនុស្សម្នាក់ៗជឿថាត្រូវតែមាន។

**សិទ្ធិ** គឺបុព្វសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គលគ្រប់រូបដោយមានការការពារពីអំណាចសាធារណៈ។[2]

**សិទ្ធិ** គឺជាអំណាចដែលប្រគល់ឱ្យបុគ្គលអាចធ្វើអ្វីៗបាន តែស្ថិតក្រោមព្រំដែននៃច្បាប់។

**សិទ្ធិ** គឺអាវុធនិងខែលសម្រាប់ការពារមនុស្សនៅពេលមានការបំពានណាមួយកើតឡើង។

**សិទ្ធិ** គឺអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាចដើម្បីរស់ឱ្យបានសមរម្យជាមនុស្ស។

**សិទ្ធិ** គឺអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាចដើម្បីរស់ឱ្យបានសមរម្យជាមនុស្ស។ សិទ្ធិគឺជាអំណាចដែលត្រូវបានទទួលស្គាល់ត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចទទួលនូវការការពារ ឬ ទាមទារនូវផលប្រយោជន៍ ដែលបានកំណត់ណាមួយ។[3]

**ខ. កុមារ**

នៅក្នុងសម័យកាលប្រទេសកំពុងអភិវឌ្ឍន៍ គឺមានមតិជាច្រើនជុំវិញការយល់ឃើញទៅលើពាក្យថាកុមារ។ ជាក់ស្តែងគេបានលើកឡើងថា មនុស្សដែលមានអាយុក្រោម ១ ឆ្នាំ គិតចាប់ពីថ្ងៃកំណើត ត្រូវបានគេហៅថាជា ទារក ឬ ទារិកា។ ឯមនុស្សដែលមានអាយុច្រើនជាង១ឆ្នាំ រហូតដល់អាយុក្រោម ៦ឆ្នាំ ត្រូវបានគេហៅថាជា កូនក្មេង។ រីឯមនុស្សដែលមានអាយុចាប់ពី៦ឆ្នាំរហូតដល់១៤ឆ្នាំ ត្រូវបានគេហៅថាជា កុមារ។

បើទោះជាយ៉ាងនេះក្តី ក៏មាននិយមន័យផ្លូវការមួយចំនួនបានលើកឡើងថា កុមារ ត្រូវបានទទួលស្គាល់ថាជាមនុស្សមានអាយុក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ លើកលែងតែច្បាប់របស់ប្រទេស ចែងពីអាយុពេញវ័យដែលគេសន្មតរហ័សជាង។[4] ការកំណត់និយមន័យបែបនេះ មានគោលបំណងសម្រាប់កំណត់អំពីអាយុរបស់កុមារ

[1] វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត

[2] ប្រវត្តិ ទសន្ទរៈ ទ្រឹស្តី នៃនីតិសិទ្ធិមនុស្ស ដោយសាស្ត្រាចារ្យ ម៉ឹង វ៉ាន់ឌី

[3] សន្ទានុក្រមនៃក្រមនីតិរដ្ឋប្បវេណី

[4] មាត្រា១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

ទៅតាមប្រទេសនីមួយៗលើពិភពលោក ដោយផ្អែកលើមូលដ្ឋាននៃការរីកលូតលាស់ទាំងផ្នែករូបរាងកាយ ចំណេះដឹង និងផ្អែកលើបរិបទសង្គមរបស់ប្រទេសទាំងនោះ។ ជាការពិតណាស់ កុមារនៅក្នុងតំបន់អាស៊ីភាគច្រើនកំណត់យកអាយុ១៨ឆ្នាំ ទើបក្លាយអាយុពេញវ័យឬអាចនិយាយម្យ៉ាងទៀតថា មាននីតិភាពដែលទទួលស្គាល់ដោយច្បាប់ដែលខុសពីកុមារដែលនៅតំបន់អឺរ៉ុប។

**គ. អត្ថន័យរួម**

សិទ្ធិកុមារ គឺជាសិទ្ធិមនុស្សដែលកុមារមានអាយុក្រោម ១៨ឆ្នាំ មានលទ្ធភាពទទួលបានការទាមទារនូវផលប្រយោជន៍ ទទួលនូវការការពារ និងអំណាចដែលមានច្បាប់ទទួលស្គាល់។ កុមារទាំងអស់មានសិទ្ធិដូចៗគ្នា ហើយសិទ្ធិគ្រប់យ៉ាងរបស់កុមារ គឺត្រូវបានចុះក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលគ្រប់ប្រទេសទាំងអស់បានយល់ស្របទៅនឹងសិទ្ធិទាំងនោះ។ សិទ្ធិកុមារ ត្រូវបានកំណត់យ៉ាងច្រើនប្រភេទ រួមបញ្ចូលទាំងភាពធំទូលាយនៃសង្គម វប្បធម៌ សេដ្ឋកិច្ច។

**១.១.១.១. សិទ្ធិជាមូលដ្ឋានរបស់កុមារ**

អនុសញ្ញារបស់អង្គការសហប្រជាជាតិដែលស្តីពីសិទ្ធិកុមារ គឺបានចែងសិទ្ធិជាក់លាក់ ៤ ប្រភេទធំៗនៃសិទ្ធិកុមារមាន៖

- សិទ្ធិរស់រានមានជីវិត
- សិទ្ធិក្នុងការចូលរួម
- សិទ្ធិទទួលបានការការពារ
- សិទ្ធិទទួលបានការអភិវឌ្ឍន៍។[5]

**១.១.១.២. សិទ្ធិរស់រានមានជីវិត**

កុមារគ្រប់រូបមានសិទ្ធិមានជីវិតតាំងពីកំណើត ហើយរដ្ឋមានកាតព្វកិច្ចក្នុងការធានាការរស់រាន និងការអភិវឌ្ឍរបស់កុមារ។ រដ្ឋភាគីទទួលស្គាល់ថា កុមារគ្រប់រូបមានសិទ្ធិរស់រានមានជីវិតជាប់ពីកំណើត។ រដ្ឋភាគី ត្រូវធានាក្នុងកម្រិតអតិបរមា តាមដែលអាចធ្វើទៅបានចំពោះការរស់រាន និងការលូតលាស់របស់កុមារ។[6]

សិទ្ធិរស់រានមានជីវិត គឺជាសិទ្ធិមួយដែលសំខាន់បំផុតដែលស្តែងចេញនូវសិទ្ធិ និងសេរីភាពផ្សេងៗទៀត។ សិទ្ធិរស់រានមានជីវិតរាប់បញ្ចូលផងដែរនូវសិទ្ធិសំរាប់អវៈយវៈនីមួយៗ ឬសតិអារម្មណ៍ ដែលជីវិតមនុស្សត្រូវការផងដែរ គឺមានន័យថាសិទ្ធិក្នុងការរស់នៅដោយមានអធិបតេយ្យជាមូលដ្ឋានមនុស្សដូចជា សិទ្ធិក្នុងការថែទាំសុខភាព វេជ្ជសាស្ត្រក្នុងកម្រិតខ្ពស់បំផុត សិទ្ធិក្នុងការបំប៉នចំណីអាហារគ្រប់គ្រាន់ សិទ្ធិមានជំរក ឬ លំនៅដ្ឋាន

[5] បោះផ្សាយដោយ យូនីសេហ្វ ឆ្នាំ២០០៩ - អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម, ទំព័រ ១០-១១

[6] មាត្រា ៦ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

សមរម្យ សិទ្ធិទទួលបានសន្តិសុខសង្គម និងសិទ្ធិមានឈ្មោះ សញ្ជាតិសមស្រប។ កាលបើមិនមានសិទ្ធិទាំងនេះទេ នោះមិនអាចចាត់ទុកថាមានការគោរពដល់សិទ្ធិរស់រានមានជីវិតឡើយ ដែលវាអាចធ្វើឱ្យកុមារទទួលរងគ្រោះថ្នាក់ផ្សេងៗ។ កុមារគ្រប់រូប ត្រូវមានសិទ្ធិរស់រានមានជីវិត មិនអាចមានជនណាម្នាក់រំលោភបំពានបានឡើយ។

**ក. ការថែទាំសុខភាព**

កុមាររីកលូតលាស់ល្អទាំងរាងកាយ និងបញ្ញាស្មារតី ដោយសារមានការថែទាំសុខភាពជាប្រចាំការថែទាំសុខភាពចាំបាច់ត្រូវធ្វើទាំងមុន និងក្រោយពេលទារកកើត។ ស្ត្រីដែលមានផ្ទៃពោះមិនត្រូវប្រើថ្នាំផ្តេសផ្តាស់ ផឹកស្រវឹង ឬ ជក់បារីទេ ព្រោះនាំឱ្យប៉ះពាលទារកក្នុងផ្ទៃ។ ក្រោយពេលកុមារកើត មាតាបិតា ទាំងអស់ចាំបាច់ត្រូវយកកូនទៅចាក់ថ្នាំការពារជម្ងឺ៦មុខ គឺជម្ងឺស្វិតដៃជើង កញ្ជ្រិល របេង ក្អកមាន់ តេតានុសនិងខាន់ស្លាក់។ កុមារកាន់តែធំ ការញ៉ាំចំណីផ្តេសផ្តាស បញ្ហាការរស់នៅ អាកាសធាតុ សុទ្ធតែជាអ្វីដែលកុមារៗប្រឈម។ ការផ្តល់ថ្នាំបង្ការគឺជាមធ្យោបាយដ៏ងាយស្រួល មានតម្លៃថោក និងមានប្រសិទ្ធភាព ជាងការព្យាយាមជួយកុមារដែលឈឺ ឬជិតស្លាប់នោះ។ ការនាំកុមារទៅទទួលថ្នាំបង្ការ គឺជាមធ្យោបាយដ៏សំខាន់បំផុតមួយក្នុងការថែរក្សាសុខភាពដល់ពួកគេ។ [7] ដូច្នេះអាណាព្យាបាលគួរស្វែងយល់ឱ្យកាន់តែច្រើនពីថ្នាំបង្ការរោគសញ្ញាទូទៅ បញ្ហាជំងឺឆ្លងលក្ខខណ្ឌកង្វះអាហារូបត្ថម្ភ បញ្ហាការលូតលាស់របស់កូន ជំងឺប្រព័ន្ធប្រសាទ បញ្ហាប្រព័ន្ធរំលាយអាហារ ជំងឺស្បែក ជំងឺផ្លូវដង្ហើម បូករួមទាំងបញ្ហាសុខភាពផ្សេងទៀត ឱ្យបានច្រើន និងប្រុងប្រយ័ត្នខ្ពស់។

**ខ. ការបំប៉នចំណីអាហារ**

កុមារត្រូវការជាចាំបាច់នូវចំណីអាហារសំរាប់ចិញ្ចឹមរាងកាយដើម្បីលូតលាស់។ កង្វះចំណីអាហារ អាចធ្វើឱ្យកុមារខ្វះជីវជាតិ ដែលជាហេតុបណ្តាលឱ្យកុមារឆាប់កើតជម្ងឺផ្សេងៗ ហើយអាចប៉ះពាល់ដល់ការរីកលូតលាស់របស់កុមារផងដែរ។ ដែលនេះជាការធ្វេសប្រហែសរបស់មាតាបិតា ក្នុងការថែទាំកុមារឱ្យបានល្អ។ តាមរយៈការសហការជាមួយក្រសួងសុខាភិបាល ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងដៃគូដទៃទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សេវា និងគុណភាពនៃការផ្តល់ការថែទាំដល់កុមារ និងឱ្យកាន់តែល្អប្រសើរជាងមុន។ យើងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់លទ្ធភាពទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ ក្នុងតម្លៃសមរម្យ ប្រកបដោយបរិយាប័ន្នមាននិរន្តរភាព និងសមធម៌ ចាប់ពីពេលទើបសម្រាល រហូតដល់វ័យជំទង់។ សេវាទាំងនេះ មានឥទ្ធិពលយ៉ាងធំធេងលើលទ្ធភាពរបស់កុមារក្នុងការរស់រានលូតលាស់ រៀនសូត្រ និងចាកចេញផុតពីភាពពក្រីក្រ ហើយក្នុងពេលជាមួយគ្នាក៏ជំរុញឱ្យមានការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ប្រទេសទាំងមូល។[8]

[7] https://km.hesperian.org/hhg/New

[8] https://www.unicef.org/cambodia/health-and-nutrition

**គ.ជំរក**

ជំរកដែលហៅសាមញ្ញថា ជាផ្ទះ វាគឺជាទីកន្លែងមួយដែលផ្តល់ភាពកក់ក្តៅសំរាប់កុមារ ដែលពួកគេអាចការពារខ្លួនឱ្យផុតពីឥទ្ធិពលធម្មជាតិមានដូចជា ភ្លៀង ព្យុះ ឬអាកាសធាតុត្រជាក់ខ្លាំង ក្តៅខ្លាំង ជាដើម។ កុមារដែលរស់នៅដោយគ្មានជំរកតែងតែកើតជម្ងឺ និងទទួលរងគ្រោះថ្នាក់ច្រើនយ៉ាង។ ផ្ទះ ជាទីកន្លែងមួយដែលកុមារត្រូវការជាចាំបាច់ ពីព្រោះវាជាទីកន្លែងដែលអាចផ្តល់ភាពកក់ក្តៅបំផុតសម្រាប់ពួកគេ ជាពិសេសនៅក្នុងកាលៈទេសៈដែលពួកគេស្ថិតក្នុងស្ថានភាពលំបាក។

**ឃ. សន្តិសុខសង្គម**

កុមារ គឺជាសមាជិករបស់សង្គមជាតិទាំងមូល មិនមែនត្រឹមតែជាសមាជិករបស់គ្រួសារណាមួយនោះទេ។ ដូច្នេះមនុស្សគ្រប់រូបក្នុងសង្គម មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យកុមារទទួល បាននូវសន្តិសុខ និងសុវត្ថិភាពក្នុងការរស់នៅ ដោយត្រូវយកចិត្តទុកដាក់ចំពោះកុមារទាំងផ្នែក ស្មារតី និងសំភារៈ។

**១.១.១.៣ សិទ្ធិទទួលបានការការពារ**

សិទ្ធិទទួលបានការការពារ គឺជាសិទ្ធិពិសេសមួយដែលរដ្ឋត្រូវធានាក្នុងការការពារកុមារពីការប្រើអំពើហិង្សា ការពារពីការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងផ្លូវភេទ ការពារពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការពារពីការរើសអើង ការពារពីការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន និងការពារពីអំពើឧក្រិដ្ឋផ្សេងៗ។ ក្នុងចំណោមសិទ្ធិធំៗទាំង ៤ ប្រភេទខាងលើ មានសិទ្ធិមួយដែលជាសិទ្ធិពិសេស ហើយត្រូវបានចាត់ទុកថា កុមារគឺជាជនងាយរងគ្រោះត្រូវមានវិធានការពិសេសដើម្បីបង្ការ និងទប់ស្កាត់នោះគឺសិទ្ធិទទួលបានការការពារ។

**ក.ការពារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរើសអើង**

កុមារមានសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ ដែលភាគច្រើនត្រូវបានធ្វើឡើងដោយមនុស្សធំ។ មាតាបិតា គប្បីនិយាយប្រាប់កូនអំពីល្បិចកលខ្លះៗ ដែលជនខិលខូចតែងតែប្រើ ដើម្បីលួងលោមបោកបញ្ឆោតក្មេងយកទៅរំលោភផ្លូវភេទ ដូចជាតាមរយៈ ការឲ្យប្រាក់ ឬ វត្ថុផ្សេងៗជាដើម ហើយមាតាបិតា ត្រូវអប់រំណែនាំកូនឱ្យចេះការពារខ្លួនផងដែរ។ មួយវិញទៀត មនុស្សគ្រប់រូបដែលរស់នៅក្នុងសង្គមមិនត្រូវបានបែងចែកឱ្យខុសៗគ្នាដោយប្រកាន់ទៅលើជាតិសាសន៍ សាសនា ពណ៌សម្បុរ ភេទ វណ្ណៈ មាន ក្រ ភាសា ជំនឿសាសនាទេ ដោយកុមារគ្រប់ៗរូបមានសិទ្ធិស្មើគ្នា និងមានសិទ្ធិរួចផុតពីការរើសអើង។ យូនីសេហ្វ ធ្វើការងារពង្រឹងប្រព័ន្ធការពារកុមាររបស់ប្រទេសកម្ពុជា ដើម្បីឱ្យកុមារអាចទទួលបានកិច្ចការពារពីការបង្កការឈឺចាប់នានា។ យើងសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អគ្គស្នងការនគរបាលជាតិ និងស្ថាប័នអង្គការពាក់ព័ន្ធដទៃទៀត ដើម្បីសម្រេចនូវចក្ខុវិស័យមួយ ដែលនាំមកនូវការផ្លាស់ប្តូរសម្រាប់ប្រទេសកម្ពុជា ក្នុងនោះកុមារី និងកុមារារាប់បញ្ចូលទាំងក្មេងជំទង់ផង អាចរួចចាកផុតពីអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចនៅក្នុងផ្ទះ សាលា និងសហគមន៍របស់ពួកគេ។ ដើម្បីឱ្យកុមារអាចទទួលបានកិច្ចការពារពីការបង្កការឈឺចាប់នានា អង្គការ

យូនីសេហ្វបានសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អគ្គស្នងការនគរបាលជាតិ និង ស្ថាប័នអង្គពាក់ព័ន្ធដទៃទៀត ដើម្បីសម្រេចនូវចក្ខុវិស័យមួយ ដែលនាំមកនូវការផ្លាស់ប្តូរសម្រាប់ប្រទេសកម្ពុជា ក្នុងនោះកុមារី និងកុមារា រាប់បញ្ចូលទាំងក្មេងជំទង់ផងអាចរស់ចាកផុតពីអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចនៅក្នុងផ្ទះ សាលា និងសហគមន៍ របស់ពួកគេ។[9]

**ខ. ជៀសវាងពីការប្រើប្រាស់គ្រឿងញៀន**

ការប្រើប្រាស់គ្រឿងញៀន ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការរស់នៅ និង សុខភាពរបស់កុមារ។ មាតាបិតា និងសហគមន៍ត្រូវការពារកុមារឱ្យគេចផុតពីបញ្ហានេះ ដោយត្រូវពន្យល់កុមារឱ្យដឹងអំពីផលប៉ះពាល់នៃគ្រឿងញៀនទៅលើសុខភាពកុមារ។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរី ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិតសម្រាប់អនុវត្តន៍នៅតាមសាលារៀនចំណេះទូទៅ។ អង្គការអប់រំពិភពលោក បានសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្នុងការបោះពុម្ពផ្សាយសៀវភៅ "ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន" ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិតតាមអនុវិទ្យាល័យ។[10]

ការដាក់បញ្ចូលសៀវភៅ "ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន" ក្នុងកម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើតគុណភាព និងប្រសិទ្ធិក្នុងការវិស័យអប់រំ ដែលនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ។ គោលបំណងទូទៅនៃឯកសារនេះ គឺផ្តល់ឱ្យសិស្សនូវចំណេះដឹង និងជំនាញដើម្បីមានជំហរ សមហេតុផលចំពោះគ្រឿងញៀន ដោយអាចធ្វើការវិភាគមានប្រសិទ្ធភាពលើគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន។

**១.១.១.៤ សិទ្ធិក្នុងការចូលរួម**

សិទ្ធិក្នុងការចូលរួម គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិផ្សេងៗទៀត ដែលផ្តល់ឱកាសឲ្យកុមារបានចូលរួមក្នុងសកម្មភាពសង្គម និងចូលរួមគ្រប់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងប្រយោជន៍កុមារ ដោយគ្មានការរើសអើង និងដោយការគោរពទៅវិញទៅមក។ កុមារគ្រប់រូបមានសេរីភាពក្នុងការគិត និងបញ្ចេញមតិយោបល់ ដើម្បីជួយឱ្យពួកគេចេះគិត និងសម្រេចចិត្តចំពោះបញ្ហាទាក់ទងនឹងការរស់នៅរបស់ពួកគេ។ កុមារត្រូវបានបង្កើតជាក្រុម ឬសមាគមន៍ដែលត្រឹមត្រូវនៅសាលារៀនឬនៅទីកន្លែងមានសុវត្ថិភាពផ្សេងៗទៀត ដើម្បីជំរុញឲ្យពួកគេមានសេចក្តីក្លាហាន ក្នុងការបញ្ចេញសមត្ថភាព ទេពកោសល្យរបស់ពួកគេ ហើយរួមចំណែកផ្សព្វផ្សាយព័ត៌មាន និងចូលរួមបញ្ចេញមតិដោយសេរីទៅលើអ្វីដែលប៉ះពាល់ជីវិតរស់នៅរបស់ខ្លួន ដោយគំនិតទាំងនោះ គប្បីត្រូវបានអ្នកឯទៀតយកចិត្តទុកដាក់ស្តាប់ និងយកទៅពិចារណាផ្តល់តម្លៃ។

---

[9] កិច្ចការពារកុមារ | អង្គការយូនីសេហ្វ (unicef.org)

[10] សេចក្តីប្រកាសលេខ ២៥២៤ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយសៀវភៅ "ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន"

**ក. ការបញ្ចេញមតិយោបល់**

កុមារមានសិទ្ធិបញ្ចេញនូវទស្សនៈ សម្តែងមតិដោយសេរី រាប់បញ្ចូលទាំងទទួលបាននិងផ្សព្វផ្សាយព័ត៌មាន និងធ្វើឱ្យគំនិត ឬព័ត៌មាននោះ ត្រូវបានគេដឹងលឺដោយគ្មានការដាក់កំហិត ។ ប៉ុន្តែការប្រើប្រាស់សិទ្ធិនេះនឹងអាច ស្ថិតក្រោមការរឹតត្បិតខ្លះបានលុះត្រាតែការរឹតត្បិតនោះ ត្រូវបានអនុញ្ញាតដោយច្បាប់ និងមានលក្ខណៈចាំបាច់ ដូចជា ដើម្បីគោរពសិទ្ធិនិងកិត្តិនាមរបស់អ្នកដទៃ ឬដើម្បីការពារសន្តិសុខជាតិឬសណ្តាប់ធ្នាប់ សុខភាពឬសីលធម៌ សាធារណៈ។[11] មាតាបិតា ឬ អាណាព្យាបាល ត្រូវបង្កលក្ខណៈងាយស្រួល និងលើកទឹកចិត្តឱ្យកុមារចូលរួម បញ្ចេញមតិយោបល់ ជួយឱ្យកុមារ ចេះគិត និងចេះធ្វើការសម្រេចចិត្តចំពោះបញ្ហាទាក់ទងនឹងជីវិត និងការរស់ នៅប្រចាំថ្ងៃរបស់ពួកគេ។

**ខ. ការចូលរួមបង្កើតក្រុម ឬសហគមន៍**

កុមារមានសិទ្ធិចូលរួមបង្កើតក្រុម ឬសហគមន៍ទោះនៅក្នុងសហគមន៍ នៅសាលារៀន ឬនៅទីកន្លែង មានសុវត្ថិភាពផ្សេងៗទៀតក្តី។ មនុស្សចាស់ត្រូវលើកទឹកចិត្តកុមារឱ្យមានសេចក្តីក្លាហាន ចូលរួមក្នុងសកម្មភាព ផ្សេងៗ ដែលជាឱកាសល្អជួយឱ្យពួកគេបានប្រើប្រាស់ និងបង្កើតសក្តានុពលព្រមទាំងទេពកោសល្យដែលមាន ស្រាប់។

**គ. ការចូលរួមផ្សព្វផ្សាយព័ត៌មាន**

កុមារមានសិទ្ធិក្នុងការទទួលព័ត៌មានសមស្របពីប្រភពផ្សេងៗ ជាពិសេសឯកសារដែលលើកកម្ពស់ការ យល់ដឹងផ្នែកសុខុមាលភាពសង្គម បញ្ញាស្មារតី និងព័ត៌មានដែលមានសីលធម៌។ ដូចនេះ សហគមន៍ មាតាបិតា ត្រូវបង្កលក្ខណៈងាយស្រួលឱ្យកុមារទទួលបាននូវពត៌មានទាំងនោះព្រមទាំងចូលរួមធ្វើការផ្សព្វផ្សាយបន្តឱ្យបាន ទូលំទូលាយដល់អ្នកដទៃទៀត ហើយមានសារៈប្រយោជន៍ទៅលើការយល់ដឹង និងសុវត្ថិភាពកុមារ។

**ឃ. ការចូលរួមសកម្មភាពសង្គម**

កុមារមានសិទ្ធិចូលរួមសកម្មភាពផ្សេងៗទៅតាមវ័យរបស់ពួកគេដើម្បីចូលរួមចំណែកអភិវឌ្ឍន៍គ្រួសារ និង សហគមន៍ មានជាអាទិ៍ការជួយសំរាលការងារផ្ទះ ការថែរក្សាបរិស្ថាន ការដាំ ដើមឈើ ការជួយការពារសម្បត្តិ សាធារណៈ និង ការលើកស្ទួយវប្បធម៌ប្រពៃណីជាតិជាដើម។ មាតាបិតាឬអាណាព្យាបាលត្រូវបានធានាថាការ ចូលរួមទាំងនោះត្រូវបានធ្វើឡើងដោយមិនប៉ះពាល់ដល់ផលប្រយោជន៍និងការអភិវឌ្ឍន៍របស់កុមារ។ កុមារមាន សិទ្ធិចូលរួមក្នុងសង្គម និងកម្មវិធីផ្សេងៗដោយខ្លួនឯង។ ក្នុងការរួមបញ្ចូលនេះការភ្ជាប់ទាក់ទងរបស់កុមារ ក្នុង បណ្ណាល័យនិងក្នុងកម្មវិធីដែលទាក់ទងនិងសង្គម សកម្មភាពសំលេងយុវជន និងការជាប់ទាក់ទងនិងការអប់រំដល់ កុមារ។

[11] មាត្រា១៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ,ឆ្នាំ១៩៨៩

### ១.១.១.៥ ការទទួលបានការអប់រំ

ការអប់រំគឺជាការវិនិយោគលើអនាគតកុមារ និងប្រទេសជាតិ។ ការអប់រំមានសារៈសំខាន់ចំពោះការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា គឺផ្ដោតការយកចិត្តទុកដាក់លើប្រជាពលរដ្ឋវ័យក្មេង ពោរពេញដោយភាពស្វាហាប់ និងចល័តភាព ដោយចាត់ទុកពួកគេជាអ្នកចូលរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ រដ្ឋាភិបាលបន្តវិភាជន៍ថវិការដ្ឋ ក្នុងចំនួនមួយដ៏ច្រើនសម្រាប់វិស័យអប់រំ ហើយយូនីសេហ្វ កំពុងប្រើប្រាស់ឱកាសបច្ចុប្បន្ននេះ ដើម្បីធ្វើកំណែទម្រង់វិស័យអប់រំ។ កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្ដល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍន៍ខ្លួនឈានទៅសម្រេចបានសក្ដានុពលរបស់ពួកគេ។[12]

កុមារមានសិទ្ធិក្នុងការទទួលបាននូវការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ។ រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្តយុទ្ធសាស្ត្រ "អប់រំសម្រាប់ទាំងអស់គ្នា" តាមរយៈការធានាសមធម៌ ក្នុងការអប់រំមូលដ្ឋានយ៉ាងតិចរយៈពេលប្រាំបួនឆ្នាំ សំរាប់កុមារគ្រប់រូប។[13] ការអប់រំក្នុងប្រព័ន្ធគឺជាការអប់រំគ្រប់កំរិតគឺថ្នាក់មត្តេយ្យ ដល់ថ្នាក់ឧត្តមសិក្សា។ រដ្ឋត្រូវធានាថា ការអប់រំកំរិត បឋមសិក្សាមិនមានការបង់ថ្លៃ និងមានលក្ខណៈជាកាតព្វកិច្ច និងត្រូវជំរុញឱ្យមានរូបភាពផ្សេងៗគ្នានៃការអប់រំកំរិតអនុវិទ្យាល័យដែលកុមារគ្រប់រូបអាចទទួលបាននិងត្រូវធ្វើឱ្យការអប់រំកំរិតឧត្តម អាចទទួលបានសម្រាប់មនុស្សគ្រប់រូប ដោយផ្អែកលើមូលដ្ឋានសមត្ថភាព។[14] រីឯការអប់រំក្រៅប្រព័ន្ធរួមមានការបង្រៀនអនក្ខរកម្ម និងជំនាញវិជ្ជាជីវៈផ្សេងៗ។ល។ ដើម្បីឱ្យកុមារមានលទ្ធភាព ប្រកបរបរចិញ្ចឹមជីវិត និងក្លាយជាពលរដ្ឋល្អក្នុងសង្គម ក្រុមគ្រួសារ សហគមន៍ វត្តអារាមអង្គការ និងស្ថាប័ននានា មានតួនាទីសំខាន់ក្នុងការជំរុញ និងបង្កលក្ខណៈឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិខាងលើនេះ។

ដើម្បីផ្ដល់ឱ្យកុមារគ្រប់រូបនូវលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន អង្គការយូនីស្វេ បានសហការជាមួយរាជរដ្ឋាភិបាល និងដៃគូដទៃទៀត ក្នុងការលុបបំបាត់នូវឧបសគ្គដែលរារាំងមិនឱ្យកុមារអាចទៅរៀនបាន ដូចជាភាពក្រីក្រ ភាពនៅដាច់ស្រយោល ការមាក់ងាយ និងការរើសអើងជាដើម។ ការសហការជាមួយរាជរដ្ឋាភិបាលដើម្បីផ្ដល់ អាហារូបករណ៍ដល់កុមារមកពីគ្រួសារក្រីក្រ ដើម្បីឱ្យពួកគេអាចបន្តទៅរៀនបាន ជាជាងបោះបង់ចោលការសិក្សាទៅរកការងារធ្វើទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាពជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល ផ្ដល់នូវសម្ភាររូបវន្តក្នុងសាលារៀនដែលកុមារី និងកុមារាទាំង

12 ការអប់រំ | អង្គការយូនីសេហ្វ ( unicef.org )

13 មាត្រា៦៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

14 ចំណុច១ មាត្រា២៨ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ,១៩៨៩

មានពិការភាព ទាំងគ្មានពិការភាព ងាយស្រួលប្រើប្រាស់ សាលារៀនដែលមានបរិក្ខារអនាម័យ និងទឹកស្អាតគ្រប់គ្រាន់។[15]

**ក.ការលេងកំសាន្ត និងលំហែកាយ**

កុមាររៀន និងស្វែងយល់តាមរយៈការលេងកំសាន្ត។ ការលេងកំសាន្តធ្វើឱ្យកុមាររីកចំរើន ផ្នែកបញ្ញា រាងកាយ ភាសា ទំនាក់ទំនង មនោសញ្ចេតនា និងសង្គម ដូចជាការប្រាស្រ័យទាក់ទងជាមួយមជ្ឈដ្ឋានខាងក្រៅជាដើម ការរៀនបែបនេះធ្វើឱ្យខួរក្បាលលូតលាស់ បង្កើនការចងចាំ និងអភិវឌ្ឍន៍សមត្ថភាពដោះស្រាយបញ្ហា។ ដូចនេះកុមារគួរតែមានឱកាសលំហែ កំសាន្ត ទៅតាមចំណូលចិត្តរបស់ខ្លួនសមស្របទៅតាមអាយុរបស់កុមារ និងចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌ និងសិល្បៈ ប្រសិនបើទង្វើនោះពុំនាំឱ្យមានគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។

**ខ. ការទទួលបានព័ត៌មាន**

ដើម្បីពង្រឹងចំណេះដឹងឱ្យបានទូលំទូលាយកុមារត្រូវទទួលបានព័ត៌មានដែលទាក់ទងនឹងជីវិតរបស់គេដោយផ្ទាល់ ឬ ដោយប្រយោលក្តី។ នេះជាឱកាសដែលកុមារស្គាល់ពីការទទួលខុសត្រូវ និង តួនាទីរបស់ខ្លួននៅក្នុងសង្គម។ ក្រសួងព័ត៌មានបានគូសបញ្ជាក់ថា ការលើកកម្ពស់ ការចូលរួមរបស់កុមារ គឺផ្តល់ឱកាសឱ្យកុមារបានចូលរួមធ្វើការសម្រេចចិត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការដាក់ស្តែង ដែលពាក់ព័ន្ធទៅនឹងកុមារ ព្រោះតែកុមារខ្លួនឯង ទើបដឹងពីស្ថានភាពខ្លួនច្បាស់លាស់។[16]

### ១.១.២. អនុសញ្ញាស្តីពីសិទ្ធិកុមារ

អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជា សន្ធិសញ្ញាអន្តរជាតិ ដែលមានចែងពីបទដ្ឋានអប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សំរាប់ការប្រព្រឹត្តលើកុមារនៅក្នុងសង្គម។ អនុសញ្ញានេះគឺជាសេចក្តីថ្លែងលម្អិតមួយពីសិទ្ធិទាំងឡាយដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ។

#### ១.១.២.១. ប្រវត្តិនៃការបង្កើត

ប្រវត្តិនៃការកំណត់អនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយមានព្រឹត្តិការណ៍ឧក្រិដ្ឋកម្មដ៏ឃោរឃៅព្រៃផ្សៃ និងសោកនាដកម្មនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៤២ ដែលពួកហ្វាស៊ីសបានសម្លាប់ប្រជាជន ជាពិសេសកុមារក្នុងអំឡុងសង្គ្រាមលោកលើកទី២ បានធ្វើឱ្យមនុស្សជាតិតក់ស្លុត និងចងចាំជានិច្ចហើយត្រូវបានសាធារណៈមតិទូទាំងសកលលោកថ្កោលទោស និងមូលមតិគ្នាបង្កើតអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្តីពីសិទ្ធិកុមារឡើង។ មូលហេតុនៃការបង្កើតអនុសញ្ញាស្តីពីសិទ្ធិកុមារៈ

[15] ការអប់រំ | អង្គការយូនីសេហ្វ (unicef.org)

[16] https://www.information.gov.kh/articles/24082

- នៅក្នុងសង្គមជាច្រើនពុំទាន់មានច្បាប់ឬរចនាសម្ព័ន្ធសង្គមជាក់លាក់សម្រាប់ធានាដល់សិទ្ធិរបស់កុមារ
- ការអភិវឌ្ឍរបស់កុមារ ជាផ្នែកមួយដ៏សំខាន់បំផុតនៃអនាគតរបស់សង្គមជាតិនីមួយៗ
- តម្រូវការចាំបាច់ជាច្រើនរបស់កុមារ ពុំទាន់មានចែងនៅក្នុងឧបសម្ព័ន្ធសិទ្ធិមនុស្សដែលមានស្រាប់នៅឡើយ
- កុមារពុំមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់
- កុមារ ងាយនឹងទទួលផលប៉ះពាល់ជាក្រុមអាយុផ្សេងៗទៀត
- សង្គមជាតិនីមួយៗ ត្រូវមានកាតព្វកិច្ចបំពេញរាល់សេចក្តីត្រូវការចាំបាច់របស់កុមារទាំងបុគ្គលភាព ប្រាជ្ញាស្មារតី ទាំងសុវត្ថិភាព។

នៅក្នុងអតីតកាល កុមារត្រូវបានគេចាត់ទុកគ្រាន់តែជាអ្នករងអំពើ ឬកម្មវត្ថុដែលគេប្រព្រឹត្តទៅលើប៉ុណ្ណោះ។ ប៉ុន្តែឥឡូវនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់កុមារថាជាមនុស្សដែលមានសិទ្ធិរបស់គេផ្ទាល់ គឺជាសិទ្ធិដែលទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួន ពីអ្នកមានភារកិច្ចនានា ដូចជាឪពុក-ម្តាយ និងរដ្ឋ ជាពិសេសមន្ត្រីនគរបាល និងតុលាការដែលមានភារកិច្ចគោរព ការពារ និងបំពេញតាមសិទ្ធិរបស់កុមារ ។

ដូចសិទ្ធិមនុស្សទាំងអស់ដែល សិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារមិនអាចបំបែកចេញពីគ្នាបានទេ។ នេះមានន័យថាសិទ្ធិទាំងអស់មាន ទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាមួយសំខាន់ជាងសិទ្ធិណាមួយឡើយ។ទោះយ៉ាងណាក៏ដោយអនុសញ្ញាស្តីពីសិទ្ធិកុមារ យកចិត្តទុកដាក់ចំពោះភាពខុសគ្នានៃវប្បធម៌នយោបាយនិងស្ថានភាពពិតខាងផ្នែកសំភារៈក្នុងចំណោមរដ្ឋនានា។ អ្វីដែលត្រូវយកមកពិចារណាជាចម្បងបំផុតនោះគឺឧត្តមប្រយោជន៍របស់កុមារ។

អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ គឺជាថ្ងៃដែលប្រារព្ធដោយសហប្រជាជាតិធ្វើជាទិវាកុមារសកល។[17]

ព្រះរាជាណាចក្រកម្ពុជា បានចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ ជារដ្ឋភាគីនៃពិធីសារបន្ថែមប្រឆាំងនឹងការជួញដូរកុមារ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០២ និងជារដ្ឋភាគីនៃពិធីសារបន្ថែមស្តីពីការពាក់ព័ន្ធកុមារនៅក្នុងជំលោះប្រដាប់អាវុធនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦។ តាមរយៈការចូលជាភាគីនេះ ព្រះរាជាណាចក្រកម្ពុជា ប្តេជ្ញា ការពារ និងបំពេញតាមសិទ្ធិនានារបស់កុមារទាំងអស់នៅកម្ពុជា។

[17] មហាសន្និបាតអង្គការសហប្រជាជាតិបានចាត់ទុកថ្ងៃទី២០ខែវិច្ឆិកា ថាជាទិវាកុមារសកល នៅឆ្នាំ១៩៥៤។ សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ក៏ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២០ខែវិច្ឆិកាដែរ តែក្នុងឆ្នាំ១៩៥៩។ នៅកម្ពុជា ទិវាកុមារអន្តរជាតិ គឺប្រារព្ធធ្វើនៅរៀងរាល់ថ្ងៃទី១ ខែមិថុនា។

### **១.១.២.២. សិទ្ធិពិសេស**

កុមារមានសិទ្ធិឱ្យគេប្រព្រឹត្តទៅលើ ដូចមនុស្សពេញវ័យដទៃទៀតដែរ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព។ ក្នុងពេលជាមួយគ្នានេះដែរ កុមារក៏មានសិទ្ធិពិសេសបន្ថែម ដោយសារតែពួកគេមានវ័យក្មេង និងងាយរងគ្រោះ។ កុមារនឹងមិនអាចរស់រាន និងឈានដល់សក្តានុពលពេញលេញ បើគ្មានជំនួយ និងការសហការពីមនុស្សពេញវ័យ។ គោលបំណងរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺបង្កើតជាបទដ្ឋានសម្រាប់ការពារកុមារប្រឆាំងនឹងការទុកចោលមិនយកចិត្តទុកដាក់ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើងដែលខ្លួនជួបប្រទះក្នុងកំរិតផ្សេងៗជារៀងរាល់ថ្ងៃនៅគ្រប់ប្រទេស។[18]

[18] យូនីសេហ្វ. ២០០៩. អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម, ០៨ ។

# ជំពូកទី២
# វិស័យអប់រំក្នុងប្រទេសកម្ពុជា

# ជំពូកទី២
# វិស័យអប់រំក្នុងប្រទេសកម្ពុជា

កម្ពុជាបានចាប់ផ្ដើមកសាងរចនាសម្ព័ន្ធ និងស្ថាប័ននយោបាយ សង្គម និងសេដ្ឋកិច្ចឡើងវិញ ដោយសម្រេចបានលទ្ធផលធំធេងក្នុងការដោះស្រាយបញ្ហាប្រឈមធំ ដោយប្រើប្រាស់រយៈពេលខ្លីកម្ពុជាមានលទ្ធភាពបង្កើត និងរៀបចំប្រព័ន្ធអប់រំថ្នាក់ជាតិឡើងវិញដោយបានដាក់ចេញនូវគោលបំណងគោលនយោបាយយ៉ាងច្បាស់លាស់ យន្តការអភិបាលកិច្ចដែលលមានដំណើរការ និងគ្រឹះស្ថានសិក្សាជាច្រើននៅទូទាំងប្រទេស។ ប្រព័ន្ធអប់រំបានផ្ដល់សេវាអប់រំដល់ សិស្ស មាតាបិតា គ្រូបង្រៀន និងអ្នកសិក្សាពេញវ័យរាប់សែននាក់នៅទូទាំងប្រទេស។[19] ស្របនឹងការប្ដេជ្ញាចិត្តខ្ពស់នៅថ្នាក់ជាតិ ភាពជាដៃគូ និងការរៀបចំអន្តរាគមន៍ចំគោលដៅ បានផ្ដល់នូវកាលានុវត្តដ៏ធំធេង ដើម្បីធានាឱ្យកុមារគ្រប់រូបអាចទទួលបានការអប់រំ។ វិស័យអប់រំនៅកម្ពុជាមានការអភិវឌ្ឍរីកចម្រើនទៅតាមសម័យកាល តាមស្ថានភាពប្រទេសនៃសម័យកាល និងតាមរយៈឆន្ទៈរបស់មេដឹកនាំប្រទេសផងដែរ។

សម្រាប់បច្ចុប្បន្នកាល រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតាក្នុងការផ្លាស់ប្ដូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ដូចនេះមានតែការពង្រឹង និងអភិវឌ្ឍន៍វិស័យអប់រំទេ ដែលជាកត្តាអាទិភាពសម្រាប់ឱ្យគោលដៅនេះ ឈានទៅសម្រេចបានជោគជ័យ ដោយពឹងផ្អែកលើសមត្ថភាពរបស់ប្រជាជនក្នុងការក្រេបយកចំណេះដឹង សមស្របនឹងជំនាញពាក់ព័ន្ធ ដែលអាចឆ្លុះបញ្ចាំងពីមរតកវប្បធម៌ និងសីលធម៌របស់ប្រទេសជាតិ។ កុមារ យុវជន និង មនុស្សពេញវ័យត្រូវមានសិទ្ធិចូលរៀននៅសាលាចំណេះដឹងទូទៅរបស់រដ្ឋដោយឥតបង់ថ្លៃហោចណាស់ត្រឹមបញ្ចប់កម្រិតមូលដ្ឋានថ្នាក់ទី៩។ [20] ការអប់រំត្រូវផ្ដល់ឱកាសដល់សិស្ស និងផ្ដោតលើការកសាងជំនាញបច្ចេកទេសវិជ្ជាជីវៈ និងជំនាញឯកទេស ដែលអាចធ្វើឱ្យពួកគេអាចមានអាជីពមួយច្បាស់លាស់។[21] ទោះជាមានវឌ្ឍនភាពបែបនេះក៏ដោយ កុមារនៅកម្ពុជានៅពុំទាន់រៀនទាន់ស្តង់ដានៃការរៀនសូត្រដែលអាចទទួលយកបាន ស្របទៅតាមអាយុរបស់ពួកគេឡើយ។ នៅកម្រិតបឋមសិក្សា មានកុមាររៀនថ្នាក់ទី៣ ជិត២៥ភាគ រយពុំចេះសរសេរសូម្បីតែពាក្យមួយម៉ាត់នៅក្នុងតេស្តសរសេរតាមអាន។ កុមារអាយុពី ៣ ទៅ ៥ឆ្នាំ ត្រឹមតែ២៧ភាគរយ តែប៉ុណ្ណោះ ដែលមានការអភិវឌ្ឍចំណេះដឹងអក្សរ និងលេខនព្វន្តស្របទៅតាមអាយុរបស់ពួកគេ ហើយមានក្មេងជំទង់ ៥៥ ភាគរយបោះបង់ចោលការសិក្សាមុនពេលពួកគេមានអាយុ ១៧ឆ្នាំ។[22]

---

[19] ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០,ទំព័រ ១៤

[20] មាត្រា៦៨ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា

[21] ការអប់រំ និង ការអភិវឌ្ឍនៅកម្ពុជា ដោយឯកឧត្តម កង ឱម (បណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំ), ទំព័រ ១

[22] ការអប់រំ | អង្គការយូនីសេហ្វ អង្គការយូនីសេហ្វ (unicef.org)

## ២.១. សិទ្ធិទទួលបានការអប់រំនៅកម្ពុជា

ការអប់រំនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយរដ្ឋតាមរយៈក្រសួងអប់រំនៅថ្នាក់ជាតិ និងដោយក្រសួងអប់រំនៅថ្នាក់ខេត្ត។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថារដ្ឋត្រូវការពារនិងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋឱ្យមានគុណភាពអប់រំគ្រប់កម្រិតទាំងអស់ដោយធានាថាពលរដ្ឋទាំងអស់មានឱកាសស្មើគ្នាក្នុងការរស់នៅ។[23] រដ្ឋនឹងអនុម័តកម្មវិធីអប់រំយោងតាមគោលការណ៍គរុកោសល្យទំនើបរួមទាំងបច្ចេកវិទ្យានិងភាសាបរទេស ព្រមទាំងរដ្ឋគ្រប់គ្រងសាលារៀនសាធារណៈនិងឯកជននិងថ្នាក់រៀននៅគ្រប់កម្រិត។[24] ប្រព័ន្ធអប់រំនៅកម្ពុជារួមមានសាលាបឋមសិក្សា អនុវិទ្យាល័យទូទៅ ការអប់រំខ្ពស់ និងការអប់រំក្រៅផ្លូវការ និងរួមមានការអភិវឌ្ឍកីឡា ការអប់រំបច្ចេកវិទ្យាព័ត៌មាន ការអភិវឌ្ឍការស្រាវជ្រាវ និងការអប់រំបច្ចេកទេស។ កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍន៍ខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពយ៉ាងគាប់ប្រសើរ ក្នុងការផ្តល់ការអប់រំដល់កុមាររបស់ខ្លួន។ ចាប់តាំងពីឆ្នាំ២០០៧ មកចំនួនកុមារដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកម្រិត មត្តេយ្យសិក្សាកើនឡើងទ្វេដង។ ចំនួនកុមារដែលចុះឈ្មោះចូលរៀនក្នុងកម្រិតអប់រំបឋមសិក្សាកើនឡើងពី ៨២ ភាគរយក្នុងឆ្នាំ ១៩៩៧ ដល់ជាង ៩៧ ភាគរយក្នុងឆ្នាំសិក្សា ២០១៧-២០១៨។[25]

ទោះជាមានវឌ្ឍនភាពបែបនេះក៏ដោយ កុមារនៅកម្ពុជា នៅពុំទាន់រៀនទាន់ស្តង់ដានៃការរៀនសូត្រដែលអាចទទួលយកបាន ស្របទៅតាមអាយុរបស់ពួកគេឡើយ។ នៅកម្រិតបឋមសិក្សា មានកុមាររៀនថ្នាក់ទី៣ ជិត ២៥ ភាគរយពុំចេះសរសេរសូម្បីតែពាក្យមួយម៉ាត់នៅក្នុងតេស្តសរសេរតាមអាន។

### ២.១.១. ការអប់រំទូទៅនៅប្រទេសកម្ពុជា

#### ២.១.១.១. ប្រវត្តិនៃការអប់រំ

ប្រពៃណីការអប់រំនៅប្រទេសកម្ពុជាត្រូវបានចេញពីវត្តអារាម ហើយព្រះសង្ឃគឺជាគ្រូបង្រៀន។ សិស្សភាគច្រើនគឺសុទ្ធតែក្មេងប្រុស ហើយការអប់រំគឺត្រូវបានកំណត់ឱ្យទន្ទេញដដែលៗដូចព្រះសង្ឃទន្ទេញបាលី។ អំឡុងពេលបារាំងគ្រប់គ្រង ប្រព័ន្ធអប់រំជាផ្អែកលើភាសាបារាំងត្រូវបានផ្តើមបញ្ជ្រាបចូលជាលំដាប់។ ដំបូងបារាំងបានធ្វេសប្រហែសចំពោះការអប់រំនៅប្រទេសកម្ពុជា។

[23] មាត្រា ៦៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[24] មាត្រា ៦៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[25] អង្គការទិន្នន័យអំពីការអភិវឌ្ឍ អត្ថបទការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា

ចាប់ពីមុនសតវត្សន៍ទី២០រហូតដល់ឆ្នាំ១៩៧៥ ប្រព័ន្ធនៃការអប់រំបានប្រតិបត្តិទៅតាមគំរូរបស់បារាំង។ ប្រព័ន្ធនៃការអប់រំត្រូវបានបែងចែកទៅជា បឋមសិក្សា អនុវិទ្យាល័យហើយនិងកំរិតខ្ពស់។ ការអប់រំក្នុងរបប សាធារណៈរដ្ឋប្រជាមានិតកម្ពុជាត្រូវបានស្ថិតនៅក្រោមអំណាចច្បាប់ក្រសួងអប់រំដែលជាអ្នកមើលការខុសត្រូវ ទាំងស្រុង វាបានធ្វើនិទស្សន៍នៃភាសា ស៊ីឈ្នួល និងចំណាយទៅលើគ្រូបង្រៀនឱ្យតែផ្គត់ផ្គង់ និងធ្វើអធិការកិច្ច ដល់សាលា ហើយនាយករបស់សាលាបឋមសិក្សាម្នាក់ដែលជាអ្នកមានអំណាចគឺត្រូវបានកំណត់ឱ្យទៅតាម បណ្ដាលខេត្ត។ គណៈកម្មាធិការវប្បធម៌នៅក្រោមក្រសួងអប់រំគឺទទួលខុសត្រូវចំពោះការបង្កើនឡើងនៅភាសា កម្ពុជា។

ការអប់រំជាដំបូងបានចែកជាពីរជុំនៃបីឆ្នាំដូចគ្នាគឺត្រូវបានបញ្ចូលខាងក្រៅប្រព័ន្ធអប់រំ និងខាងក្នុង ប្រព័ន្ធអប់រំហើយការសម្រេចជោគជ័យនៃការប្រលងបញ្ចប់បានទទួលវិញ្ញាបនប័ត្របន្ទាប់ពីការវគ្គនីមួយៗ។ វគ្គ សិក្សាអប់រំដំបូងស្ថិតលើការគណនានព្វន្តសាស្ត្រ ប្រវត្តិសាស្ត្រ សីលធម៌ ពលរដ្ឋ ការព្រាង ភូមិសាស្ត្រ សុខ វិទ្យា ភាសា ហើយនិង វិទ្យាសាស្ត្រ។ ថែមទាំងបានបញ្ចូលមុខវិជ្ជា អប់រំផ្លូវចិត្ត ហើយនិងការងារហត្ថកម្ម។ ការ សិក្សាភាសាបារាំងបានចាប់ផ្ដើមក្នុងរយៈពេលពីរឆ្នាំ។ ខ្មែរគឺជាភាសាការអប់រំក្នុងសម័យកាលដំបូង ប៉ុន្តែបារាំងគឺ ត្រូវបានបំរើក្នុងសម័យកាលលើកទីពីរហើយ និងមានបន្ទាប់មកទៀត។ ដោយមុនឆ្នាំ១៩៧០ ខ្មែរត្រូវបានបន្ថែម យ៉ាងទូលំទូលាយនៅក្នុងបឋមសិក្សា។ សាកលវិទ្យាល័យភ្នំពេញដែលជាសាកលវិទ្យាល័យធំជាងគេបង្អស់ មានសិស្សប្រុសជិត ៤៥៧០ នាក់ និងថែមសិស្សស្រីជាង៧៣០ ក្នុងប្រាំបី ផ្នែក មនុស្សសាស្ត្រ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ច្បាប់ និងសេដ្ឋកិច្ច ថ្នាំកែរោគ គិលានុដ្ឋាន ពាណិជ្ជសាស្ត្រ គរុកោសល្យ និងឧត្តមគរុ កោសល្យ។ សាកលវិទ្យាល័យបានប្រតិបត្តិក្នុងខេត្ត កំពង់ចាម តាកែវ បាត់ដំបង និង ក្នុងរាជធានីភ្នំពេញ សាកលវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និង សាកលវិទ្យាល័យវិចិត្រសិល្បៈ។ ក្នុងអំឡុងពេលរបបខ្មែរក្រហម ការ អប់រំគឺធ្លាក់ចុះ និងធ្លាប់រីកចម្រើនថយចុះការសរសេរ និងការអប់រំអំឡុងពេលពីរទស្សវត្សន៍ដោយទទួលឯក រាជ្យគឺត្រូវបានលុបបំបាត់ប្រព័ន្ធអប់រំចោល។ សាលាត្រូវបានបិទបានអប់រំមនុស្ស និងគ្រូបង្រៀនគឺបានធ្វើជា កូនចៅគេ គ្រប់គ្រងដោយគ្រោគគ្រាត និងអាក្រក់បំផុតប្រហារជីវិត។ ឯកសារសូវៀតបានរាយការណ៍ថា ៩០ ភាគរយនៃគ្រូបង្រៀនទាំងអស់ត្រូវបានសំលាប់ក្រោមរបបខ្មែរក្រហម។ ការអប់រំដែលនៅសល់តិចតួចគឺត្រូវបាន ប្រមូលផ្ដុំដោយបដិវត្តន៍ខ្មែរ ក្មេងជាអ្នកអប់រំមនុស្សចាស់ ប៉ុន្តែការទទួលយកចំណេះគឺមិនទៀងទាត់ ហើយ ជំនាន់ក្មេងកម្ពុជាទូទាំងប្រទេសសុទ្ធតែជាអក្ខរជន។ បន្ទាប់មកខ្មែរក្រហមត្រូវបានកាន់កាប់អំណាចប្រព័ន្ធអប់រំ បានបង្កើតឡើងវិញ ចាប់ពីគ្មានអ្វីទាំងអស់។ ក្រោយមកទៀត ការអប់រំនៅកម្ពុជានៅទទួលបាននូវភាព ជោគជ័យ ទៅលើការអប់រំកុមារ។[26] ការចុះឈ្មោះចូលរៀនឱ្យថ្នាក់មត្តេយ្យកើតច្រើនទ្វេដងចាប់តាំងឆ្នាំ២០០៧

[26] អត្ថបទដកស្រង់ ពីគេហទំព័រការិយាល័យអប់រំ យុវជន និងកីឡាស្រុកព្រៃឈរ

សិស្សចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សានៅឆ្នាំ១៩៩៧ មានចំនួន៨២% តែកើតដល់៩៧%នៅក្នុងឆ្នាំ ២០១៧។

ការអប់រំនៅកម្ពុជា គ្រប់គ្រងដោយរដ្ឋាភិបាល តាមរយៈក្រសួងអប់រំយុវជន និង កីឡា នៅថ្នាក់ជាតិ និង មន្ទីរអប់រំនៅថ្នាក់ខេត្ត។ ប្រព័ន្ធអប់រំនៅកម្ពុជាមានដូចសាលា មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ការអប់រំនៅឧត្តមសិក្សា និង កាអប់រំវិជ្ជាជីវៈ។ ការអប់រំថ្នាក់បឋមនៅប្រទេសកម្ពុជាគឺចាប់ផ្តើមពីអាយុ៦ឆ្នាំ ដែលមានរយៈពេល៦ឆ្នាំ។ នាឆ្នាំ២០១៧ ប្រទេសកម្ពុជាមានសាលាបឋមសិក្សាចំនួន ៧១៤៤ សាលា និង៩៦ កន្លែងទៀតនៅតំបន់ជួបការលំបាក ដែលមានបុគ្គលិកចំនួន ៤៦១៤៩នាក់ បង្រៀនសិស្សចំនួន២០២២០៦១នាក់។ នៅឆ្នាំ១៩៩៣ ក្រសួងអប់រំបានបែងចែកការអប់រំថ្នាក់បឋមសិក្សាជាកំរង។ កំរង មានដូចជាសាលាបឋមសិក្សា ការសិក្សាចំនេះដឹងទូទៅ ដែលជាផ្នែកមួយនៃប្រព័ន្ធអប់រំ។ នៅក្នុងកំរងនីមួយៗ មាន៦ទៅ៧សាលាក្នុងគោលបំណង អភិវឌ្ឍន៍គុណភាពដោយការផ្តល់ជូននៅហិរញ្ញវត្ថុ និងធនធាននៃការអប់រំ ជាមួយនិងបទពិសោធន៍គ្រប់គ្រងសាលា ជាបណ្តាញ និងការពិភាក្សារវាងបុគ្គលិក និងគ្រូបង្រៀន។ ក្រសួងអប់រំបានកំណត់ថាសាលាកំរងគឺជា យន្តការការងារដែលមានប្រសិទ្ធភាពក្នុងការផ្គត់ផ្គង់ដោយផ្ទាល់សម្រាប់សហគមន៍ក្នុងការផ្សព្វផ្សាយការចុះឈ្មោះចូលរៀនរបស់កុមារ។ តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនៅសកម្មភាពជាច្រើនក្នុងការបង្រៀនដើម្បីពង្រឹងសមត្ថភាពអប់រំជាពិសេសគឺការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សឱ្យកាន់តែមានប្រសិទ្ធភាព រួមមានការសិក្សាតាមបែបសាលាកុមាមេត្រី បរិស្ថានសាលា ពង្រឹងសិស្សខ្សោយ និងការសិក្សានៅបណ្ណាល័យ។ ទោះបីជាមានការសិក្សាបែបទំនើបក៏ដោយ ក៏នៅមានការបង្រៀន តាមបែបទ្រឹស្តី និងការចងចាំ។ ការអប់រំនៅថ្នាក់បឋមគឺផ្តោតទៅលើកម្មវិធីជំនាញមូលដ្ឋាន អក្សរ លេខ និងសិល្បៈ ជាដើម។ ភាសាគោលក្នុងការបង្រៀនគឺជាភាសាខ្មែរ មិនតែប៉ុណ្ណោះក្រសូងអប់រំបានបញ្ចូលកម្មវិធីសិក្សាភាសាអង់គ្លេសដែលចាប់ពីថ្នាក់ទី៥ឡើងទៅ។[27]

**ក. ការអប់រំថ្នាក់ចំណេះដឹងទូទៅ**

បន្ទាប់ពីបញ្ចប់ការអប់រំនៅថ្នាក់បឋមសិក្សា សិស្សានុសិស្សត្រូវបន្តការសិក្សានៅថ្នាក់ចំណេះដឹងទូទៅកម្រិតទាបរឺថ្នាក់អនុវិទ្យាល័យ(មធ្យមសិក្សាបឋមភូមិ)រយៈពេល៣ឆ្នាំ។ ហើយបន្តទៅថ្នាក់ចំនេះដឹងទូទៅកម្រិតខ្ពស់រឺថ្នាក់វិទ្យាល័យ (មធ្យមសិក្សា ទុតិយភូមិ) រយៈពេល៣ឆ្នាំរឺការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតមធ្យមដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រួចបន្ទាប់ពីបានបញ្ចប់ការសិក្សានៅថ្នាក់វិទ្យា-ល័យសិស្សានុសិស្សត្រូវប្រឡងបញ្ចប់ (ថ្នាក់ជាតិ)។ លទ្ធផលសិស្សប្រឡងថ្នាក់ជាតិនៅឆ្នាំ២០១៩ អត្រាសិស្សជាប់មាន៦៨%។ ពួកគេអាចបន្តថ្នាក់ បរិញ្ញាបត្ររងសិក្សារយៈពេល២ឆ្នាំ បរិញ្ញាបត្រ សិក្សារយៈពេល៤ឆ្នាំ និងវេជ្ជសាស្ត្រ សិក្សារយៈ៧ឆ្នាំ នៅថ្នាក់ឧត្តមសិក្សា(សាកលវិទ្យាល័យ)។ យ៉ាងណាក្តី អត្រាសិស្សចូលរៀននៅ

[27] ការអប់រំនៅកម្ពុជា ( contessa-project.eu )

មានកម្រិត មានត្រឹមតែ១៣% នៃសិស្សដែលចូលរៀននៅសាកលវិទ្យាល័យ។ សិស្សទាំងអស់មានឱកាសចូលរៀនក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈឬបរិញ្ញាបត្ររង។

**ខ. យេនឌ័រ**

សមភាពយេនឌ័រក្នុងការចុះឈ្មោះត្រូវបានអនុវត្តនៅថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ។ សមាមាត្រសិស្សស្រីនៅឆ្នាំ២០០៨មានត្រឹមតែ៣៣.៨% ហើយឡើនដល់៥០%នៅក្នុងឆ្នាំ២០១៧។ ទោះជាយ៉ាងណាក៏នៅមានគំលាតគ្នារវាងជនបទ និងទីក្រុង ក្មេងស្រីជនជាតិភាគតិចភាគច្រើនជួបការលំបាកជាងក្មេងដទៃ។ ប៉ុន្តែអត្រាយេនឌ័រនៅថ្នាក់អនុវិទ្យាល័យ ក្មេងប្រុស (២៧%)តិចជាង ក្មេងស្រី(៣៣%)។[28]

**២.១.១.២. អំពីក្រសួងអប់រំ យុវជន និងកីឡា**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៦ ដោយច្បាប់។[29] ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។[30] រដ្ឋមន្រ្តីទទួលបន្ទុកក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានជ្រើសរើសដោយនាយករដ្ឋមន្រ្តី និងតែងតាំងដោយព្រះមហាក្សត្រ។ បន្ទាប់ពីទទួលបានការបោះឆ្នោតទុកចិត្តពីរដ្ឋសភា រដ្ឋមន្រ្តីត្រូវបានតែងតាំងជាមួយនឹងគណៈរដ្ឋមន្រ្តីទាំងមូល ដោយព្រះរាជក្រឹត្យ។[31]

ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មគ្រប់គ្រង និងអភិវឌ្ឍន៏វិស័យអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃប្រទេសកម្ពុជា។ រាប់បញ្ចូលទៅក្នុងសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង រួមមានការអភិវឌ្ឍធនធានមនុស្សនិងគុណភាពធនធានមនុស្សតាមរយៈគោលនយោបាយ និង ផែនការសកម្មភាពជាតិ និងការកសាងច្បាប់ និងបទបញ្ញាក្នុងវិស័យពាក់ព័ន្ធ។[32] ដើម្បីបំពេញភារកិច្ចនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានរៀងចំជាអគ្គនាយកដ្ឋានទៅតាមផ្នែកផ្សេងៗនិងគ្រឹះស្ថានឧត្តមសិក្សារដ្ឋព្រមទាំង មន្ទីរអប់រំ យុវជន និងកីឡានៅតាមបណ្តារាជធានី និងខេត្ត។[33] ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនលើផ្អែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។[34]

---

[28] ការអប់រំនៅកម្ពុជា ( contessa-project.eu )

[29] ច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករាឆ្នាំ១៩៩៦។

[30] អនុក្រឹត្យ លេខ៨៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង អប់រំ យុវជន និងកីឡា ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៩។

[31] បច្ចុប្បន្ន រដ្ឋមន្ត្រី នៃក្រសួងអប់រំ យុវជន និងកីឡា គឺ ឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុន។ ឯកឧត្តមរដ្ឋមន្ត្រី ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកម/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣។

[32] មាត្រា៩ នៃច្បាប់ស្តីពីការអប់រំ

[33] មាត្រា៦ នៃច្បាប់ស្តីពីការអប់រំ

[34] http://moeys.gov.kh/ministry/about/

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡាមានបេសកកម្ម ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឲ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក ។ វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺការអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថា យុវជននិងកុមារកម្ពុជាគ្រប់ រូបមានឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ និងកាយសម្បទា។

ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសាកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

**២.១.១.៣. ការអប់រំសាធារណៈ (ការអប់រំតាមបែបប្រពៃណី)**

ក្រសួងអប់រំ យុវជន និងកីឡា គឺជាស្ថាប័នរដ្ឋដែលមានតួនាទីទទួលបន្ទុកវិស័យអប់រំនៅកម្ពុជា។ ការអប់រំជាមូលដ្ឋានត្រូវបានចែកចេញជាពីរកម្រិតសំខាន់ គឺការអប់រំកម្រិតបឋម និងមធ្យមសិក្សា។ ការអប់រំកម្រិតបឋមសិក្សាសំដៅទៅលើឆ្នាំសិក្សា ៦ ដំបូង គឺចាប់ថ្នាក់ទី ១ ដល់ថ្នាក់ទី ៦ និងបន្ទាប់មកកម្រិតមធ្យមសិក្សា ៦ ឆ្នាំទៀត គឺចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២។[35] ការអប់រំសាធារណៈ គឺជាប្រព័ន្ធអប់រំជាតិដែលគ្រប់គ្រង និងផ្តល់ហិរញ្ញប្បទានដោយរដ្ឋ ក្នុងគោលបំណងធានានូវលទ្ធភាពទទួលបានការអប់រំសម្រាប់ប្រជាជនទាំងមូល ដោយមិនមានការរើសអើង ដោយគោលបំណងនៃការបង្កើតគម្រោងរបស់ប្រទេសជាតិតាមរយៈការបណ្ដុះបណ្ដាលដល់មនុស្សជំនាន់ក្រោយ។ កម្មវិធីសិក្សាមូលដ្ឋានត្រូវបានបែងចែកជាបីវដ្តនៃបីឆ្នាំនីមួយៗ[36]

- ❖ វដ្តទីមួយ(ថ្នាក់ទី ១-៣)មានមេរៀន ២៧-៣០ ដែលត្រូវបានបែងចែកទៅជាមុខវិជ្ជាសំខាន់ៗចំនួនប្រាំ៖
- ➢ ភាសាខ្មែរ (១៣មេរៀន)
- ➢ គណិតវិទ្យា (៧មេរៀន)
- ➢ វិទ្យាសាស្ត្រ និងការសិក្សាសង្គម រួមទាំងសិល្បៈ (៣ មេរៀន)
- ➢ ការអប់រំកាយ និងសុខភាព (២មេរៀន)

[35] https://opendevelopmentcambodia.net/km/topics/primary-and-secondary-education/#ref-149738-5
[36] https://www.bookbridge.org/post/the-education-system-in-cambodia

- កម្មវិធីបំណិនជីវិតក្នុងស្រុក (២-៥មេរៀន)

❖ វដ្តទីពីរ (ថ្នាក់ទី ៤-៦) រួមមានចំនួនមេរៀនដូចគ្នា ប៉ុន្តែខុសគ្នាបន្តិចបន្តួច៖

- ភាសាខ្មែរ (១០ សម្រាប់ថ្នាក់ទី ៤ និងទី ៨ សម្រាប់ថ្នាក់ទី ៥-៦)
- គណិតវិទ្យា (៦ សម្រាប់ថ្នាក់ទី ៤-៦)
- វិទ្យាសាស្ត្រ (៣ សម្រាប់ថ្នាក់ទី ៤ និងទី ៤ សម្រាប់ថ្នាក់ទី ៥-៦)
- ការសិក្សាសង្គមរួមទាំងសិល្បៈ (៤ សម្រាប់ថ្នាក់ទី ៤ និងទី ៥ សម្រាប់ថ្នាក់ទី ៥-៦)
- ការអប់រំរាងកាយ និងសុខភាព (២ សម្រាប់ថ្នាក់ទី ៤-៦)
- កម្មវិធីបំណិនជីវិតក្នុងស្រុក (២-៥ សម្រាប់ថ្នាក់ទី ៤-៦) ។

❖ វដ្តទីបី (ថ្នាក់ទី ៧-៩) មានមេរៀន ៣២-៣៥ ដែលត្រូវបានបែងចែកសម្រាប់ ៦ មុខវិជ្ជាសំខាន់ៗ៖

- ភាសាខ្មែរ
- គណិតវិទ្យា
- ការសិក្សាសង្គម និងវិទ្យាសាស្ត្រ (៦មេរៀន)
- ភាសាបរទេស (៤ មេរៀន)
- អប់រំកាយ និងសុខភាព និងកីឡា (២មេរៀន)
- កម្មវិធីបំណិនជីវិតក្នុងស្រុក (២-៥មេរៀន)

សាលារៀនជាកន្លែងហ្វឹកហ្វឺន និងជាកន្លែងអប់រំមនុស្ស ធ្វើយ៉ាងណាឱ្យមនុស្សក្លាយជាមនុស្សល្អពេញលក្ខណៈ មានទាំងសមត្ថភាពនិងគុណធម៌។ នៅពេលអ្នកចូលមកកាន់សាលារៀន សិស្សានុសិស្សតែទទួលយកការហ្វឹកហ្វឺន និងការបណ្តុះបណ្តាលជាចាំបាច់ បើមិនក្រៅពីការសិក្សាចំណេះជំនាញ សាលាចាំបាច់ត្រូវមានបទបញ្ជាដែលជាច្បាប់សម្រាប់ឱ្យសិស្សអនុវត្តន៍។ ដូចជាតម្រូវឱ្យសិស្សានុសិស្សស្លៀកសម្លៀកបំពាក់ឱ្យមានភាពសមរម្យ មានក្រមសីលធម៌សុជីវធម៌ មានអនាម័យល្អ និងត្រូវគោរពពេលវេលានៃការសិក្សា។ ការសិក្សាដោយផ្ទាល់នៅសាលា គឺសិស្សមានឱកាសក្នុងការសិក្សា ស្រាវជ្រាវ អនុវត្តកិច្ចការរបស់ខ្លួនដោយផ្ទាល់ជាមួយមិត្តរួមក្រុម និងលោកគ្រូ អ្នកគ្រូត្រួតពិនិត្យដោយផ្ទាល់នៅសាលា។ ការសិក្សាដោយផ្ទាល់នៅសាលានេះជាកន្លែងដែលបណ្តុះបណ្តាល អប់រំ និងហ្វឹកហ្វឺន ដើម្បីកែទម្លាប់របស់សិស្ស ព្រមសិក្សាក្រេបយកនូវចំណេះដឹង និងហាត់ពត់កាយវាចាចិត្ត ធ្វើយ៉ាងណាឱ្យខ្លួនមានការចេះដឹងបានស្ទាត់ជំនាញ និងមានឥរិយាបថល្អអាចរស់នៅចុះសម្រុងក្នុងសង្គម។ ការអប់រំបែបប្រពៃណីនេះត្រូវបានផ្លាស់ប្តូរជាបណ្តើរៗនៅពេលប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមបារាំង (១៨៦៣-១៩៥៣)។[37]

[37] ប្រព័ន្ធអប់រំនៅកម្ពុជា | https://www.bookbridge.org/post/the-education-system-in-cambodia

**ក. អំពីគោលនយោបាយនៃសាលារៀនជំនាន់ថ្មី**

ខណៈពេលដែលព្រះរាជាណាចក្រកម្ពុជាបានឈានចូលក្នុងសតវត្សន៍ទី២១ ប្រព័ន្ធអប់រំនៅមានបញ្ហាប្រឈមជាច្រើន ដោយមានការកើតឡើងនៃការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការជ្រៀតចូលយ៉ាងឆាប់រហ័សនូវប្រព័ន្ធបច្ចេកវិទ្យានៅក្នុងសង្គមកម្ពុជា ការកើនឡើងផ្នែកនគូបនីយកម្ម ការពង្រីកសាលាឯកជន និងចំនួនពលរដ្ឋជាយុវជនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលតម្រូវឱ្យមានសេចក្តីណែនាំទូលំទូលាយអំពីជម្រើស និងគំនិតប្រកួតប្រជែងនៅក្នុងសង្គមបច្ចុប្បន្ន។ ក្រសួងបានផ្តល់អាទិភាពខ្ពស់ ក្នុងការកែលំអរគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដោយតាមរយៈអនុវត្តសាលារៀនជំនាន់ថ្មី ដើម្បីធ្វើការឆ្លើយតបនឹងបញ្ហាប្រឈមខាងលើព្រមទាំងជួយលើកកម្ពស់ធនធានមនុស្សប្រកបដោយនិរន្តភាព។

ការបង្កើតសាលារៀនជំនាន់ថ្មី គឺជាគោលនយោបាយផ្លូវការមួយរបស់ក្រសួងអប់រំ យុវជន និងកីឡាអនុលោមតាមក្របខ័ណ្ឌកំណែទម្រង់វិស័យអប់រំ ដែលបានប្រកាសឱ្យប្រើដោយក្រសួងក្នុងឆ្នាំ ២០១៣ នៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិស័យអប់រំ។ គោលនយោបាយនេះត្រូវបានរៀបចំឡើង ស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជា-ណាចក្រកម្ពុជា ច្បាប់ស្តីពី ការអប់រំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចក្ខុវិស័យនៃសាលារៀនជំនាន់ថ្មី គឺនឹងនាំមកនូវក្របខណ្ឌរដ្ឋបាលថ្មីដែលអាចធានាលក្ខខណ្ឌចាំបាច់ជាសារវន្ត និងមានប្រសិទ្ធភាពក្នុងការធ្វើវិនិយោគប្រព័ន្ធអប់រំដោយជោគជ័យ រួមទាំងព្យាយាមបង្កើតគំរូអភិវឌ្ឍន៍ថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈ ដែលនឹងនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វ័យតដែលទទួលបានការវិនិយោគខ្ពស់ផ្សាភ្ជាប់នឹងស្តង់ដាថ្មីមានគណនេយ្យភាព និងអភិបាលកិច្ចល្អព្រមទាំងស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សទី២១។ [38]

ដើម្បីពង្រឹងការអភិវឌ្ឍក្នុងការអនុវត្តសាលារៀនជំនាន់ថ្មី គឺតម្រូវឱ្យដាក់ការអនុវត្តប្រភេទមុខវិជ្ជាបន្ថែមជាពិសេសផ្តើតលើមុខវិជ្ជា STEM ភាសាបរទេស ឬផ្នែកផ្សេងទៀតតាមតម្រូវការរបស់សហគមន៍ក្នុងមូលដ្ឋាន។ លើសពីនេះ គឺមានការបង្កើតម៉ោងបង្រៀនដល់ ៣៤ ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅកម្រិតបឋមសិក្សា និង៤០ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ សម្រាប់មធ្យមសិក្សា។

**២.១.១.៤ ការអប់រំឯកជន (ការអប់រំតាមបែបប្រពៃណី)**

ចំពោះផ្នែកមួយនៃប្រជាជនទីក្រុងនៅកម្ពុជា ការអប់រំឯកជនមានសារៈសំខាន់ក្នុងប៉ុន្មានឆ្នាំមុនពេលដែលកុម្មុយនិស្តកាន់កាប់។ សាលារៀនឯកជនមួយចំនួនត្រូវបានដំណើរការដោយជនជាតិភាគតិចដូចជាជនជាតិចិន វៀតណាម អឺរ៉ុបរ៉ូម៉ាំង និងមូស្លីម ដូច្នេះកុមារអាចរៀនភាសារបស់ពួកគេវប្បធម៌ឬសាសនា។ ប្រព័ន្ធអប់រំឯកជនមានសាលារៀនភាសាចិន សាលារៀនភាសាវៀតណាម (ជារឿយរ៉ូម៉ាំងកាតូលិក) សាលាភាសា

[38] គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី

បារាំង សាលារៀនភាសាអង់គ្លេស និងសាលារៀនភាសាខ្មែរ។[39] ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាឯកជនបានកើនឡើង ហើយការអប់រំមធ្យមសិក្សាឯកជនត្រូវបានតំណាងដោយវិទ្យាល័យមួយចំនួនផងដែរ។ កម្ពុជាបានសម្រេចចិត្តឱ្យវិស័យឯកជនចូលរួមវិនិយោគលើវិស័យអប់រំ ដែលបានបើកឱកាសឱ្យមានការចូលរួមតាំងពីឆ្នាំ១៩៨៩ ឬឆ្នាំ១៩៩០ គឺមុនកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩៣នោះទៅទៀត។ ការផ្តល់ឱកាសឱ្យវិស័យឯកជនចូលរួមវិនិយោគក្នុងវិស័យអប់រំ គឺជាការរីកចម្រើនយ៉ាងឆាប់រហ័សដែលកំពុងផ្លាស់ប្តូរទិដ្ឋភាពអប់រំរបស់កម្ពុជា និងនាំមកនូវឱកាសសិក្សាកាន់តែច្រើនសម្រាប់យុវជនជំនាន់ក្រោយ។ វិស័យអប់រំឯកជននៅកម្ពុជានាពេលបច្ចុប្បន្ន គឺការកើនឡើង និងរីកចម្រើនខ្លាំងទាំងបរិមាណ និងគុណភាព សម្រាប់រួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីកសាង និងអភិវឌ្ឍន៍សង្គមជាតិទាំងមូល។[40]

ការចូលរៀននៅសាលាឯកជនដែលភាគច្រើនបើកដំណើរការដោយក្រុមហ៊ុនបរទេស កំពុងចាប់ផ្តើមបង្កើនគុណភាពវិស័យអប់រំ និងបំពេញគម្លាតផ្គត់ផ្គង់នៅក្នុងប្រព័ន្ធអប់រំផងដែរ។ សាលាឯកជនភាគច្រើនមានបំពាក់ដោយសម្ភារទំនើប បន្ទប់រៀនស្អាតមានហេដ្ឋារចនាសម្ព័ន្ធល្អគ្រូមានសមត្ថភាពខ្ពស់ដែលអាចបង្រៀននូវកម្មវិធីសិក្សាដែលមានតម្រូវការខ្ពស់នៅលើទីផ្សារ ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងការចង់បានពីអ្នកដែលមានលទ្ធភាពផងដែរ។ យោងតាមរបាយការណ៍ស្ថិតិ និងសូចនាករអប់រំឯកជនរបស់ក្រសួងអប់រំយុវជន និងកីឡា (ឆ្នាំសិក្សា ២០១៨-២០១៩) បានបង្ហាញថាសិស្សសរុបចំនួន ២១៨,៣៥៧ នាក់ បានចុះឈ្មោះចូលរៀននៅសាលាឯកជនចំនួន ១២២២ សាលា នៅទូទាំងប្រទេសចាប់ពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់វិទ្យាល័យ។ សាលារៀនឯកជនបានកើនឡើងយ៉ាងខ្លាំង រួមទាំងប្រភេទនៃកម្មវិធីសិក្សាក៏កើនឡើងយ៉ាងច្រើនផងដែរ ដូចនេះឪពុកម្តាយអាចជ្រើសរើសដាក់កូនរបស់គេតាមប្រព័ន្ធអប់រំណាមួយក៏បាន ដែលជាជំហានផ្លាស់ប្តូរជាវិជ្ជមានមួយសម្រាប់ឱ្យស៊ាំខ្លួនកូនសិស្សទៅនឹងការសិក្សារបៀបនៅបរទេស។ កម្មវិធីសិក្សាដែលមានប្រជាប្រិយភាពមានដូចជា កម្មវិធីសិក្សារបៀបអាមេរិក ចក្រភពអង់គ្លេស កាណាដា អូស្ត្រាលី សិង្ហបុរី និងចិន។ កម្មវិធីនៃការសិក្សារបស់សាលារៀនឯកជន គឺត្រូវបានអនុវត្តដោយកម្មវិធីស្តង់ដារបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយភាគច្រើននៃសាលារៀនឯកជនត្រូវបានផ្តល់ជូននូវសកម្មភាពក្រៅម៉ោងជាច្រើន ដូចជាសិល្បៈទស្សនីយភាព និងសម្តែងក្លឹបគ្រប់ប្រភេទក្រុមការងារ និងសេវាកម្មសហគមន៍គឺជាសកម្មភាពមួយចំនួនដែលអ្នកអាចរកបាននៅសាលាឯកជន។ កម្មវិធីសិក្សារបស់យើងអាចជួយឱ្យសិស្សអភិវឌ្ឍន៍ខ្លួន និងផ្តត់គំនិតជាលក្ខណៈអន្តរជាតិ ហើយពួកគេបានបំពាក់ក្នុងខ្លួនគេនូវចំណេះដឹង និងបទពិសោធដើម្បីបានត្រៀមខ្លួនប្រែក្លាយជាប្រជាជននៃសម័យសកលភាវូនីយកម្មរួចជាស្រេច។[41] សកម្មភាពក្រៅម៉ោងបន្ថែមបំពេញបន្ថែមការបង្រៀនផ្នែកសិក្សាអប់រំ

[39] វិស័យអប់រំនៅកម្ពុជា https://km.wikipedia.org

[40] វិស័យអប់រំឯកជនមានការរីកចម្រើនទាំងបរិមាណ និងគុណភាពគួរឱ្យកត់សម្គាល់ https://www.khmertimeskh.com

[41] សាលាអន្តរជាតិឯកជន ជួយពង្រឹងការអប់រំប្រកបដោយគុណភាព https://www.postkhmer.com

ដែលនេះជាមូលហេតុដែលសាលាសង្កត់ធ្ងន់លើសិស្សានុសិស្ស ក្នុងនោះរួមមានកម្មវិធីកីឡារួមបញ្ចូលគ្នាជាមួយការងារសិក្សា និងសកម្មភាពក្រៅប្រព័ន្ធដើម្បីអភិវឌ្ឍកុមារទាំងមូល។ សាលារៀនឯកជនភាគច្រើនតម្រូវឱ្យសិស្សរបស់ពួកគេចូលរួមក្នុងកីឡាមួយចំនួន ហើយគ្រូបង្រៀនក៏ត្រូវបានគេតម្រូវឱ្យចូលរួមក្នុងការបង្វឹកកីឡាផងដែរ។[42]

### ២.១.២ ការអប់រំក្នុងបរិបទជំងឺកូវីដ-១៩

ជំងឺកូវីដ-១៩ បានជះឥទ្ធិពលជាអវិជ្ជមានយ៉ាងខ្លាំងលើប្រព័ន្ធអប់រំនៅទូទាំងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ចាប់តាំងពីការប្រកាសដាក់ឱ្យអនុវត្តវិស្សមកកាលមុនកាលកំណត់ និងការពន្យារពេលបើកដំណើរការសាលារៀនធម្មតាឡើងវិញ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយភាគីពាក់ព័ន្ធបានខិតខំលើកកម្ពស់ការអប់រំពីចម្ងាយដើម្បីឱ្យកុមារ និងសិស្សានុសិស្សអានបន្តការសិក្សារបស់ពួកគេប្រកបដោយសុវត្ថិភាពពីផ្ទះ។ ក្នុងដំណើរការអប់រំនៃបរិបទជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់នូវវិធានការយ៉ាងល្អិតល្អន់ដោយបើកជាជំហានៗនឹងបើកពេញលេញគ្រប់កម្រិតសិក្សានៅទូទាំងប្រទេស អាស្រ័យលើការពិគ្រោះយោបល់វាយតម្លៃពីស្ថានភាពរាតត្បាតជំងឺកូវីដ-១៩ ជាមួយក្រសួងសុខាភិបាល ព្រមទាំងទទួលបានការឯកភាពពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា។[43] សម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំដោយឱ្យអនុវត្តន៍តាមគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) ពោលគឺការរស់នៅសិក្សារៀនសូត្រធម្មតាតាមបែបគន្លងថ្មីឱ្យបានខ្ជាប់ខ្ជួនតាមការណែនាំរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោកដើម្បីធ្វើការធានាបាននូវសុវត្ថិភាពដល់អ្នកសិក្សា និងបុគ្គលិកអប់រំ។

#### ២.១.២.១. ជំងឺកូវីដ ១៩ និងប្រព័ន្ធអប់រំកម្ពុជា

ជំងឺកូវីដ-១៩ ជាជំងឺឆ្លងថ្មីមួយដែលរាតត្បាតជាសាកល ជាជំងឺឆ្លងផ្លូវដង្ហើមដែលប៉ះពាល់សួតធ្ងន់ធ្ងរបង្កឡើងដោយវីរុសក្លូរ៉ូណា (Coronavirus)។ វីរុសក្លូរ៉ូណា ជាក្រុមគ្រួសារនៃវីរុសដ៏ធំមួយដែលបណ្តាលឱ្យមានជំងឺផ្តាសាយធម្មតា និងជំងឺសួតធ្ងន់ធរជាច្រើនទៀតដូចជា ជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (Middle East Respiratory Syndrome = MRS) និងជំងឺសា (Server Actute Respiratory Syndrome= SARS) ជា ដើម។ ជំងឺកូវីដ-១៩ ត្រូវបានឃើញដំបូងនៅទីក្រុងវូហាន (Wuhan) ខេត្តហ៊ុយបេ (Hubei) នៃសាធារណៈរដ្ឋប្រជាមានិតចិន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ហើយកម្ពុជាបានរកឃើញករណីដំបូងនៃជំងឺកូវីដ-១៩ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ អង្គការសុខភាពពិភពលោក (WHO) បានដាក់ឈ្មោះជំងឺបណ្តាលមកពីវីរុសក្លូរ៉ូណាប្រភេទថ្មី (2019-nCoV) ជាផ្លូវការថា ជំងឺ (COVID-19) ដែលមកពីពាក្យកាត់ “CO” តំណាងឱ្យពាក្យ Corona (ក្លូរ៉ូណា) “VI” តំណាងឱ្យពាក្យ Virus (វីរុស) “D” តំណាងឱ្យពាក្យ Disease

[42] https://km.eferrit.com/10

[43] សៀវភៅដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩

(ជំងឺ) និងលេខ១៩ តំណាងឱ្យឆ្នាំ២០១៩ ហើយបានកំណត់ថាជំងឺរាតត្បាតសាកល (Global Pandemic) ចាប់ពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។ ក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសផ្អាកដំណើរការគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនគ្រប់កម្រិតនៅទូទាំងប្រទេស ខណៈក្រសួងការងារផ្អាកគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីបង្ការកុំឱ្យការចម្លងកូវីដ-១៩ កាន់តែមានទ្រង់ទ្រាយធំ ស្របពេលដែលឥទ្ធិពលនៃព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» កំពុងបន្តរីករាលដាលនៅកម្ពុជា ព្រមទាំងចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងផ្ទុះឡើងក្នុងសហគមន៍គួរឱ្យបារម្ភ។ ដើម្បីធានាពីលទ្ធភាពដែលសិស្សានុសិស្ស និងកុមារអាចមានការរៀនសូត្រជាបន្ត និងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងទប់ស្កាត់ និងបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងការងារបានណែនាំឱ្យគ្រប់គ្រឹះស្ថានទាំងអស់ដំណើរការបណ្ដុះបណ្ដាលតាមប្រព័ន្ធបណ្ដុះបណ្ដាលពីចម្ងាយ ឬតាមអនឡាញ។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្វែរបញ្ហាប្រឈមដោយសារកូវីដ-១៩ ឱ្យបានក្លាយជាឱកាសក្នុងការពង្រឹងការអប់រំបែបឌីជីថលដែលស្ថិតក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០៣០។[44]

ក្នុងការបង្កាការឆ្លងរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តបិទសាលារៀនគ្រប់ប្រភេទ និងគ្របកម្រិតសិក្សាទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ស្ថានភាពនេះបានជះឥទ្ធិ-ពលយ៉ាងខ្លាំងទៅដល់សុខុមាលភាពរបស់កុមារ ព្រមទាំងការសម្រេចបាននូវសិទ្ធិរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការសិក្សាស្រាវជ្រាវ កុមារដែលមានអាយុចាប់ពី ១០-១៧ ឆ្នាំបានបង្ហាញថា ៧៨% នៃកុមារនិងយុវជនដែលត្រូវបានសម្ភាសន៍ បានរាយការណ៍ថាពួកគេបាននិងកំពុងបន្តការសិក្សាខ្លះៗដែលចំនួនពាក់កណ្ដាលនៃកុមារទាំងនោះបានសិក្សាតិចជាង ១០ ម៉ោងក្នុងមួយសប្ដាហ៍នៅផ្ទះ បើប្រៀបធៀបទៅនឹង ២០ ម៉ោងក្នុងមួយសប្ដាហ៍ពេលរៀនធម្មតានៅសាលា។[45] ក្នុងអំឡុងវិស័យនៅកម្ពុជា បានទទួលរងការយីយាពីជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡាបានរិះរកគ្រប់មធ្យោបាយ ដើម្បីកុំឲ្យការអប់រំនៅប្រទេសកម្ពុជាមានការជាប់គាំង ហើយបច្ចេកវិទ្យាគឺជាជម្រើសអាទិភាពមួយដែលក្រសួងអប់រំបានប្រើប្រាស់ ដើម្បីធ្វើឱ្យការអប់រំបន្តដំណើរការ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហារាតត្បាតនៃជំងឺកូវីដ-១៩ រដ្ឋមន្ត្រីក្រសួងអប់រំ លោកបណ្ឌិត ហង់ជួន ណារ៉ុនបានចែករំលែកនូវផែនការយុទ្ធសាស្ត្រមួយចំនួន ដែលកម្ពុជាបានដាក់ចេញ ដើម្បីពង្រឹងប្រព័ន្ធអប់រំជាតិ។ កម្ពុជាបានខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ ដោយងាកទៅរកវិធីសាស្ត្រសិក្សាចម្រុះ ហើយក៏បានយកចិត្តទុកដាក់លើការកែទម្រង់កម្មវិធីសិក្សាជាតិ និងសម្ភារៈអប់រំផ្សេងៗទៀត ដើម្បីលើកកម្ពស់គុណភាព

[44] https://www.postkhmer.com (ក្រសួងអប់រំផ្អាកដំណើរការគ្រឹះស្ថានសិក្សារដ្ឋ-និងឯកជនគ្រប់កម្រិតនៅទូទាំងប្រទេស)

[45] ការស្ទង់មតិធ្វើឡើងដោយសម្ព័ន្ធ Joining Forces និងអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា

ក្នុងអំឡុងការរីករាលដាលនៃជំងឺកូវីដ-១៩។[46] បច្ចេកវិទ្យា បានផ្តល់គុណសម្បត្តិជាច្រើនដល់វិស័យអប់រំនៅកម្ពុជា ក្នុងអំឡុងពេលដែលកម្ពុជាបានជួបការលំបាលដោយសារជំងឺកូវីដ-១៩ ដោយសារបច្ចេកវិទ្យា វិស័យអប់រំកម្ពុជាមានការវិវត្តទៅមុខដើរលឿន១០ឆ្នាំ មុនពេលកំណត់។[47] ការអប់រំនៅកម្ពុជាគឺបានស្ថិតនៅក្នុងបរិបទថ្មីដែលហៅថាការទទួលបានការអប់រំគ្រប់រូបភាព ឬការទទួលបានការអប់រំបែបចម្រុះ ដោយសារក្នុងអំឡុង២ឆ្នាំនេះ សិស្សានុសិស្ស និងនិស្សិតទទួលបានការអប់រំពីចម្ងាយផង (តាមអនឡាញ) ទទួលបានការសិក្សាក្នុងថ្នាក់ផង និងស្វ័យសិក្សាផង។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមគំនិតហើយមានការគាំទ្រដោយអង្គការយូនីសេហ្វ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាធនធានឌីជីថលដើម្បីធ្វើទំនើបកម្ម កែលម្អការបង្រៀន និងលើកកម្ពស់ការអប់រំសម្រាប់សិស្សានុសិស្សនៅក្នុងប្រទេស ហើយខណៈពេលដែលគំនិតផ្តួចផ្តើមនៃការសិក្សាតាមប្រព័ន្ធអនឡាញក្នុងអំឡុងពេលបិទសាលាដោយសារជំងឺកូវីដ-១៩ បានធ្វើឱ្យគ្រូបង្រៀន និងសិស្សនៅទូទាំងប្រទេសអាចរៀនតាមអ៊ីនធឺណិត។[48] ការសិក្សាពីចម្ងាយអំឡុងពេលដែលសាលារៀនត្រូវបិទទ្វារ គឺត្រូវបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនានានៅតាមផ្ទះ ដើម្បីសម្រួលដល់កុមារក្នុងការទទួលបានការអប់រំនៃបរិបទកូវីដ-១៩ ដែលមានដូចជា៖ កម្មវិធី Telegram, ZOOM , Google Classroom, Team Microsoft, និង WhatsApp ផងដែរ។[49] តាមរយៈការសិក្សាពីចម្ងាយនេះ កុមារបានប្រើប្រាស់ ទូរស័ព្ទឆ្លាត កុំព្យូទ័រ ថាបលែត វិទ្យុ ទូទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គមនានា ហើយក្នុងនោះមានវិធីសាស្ត្រសិក្សាពីចម្ងាយចំនួន ៤ សំខាន់ៗជាងគេដែលកុមារប្រើប្រាស់៖

- ❖ ក្រដាសកិច្ចការ និងឯកសារសិក្សាជាក្រដាសដទៃទៀត ។
- ❖ វីដេអូសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចដែលផ្តល់ដោយមិនគិតថ្លៃតាមប្រព័ន្ធអនឡាញ តាមរយៈបណ្តាលទំនាក់ទំនងសង្គមរបស់ក្រសួងអប់រំ យុវជន និងកីឡា និងថ្នាលបច្ចេកវិទ្យាដទៃទៀត។
- ❖ ម៉ូឌុលសិក្សាតាមប្រព័ន្ធអនឡាញដែលរៀបចំដោយសាលារៀន ដែលពួកគេទៅរៀន។
- ❖ ការផ្សព្វផ្សាយពីកម្មវិធីអប់រំតាមទូរទស្សន៍ជាតិ។[50]

### ២.១.២.២ ផលប៉ះពាល់ចម្រុះនៃជំងឺកូវីដ-១៩ មកលើប្រព័ន្ធអប់រំ

នាពេលដែលកម្ពុជាស្ថិតក្នុងស្ថានភាពដ៏ស្វិតស្វាញនៃជំងឺកូវីដ-១៩ នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបិទគ្រឹះស្ថានអប់រំទាំងអស់ ទាំងគ្រឹះស្ថានសាធារណៈ និងឯកជន ដើម្បីជាវិធានការការពារការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។ការបិទសាលារៀនទាំងនេះបង្កការរំខានដល់ការសិក្សានៅក្នុងសាលារៀនប្រមាណ

[46] រដ្ឋមន្ត្រីក្រសួងអប់រំ ប្តេជ្ញាកាត់បន្ថយជំងឺកូវីដ-១៩ ក្នុងប្រព័ន្ធអប់រំ - Khmer Times (khmertimeskh.com)
[47] ប្រសាសន៍លោកបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១
[48] https://thmeythmey.com/?page=detail&id=114716
[49] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី១១
[50] ឯកសារអប់រំមូលដ្ឋាននៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

១៣៤៨២ កន្លែងទូទាំងប្រទេសកម្ពុជា ដោយគិតចាប់ពីសាលាមត្តេយ្យសិក្សា ឬ រហូតដល់វិទ្យាល័យ ហើយក្នុងនោះមានសិស្សប្រមាណ ៣,២ លាននាក់ ត្រូវបានរងផលប៉ះពាល់។[51] តាមរយៈការផ្លាស់ប្តូរស្ថានភាពការងាររបស់កុមារ និងមានការប្រឈមនឹងការបោះបង់ចោលការសិក្សា៖

- កុមារត្រូវតែជួយការងារក្នុងផ្ទះបន្ថែមទៀត ដែលមានរហូតទៅដល់ ៦១%
- សិស្ស ១៦% បានបោះបង់ចោលការសិក្សារួចទៅហើយ ឬប្រឈមនឹងការបោះបង់ចោលការសិក្សា
- កុមារជាង ៦% ត្រូវធ្វើការពេញម៉ោង
- មានកុមារជាង ៤% ធ្វើការក្រៅម៉ោងចាប់តាំងពីសាលារៀនត្រូវបានបិទទ្វារ
- កុមារា និងកុមារី ២០% បានរាយការណ៍ថាពួកគេទទួលរងឬប្រឈមនឹងអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ច ដោយសារការបិទទ្វារសាលារៀន
- មានសិស្សជាង ៥៥% ទទួលរងបញ្ហាសុខភាពផ្លូវចិត្ត ឬបញ្ហាចិត្តសង្គម ដែលបានបង្កភាពតានតឹងដល់ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសាកល។[52]

**ក. លទ្ធភាពរបស់សិស្សក្នុងការទទួលបានស្បៀង និងអាហាររូបត្ថម្ភ**

ផលប៉ះពាល់នៃការអូសបន្លាយពេលបិទសាលារៀនលើស្ថានភាពស្បៀង និងអាហាររូបត្ថម្ភរបស់កុមារបានក្លាយជាផលវិបាកគួរឱ្យព្រួយបារម្ភនៃផលប៉ះពាល់ចម្រុះ ដែលបង្កឡើងដោយសារការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩។ កុមារជាច្រើននាក់នៅទូទាំងសកលលោក ជាពិសេសកុមារដែលងាយរងគ្រោះជាងគេ គឺជាក្រុមដែលទទួលបានប្រយោជន៍ពីកម្មវិធីផ្តល់អាហារនៅតាមសាលារៀន។ ជាការសំខាន់ណាស់ដែលគេត្រូវយល់ពីបម្រែបម្រួលនៃការទទួលបានស្បៀង និងអាហារូបត្ថម្ភរបស់កុមារ ក្នុងអំឡុងពេលដែលសាលារៀនបិទទ្វារ។ តាមរយៈការវាយតម្លៃនេះ យើងបានកត់សម្គាល់ឃើញថាមានការថយចុះនូវកម្រិតនៃការទទួលបានស្បៀង ក្នុងអំឡុងពេលដែលសាលារៀនបិទទ្វារក្នុងគ្រប់គ្រួសារទាំងអស់។ ហើយគ្រួសារដែលមានកូនរៀននៅកម្រិតអប់រំទាប ដូចជា មត្តេយ្យសិក្សា (៥១%) និងបឋមសិក្សា (៤៧%) ក៏ដូចជាគ្រួសារដែលមានកូនចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ (៤៦%)។ [53]

**ខ. ការប្រឈមនឹងអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ច បញ្ហាសុខភាពផ្លូវចិត្ត និងបញ្ហាសង្គមដោយសារជំងឺកូវីដ-១៩ និងការបិទទ្វារសាលារៀន**

តាមរយៈការសិក្សាស្រាវជ្រាវរកឃើញថា កុមារី និងកុមារា កាន់តែប្រឈមហានិភ័យក្នុងអំឡុងពេលបិទទ្វារសាលារៀន ដោយសារតែពួកគេក្នុងភាគរយមួយឱ្យកត់សម្គាល់ ដោយកុមារផ្ទាល់បានទទួលរង

[51] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី១៥
[52] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី១៤
[53] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី១៦

អំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចរឹតតែច្រើនជាងមុន។ កម្រិតនៃការកើនឡើងនូវការប្រឈមនឹងអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច តាមការលើកឡើងរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំដែលយល់ឃើញថា ហានិភ័យមានការកើនឡើង។ ក្រៅតែពីការកើនឡើងនូវការប្រឈមនឹងអំពើហិង្សា ក៏មានការរកឃើញផងដែរថាសិស្សមានបញ្ហាសុខភាពផ្លូវចិត្ត និងបញ្ហាចិត្តសង្គមច្រើនជាងមុនក្នុងអំឡុងជំងឺកូវីដ-១៩ ដោយពួកគេជាងពាក់កណ្តាលបានលើកឡើងថា បានជួបនឹងកត្តាដែលបង្កឱ្យមានភាពតានតឹងមកលើសុខភាពផ្លូវចិត្ត និងស្ថានភាពចិត្តសង្គមរបស់ពួកគេ យ៉ាងហោចណាស់មួយប្រភេទក្នុងអំឡុងរយៈពេលនៃការរាតត្បាតជាសាកលនេះគឺដូចជា ភាពសោកសៅ ភាពកណ្តោចកណ្តែង និងការភ័យខ្លាចជាដើម។

**គ. ផលប៉ះពាល់សេដ្ឋកិច្ចដែលបង្កឡើងដោយសារជំងឺកូវីដ-១៩**

ជំងឺរាតត្បាតជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោក ហើយការកើនឡើងនៃវិបត្តិនេះបានប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍មិនត្រឹមតែទៅលើភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លាញដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដល់ប្រទេសទាំងនោះយ៉ាងធ្ងន់ធ្ងរផងដែរ។[54] ដូចគ្នានេះដែលបណ្តាប្រទេសសមាជិកអាស៊ានទាំងអស់បានរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមពីជំងឺកូវីដ-១៩។ ខណៈការផ្ទុះឡើងនៃជំងឺនេះជាសាកល បាននាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរនៃការធ្វើដំណើរ ពាណិជ្ជកម្ម និងការវិនិយោគ ដែលជាហេតុបាននាំមកនូវការរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសអាស៊ាន ហើយក្នុងនោះរួមទាំងប្រទេសកម្ពុជាផងដែរ។[55] ជំងឺកូវីដ-១៩ បានគម្រាមកំហែងយ៉ាងខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ចទៅលើវិស័យផ្សេងៗនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ខណៈដែលវិស័យទេសចរណ៍ផលិតកម្មសម្រាប់ការនាំចេញនិងវិស័យសំណង់ត្រូវបានគេមើលឃើញថាជាវិស័យដែលបានរងផលប៉ះពាល់ខ្លាំងបំផុត។ យោងតាមអង្គការសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) វិបត្តិសេដ្ឋកិច្ចនេះនឹងបន្តឱ្យមានផលប៉ះពាល់រយៈពេលមធ្យមលើភាពក្រីក្រ និងសុខុមាលភាព ជាពិសេសក្នុងចំណោមជនងាយរងគ្រោះនៅក្នុងសង្គម និងអ្នកដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ដូចដែលត្រូវបានលើកឡើងនៅក្នុងអត្ថបទសង្ខេបគោលនយោបាយរបស់អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) បានបង្ហាញថាជំងឺរាតត្បាតកូវីដ-១៩នឹងធ្វើឱ្យក្រុមជនងាយរងគ្រោះជាក់លាក់មួយចំនួន រួមមានស្ត្រី កុមារ ជនជាតិដើមភាគតិច និងពលករចំណាកស្រុករងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ ដោយសារតែភាពអត់ការងារធ្វើ និងកង្វះការងារសម្រាប់អ្នកប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ កុមារនៅកម្ពុជាក៏ទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយសារតែផលប៉ះពាល់សេដ្ឋកិច្ច ដែល

[54] កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(UNDP)

[55] អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OEDC) នៃការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ក្នុងរដ្ឋសមាជិកអាស៊ាន

បង្កឡើងដោយសារជំងឺកូវីដ-១៩ ផងដែរ។ ខណៈពេលដែលកុមារត្រូវធ្វើការពេញម៉ោង ហើយខ្លះទៀតត្រូវធ្វើការក្រៅម៉ោងដើម្បីជួយរកប្រាក់មកផ្គត់ផ្គង់គ្រួសារ ឬបានរួមចំណែកធ្វើការងារផ្ទះច្រើនជាងមុនជាដើមដែលនេះជាមូលហេតុកុមារបានប្រឈមនឹងការបោះបង់ចោលការសិក្សា។[56]

កុមារជាច្រើននាក់មកពីគ្រួសារទីទល់ក្រទាំង បានយកពេលដែលពួកគេទទួលបានពីការបិទទ្វារសាលារៀនទៅធ្វើការ ដើម្បីរួមចំណែករកប្រាក់ចំណូលឱ្យគ្រួសារ។ នេះអាចបង្កផលប៉ះពាល់ដល់លទ្ធភាពទទួលបានការអប់រំរបស់ពួកគេ ព្រោះថាពួកគេអាចមិនត្រឡប់ទៅសាលារៀនវិញ។ គួរផ្សំនឹងការត្រូវធ្វើកិច្ចការផ្ទះបន្ថែមទៀតផងនោះ ទាំងនេះអាចជាបញ្ហាប្រឈមដែលកុមារបានខាតបង់ក្នុងការសិក្សាពីចម្ងាយ។

### ២.១.២.៣ បញ្ហាដែលកុមារជួបប្រទះក្នុងការសិក្សាពីចម្ងាយ

ទន្ទឹមនឹងភាពរីកចម្រើននៃបច្ចេកវិទ្យាក្នុងការសិក្សាពីចម្ងាយនេះដែរ យើងឃើញមានការស្រាវជ្រាវមួយចំនួនបានបង្ហាញពីឧបសគ្គចំពោះការសិក្សាចំនួន ៤ ដែលត្រូវបានកុមាររាយការណ៍ញឹកញាប់ជាងគេ៖

#### ក. ឧបសគ្គផ្នែកហិរញ្ញវត្ថុ

ដោយជំងឺកូវីដ-១៩បានធ្វើការគម្រាមកំហែងយ៉ាងខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ចទៅលើស្ទើរគ្រប់វិស័យទាំងអស់ ហើយត្រូវបានលើកឡើងនៅក្នុងអត្ថបទសង្ខេបគោលនយោបាយរបស់អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) បានបង្ហាញថាជំងឺរាតត្បាតកូវីដ-១៩ នឹងធ្វើឱ្យក្រុមជនងាយរងគ្រោះជាក់លាក់មួយចំនួន រួមមានស្ត្រី កុមារ ជនជាតិដើមភាគតិច និងពលករចំណាកស្រុករងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរដោយសារតែភាពអត់ការងារធ្វើ និងកង្វះការងារសម្រាប់អ្នកប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។[57] ការអនុវត្តបទបញ្ជានៃការបិទប្រទេសទាំងស្រុង និងការបិទដោយផ្នែក នៅតាមតំបន់ដែលរងការប៉ះពាល់ធ្ងន់ធ្ងរក្នុងប្រទេសមួយចំនួនក្នុងគោលដៅទប់ស្កាត់ការរីករាលដាលនៃជំងឺ-១៩ បានបង្ខំឱ្យអាជីវកម្ម និងកន្លែងជួបជុំសាធារណៈនានាត្រូវបានបិទទ្វារ។ ដោយសារការបិទប្រទេស និងការអនុវត្តគម្លាតសុវត្ថិភាព អាជីវកម្មគ្រប់ទំហំត្រូវរងផលប៉ះពាល់ដោយប្រយោលពីជំងឺកូវីដ-១៩។ ការបិទទ្វារបណ្តោះអាសន្ននៃសាលសារៀន ភោជនីយដ្ឋាន បៀរហ្គារឌិន និងទីសាធារណៈផ្សេងទៀត ក៏មានន័យថាការផ្អាកការងារបណ្តោះអាសន្នរបស់បុគ្គលិក កម្មករ និយោជិត ប្រតិបត្តិការអាជីវកម្ម និងសកម្មភាពទាក់ទងនឹងសេដ្ឋកិច្ចផ្សេងទៀតដូចគ្នា។ គ្រួសារមួយចំនួនត្រូវប្រឈមនឹងការបាត់បង់ប្រាក់ចំណូលប្រចាំខែ ដោយសារកន្លែងធ្វើការរបស់ពួកគេ ចាប់ផ្តើមផ្អាកប្រតិបត្តិការ ឬបានបិទទ្វារទាំងស្រុងតែម្តង។[58] តាមរយៈការសិក្សាស្រាវជ្រាវរបស់ក្រសួងអប់រំ យុវជន

---

[56] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី១៨

[57] https://www.fao.org/3/ca8560en/CA8560EN.pdf

[58] សេចក្តីសម្រេច ស្តីពីការដាក់ចេញនូវវិធានការរដ្ឋបាល ដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ សម្រាប់រយៈពេល១៤ថ្ងៃ

និងកីឡា ដែលសហការជាមួយអង្គការយូនីសេហ្វ នៅក្នុងគម្រោងនៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩បានបង្ហាញប្រាប់ពីទិន្នន័យជាង ៧៧% នៃអ្នកឆ្លើយតប គឺពុំបានផ្លាស់ប្តូរការងារ ឬមុខរបររបស់ខ្លួនដោយសារកូវីដ-១៩ នោះឡើយ ហើយ ១៦% ទៀតត្រូវស្វែងរកការងារមួយផ្សេងទៀត។ ដោយសារកត្តាជីវភាពមានការធ្លាក់ចុះកុមារត្រូវបានបោះបង់ការសិក្សា ដើម្បីចាប់ផ្តើមធ្វើការសម្រួលជីវភាពគ្រួសារ ហើយមានកុមារផ្សេងទៀតត្រូវបានកាត់បន្ថយម៉ោងសិក្សារបស់ខ្លួន ព្រោះតែជួយដល់ការងារផ្ទះច្រើនជាងមុនដែលមានផលរំខានដល់ការសិក្សារបស់កុមារ។[59] លើសពីនេះ ឧបសគ្គដែលដែលត្រូវបានលើកឡើងញឹកញាប់ជាងគេ គឺឧបសគ្គផ្នែកហិរញ្ញវត្ថុសម្រាប់បង់ថ្លៃអ៊ីនធឺណេត ទូរទស្សន៍ខ្សែកាប ឬបរិក្ខារដទៃទៀតសម្រាប់សិក្សាពីចម្ងាយ។[60]

### ខ. បញ្ហាក្នុងការភ្ជាប់អ៊ីនធឺណែត

ការបិទផ្អាកគ្រឹះស្ថានសិក្សាទាំងរដ្ឋនិងឯកជនត្រូវបានជំនួសមកវិញដោយការសិក្សាពីចម្ងាយ (តាមអនឡាញ)ដែលតាមរយៈប្រព័ន្ធអ៊ីនធឺណែតដូចជា Google Meet ឬ Zoom Meeting ជាដើម។ ការសិក្សាបែបនេះបានផ្តល់ផលវិបាកជាច្រើនទៅដល់សិស្សានុសិស្ស ព្រមទាំងលោកគ្រូអ្នកគ្រូផងដែរដូចជា៖

• ការពិបាកក្នុងការសួរគ្រូអំពីសំណួរដែលទាក់ទងទៅនឹងមេរៀន

• លោកគ្រូអ្នកគ្រូបង្រៀនសិស្សមិនបានដិតដល់

• បញ្ហាប្រព័ន្ធប្រព័ន្ធអ៊ីនធឺណែតដំណើរការមិនរលូនដែលនេះជាផលវិបាកដល់សិស្សដែលរស់នៅតាមតំបន់ជនបទ

• ការសិក្សាមិនសូវមានភាពទាក់ទាញ

• សិស្សមិនសូវចាប់អារម្មណ៍ក្នុងការរៀនសូត្រ និងមិនសូវមានសកម្មភាពច្រើនដូចជាការឡើងដោះស្រាយលំហាត់ដោយផ្ទាល់

• សិស្សមួយចំនួនពិបាកក្នុងការចូលរួមធ្វើការងារជាក្រុម

• លោកគ្រូអ្នកគ្រូមិនសូវមានបច្ចេកទេសក្នុងការបង្រៀនតាមប្រព័ន្ធអ៊ិនធឺណេត

• រៀនមិនបានគ្រប់ម៉ោង

• លោកគ្រូអ្នកគ្រូមានការលំបាកក្នុងការគ្រប់គ្រងការប្រឡងនានា។[61]

ជាក់ស្តែងមានសិស្សានុសិស្សមួយចំនួនបាននិយាយរៀបរាប់ពីបញ្ហានេះ ដែលបានកើតមានឡើងជាប្រចាំក្នុងអំឡុងពេលសិក្សាពីចម្ងាយ។ ការរៀនសូត្រពីចម្ងាយតាមរយៈអនឡាញនេះ គឺបានបង្កភាពងាយ

[59] ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច នៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី១៤

[60] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី២០

[61] ទូរសិក្សា នៃគម្រោងវេទិការៀនឌីជីថល

ស្រួលក៏ពិតមែន តែក៏មានបញ្ហាមួយចំនួនដែលសិស្សានុសិស្សបានជួបប្រទះដូចដែលបានរៀបរាប់ខាងលើ ហើយសេវាអ៊ីនធឺណេតយឺត ធ្វើឱ្យពេលដែលលោកគ្រូ អ្នកគ្រូពន្យល់មកសិស្សានុសិស្សមិនសូវបាន មិនសូវយល់ ឬរំលងចំនុចសំខាន់នៃមេរៀន ហើយបញ្ហាភ្ជាប់អ៊ីនធឺណេតនេះជាបញ្ហាចម្បងដែលកុមារជួបគ្រប់ៗគ្នា។[62]

### គ. អាណាព្យាបាលខ្វះចំណេះដឹងអំពីខ្លឹមសារនៃការសិក្សា

ការវាយតម្លៃលើតម្រូវការនេះមានគោលបំណងវាស់វែងកម្រិតនៃការគាំទ្រ ដែលកុមារបានទទួលពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេពាក់ព័ន្ធនឹងការសិក្សាពីចម្ងាយ។ ឧបសគ្គធំៗដែលធ្វើឱ្យឪពុកម្តាយ ឬអាណាព្យាបាលពុំអានចូលរួម និងផ្តល់ការគាំទ្រដល់កូនបាន រួមមានការខ្វះចំណេះដឹងអំពីមាតិកានៃការសិក្សា ការខ្វះពេលវេលាដោយសារត្រូវធ្វើការ និងបំពេញការទទួលខុសត្រូវផ្សេងទៀត និងការខ្វះចំណេះដឹង និងពុំមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា។[63]

### ឃ. អាណាព្យាបាលខ្វះពេលវេលា ដើម្បីផ្តល់ការគាំទ្រដល់ការសិក្សានៅផ្ទះ

កុមារមួយចំនួន មិនទាន់នឹងសម្របខ្លួនបានលឿនទៅក្នុងរបៀបសិក្សាថ្មីបែប (តាមអនឡាញ) នេះបានទេ ហើយអាចខ្វះទាំងចំណេះដឹងផ្នែកបច្ចេកវិទ្យា ព្រមទាំងការគ្រប់គ្រងការរៀនសូត្ររបស់ពួកគេផងដែរដូចនេះកុមារទាមទារឱ្យមានការគាំទ្រខ្លាំងក្លាពីឪពុកម្តាយ ឬអាណាព្យាបាលទើបពួកគេអាចធ្វើបន្តការសិក្សាបាន។[64] ដើម្បីផ្គត់ផ្គង់ជីវភាពក្នុងក្រុមគ្រួសារ ឪពុកម្តាយនិងអាណាព្យាបាលទាំងអស់ត្រូវចំណាយពេលវេលាជាច្រើនរបស់ខ្លួនដើម្បីធ្វើការ និងប្រកបមុខរបររកស៊ីជាដើម ខណៈពេលដែលមានការព្រួយបារម្ភពីសុខភាពយ៉ាងខ្លាំងអំពីការរាតត្បាតនៃជំងឺកូវីដ-១៩ និងលំហូរសេដ្ឋកិច្ច ហើយនេះជាមូលហេតុដែលឪពុកម្តាយ ឬអាណា-ព្យាបាលជាង ២០% ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការគាំទ្រ ក៏ដូចជាជំរុញដល់ការសិក្សានៅផ្ទះរបស់កុមារ។[65]

### ២.១.២.៤ ការឆ្លើយតបចំពោះជំងឺកូវីដ-១៩ នៅក្នុងវិស័យអប់រំ

ក្រោមការដឹកនាំរបស់ឯកឧត្តមរដ្ឋមន្ត្រីបណ្ឌិត ហង់ ជួនណារ៉ុន បានផ្តល់ការយល់ព្រមជាផ្លូវការទៅលើកផែនការឆ្លើយតបរបស់វិស័យអប់រំនៅកម្ពុជាចំពោះការរាត្បាតជាសកលនៃជំងឺកូវីដ-១៩។[66] ផែនការឆ្លើយតបនេះ ត្រូវបានរៀបចំឡើងទៅតាមតម្រូវការជាក់លាក់ ដែលបានកើតឡើងដោយសារតែស្ថានភាពជំងឺកូវីដ-១៩។

---

[62] សិស្សនៅជនបទខ្លះ ជួបការលំបាកនឹងអ៊ីនធឺណិត ដែលធ្វើឱ្យការសិក្សាពីចម្ងាយមិនបានគ្រប់គ្រាន់ (thmeythmey.com)

[63] មើលការចូលរួមរបស់ឪពុកម្តាយនៅក្នុងការសិក្សាពីចម្ងាយ នៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី២០

[64] https://thmeythmey.com/event/?page=detail&id=106509

[65] មើលលទ្ធភាពចូលរួមក្នុងការកម្មវិធីសិក្សាពីចម្ងាយ នៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី២០

[66] https://www.moeys.gov.kh/index.php/en/planning/3858.html#. X4_EMIgzY2w

ផែនការនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ជាគំនិតជូនដៃគូអំពីការគាំទ្រដែលពួកគេអាចផ្តល់ឱ្យបាន សម្រាប់ការពារជំងឺនេះ ការគាំទ្រដល់អ្នកសិក្សា ជាពិសេសដល់កុមារដែលរងគ្រោះក្នុងការអំឡុងពេលដែលសាលារៀនត្រូវបិទទ្វា។

ក្រសួងអប់រំ យុវជន និងកីឡាបានចេញសារាចរមួយ ស្តីពីការអនុវត្តកម្មវិធីសិក្សាពីចម្ងាយ និងកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច សម្រាប់កម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។[67] ជាការបំពេញបន្ថែមលើសារាចរនេះ គឺក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលការណ៍ណែនាំប្រតិបត្តិ[68] ដើម្បីគាំទ្រដល់ការអនុវត្តការសិក្សាពីចម្ងាយនៅតាមសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សាចំណេះទូទៅ និងគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។ ក្នុងគោលការណ៍ណែនាំនេះ គាំទ្រដល់ការអនុវត្តសារាចរណែនាំនៅថ្នាក់សិក្សាជាតិ ថ្នាក់ក្រោមជាតិ និងកម្រិតគ្រឹះស្ថានសិក្សា ក៏ដូចជារៀបរាប់បន្ថែមទៀតអំពីកិច្ចការគ្រប់គ្រង និងកិច្ចការសម្រាប់អនុវត្តការសិក្សាចម្ងាយ។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការផ្សាយផ្ទាល់វីដេអូបង្រៀនកុមារចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៣ ដែលវីដេអូបង្រៀនត្រូវបានរក្សាទុក និងអាចឱ្យកុមារចូលមើលបានតាមរយៈគេហទំព័រជាច្រើនដូចជា ទំព័រហ្វេសប៊ុករបស់ក្រសួងអប់រំ យុវជន និងកីឡា យូធូប និងកម្មវិធី E-Learning។ល។[69] បន្ទាប់មកក្រសួងអប់រំ យុវជន និងកីឡា បានចេញគោលការណ៍ចាំបាច់ ដែលបានធ្វើការណែនាំឱ្យគ្រឹះស្ថានអប់រំរដ្ឋ និងឯកជនទាំងអស់អនុវត្តន៍វិធានការជាច្រើន រួមទាំងវិធានការសុខភាពផងដែរ ដើម្បីឱ្យគ្រឹះស្ថានអប់រំទាំងអស់បានត្រៀមខ្លួនសម្រាប់ការបើកដំណើរការសាលារៀនឡើងវិញ។ គោលការណ៍ណែនាំទាំងនេះ ផ្តល់ការណែនាំអំពីរបៀបធានាសុវត្ថិភាព និងសុខភាពបុគ្គលិកសិក្សា គ្រូបង្រៀន និកុមារនៅក្នុងបរិបទជំងឺកូវីដ-១៩ និងរយៈពេលក្រោយៗទៀត។ គោលកាណ៍ណែនាំទាំងនេះអំពាវឱ្យមានការបង្កើន ការសហការ និងធ្វើការជាមួយដៃគូរអង្គពាក់ព័ន្ធនានា និងបានកំណត់នូវលក្ខខណ្ឌសម្រាប់ពិនិត្យតាមដានគ្រប់គ្រងករណី និងរៀបចំរបាយការណ៍។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្អាកការប្រលងថ្នាក់ជាតិសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិក្នុងឆ្នាំសិក្សា ២០១៩/២០២០ និងបានណែនាំឱ្យសិស្សទាំងអស់ធ្វើស្វ័យសិក្សានៅផ្ទះដោយប្រើប្រាស់សៀវភៅសិក្សា និងថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតឱ្យគ្រឹះស្ថានអប់រំឯកជនរៀបចំការប្រលងតាមអនប្រព័ន្ធអនឡាញទៅតាមប្រតិទិននៃគ្រឹះស្ថានទាំងនោះ ដោយត្រូវអនុវត្តតាមស្តង់ដារគុណភាព សម្រាប់ការសិក្សានៅកម្រិតបឋមភូមិ និងទុតិយភូមិ។ ហើយលិខិតនេះបានផ្តល់ការណែនាំឱ្យគ្រឹះស្ថានទាំងនេះចេញលិខិត

[67] សារាចរណែនាំលេខ ២៣ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពី កម្មវិធីសិក្សាពីចម្ងាយ និង កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់សិស្សនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ចេញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០

[68] សេចក្តីណែនាំប្រតិបត្តិលេខ ២៩ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការអនុវត្តការសិក្សាពីចម្ងាយ

[69] សេចក្តីប្រកាសលេខ៣៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីកាលបរិច្ឆេទបញ្ចប់ការផ្សាយផ្ទាល់វីដេអូបង្រៀនថ្នាក់ទី១ដល់ទី៣

បញ្ជាក់ការប្រលងដោយខ្លួនឯងដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។[70] លិខិតមួយទៀត ត្រូវបានផ្ញើជូនគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទាំងអស់ដែលបានផ្តល់ការសិក្សាពីចម្ងាយឱ្យរៀបចំការប្រលងដែលនិស្សិតត្រូវចូលរួមដោយគោរពតាមលក្ខខណ្ឌសុវត្ថិភាព។[71]

ដើម្បីពង្រឹងបន្ថែមលើការអប់រំសម្រាប់កុមារ ក្រសួងអប់រំ យុវជន និងកីឡាបានផលិតសៀវភៅលំហាត់សម្រាប់សិស្ស និងផ្សព្វផ្សាយតាមរយៈក្រុមតេឡេក្រាម (Telegram)[72] និងបណ្តាញទំនាក់ទំនងសង្គមដទៃទៀត។ ក្រសួងបានណែនាំឱ្យគណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនធ្វើការបោះពុម្ព និងថតចម្លងសៀវភៅលំហាត់ជូនកុមារមកពីគ្រួសារក្រីក្រ។[73]

**ក. ការសិក្សាពីចម្ងាយក្នុងអំឡុងនៃការរាតត្បាតជាសកល**

ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក្រសួងអប់រំ យុវជន និងកីឡា បានចាត់វិធានការដើម្បីធានាឱ្យកុមារមានសុវត្ថិភាព ទទួលបានការការពារ និងសុខភាពមាំមួន បើទោះជាសាលារៀនត្រូវបិទទ្វារក៏ដោយ។ ការគាំទ្រសំខាន់ៗរួមមាន សកម្មភាពដែលពាក់ព័ន្ធនឹងការធានានិរន្តភាពនៃការសិក្សា ដូចជា ការផលិតឯកសារព័ត៌មានអប់រំ និងផ្សព្វផ្សាយ និងសកម្មភាពអប់រំផ្សព្វផ្សាយអំពីហានិភ័យដែលពាក់ព័ន្ធ, ការគាំទ្រដល់ការកសាងបរិយាកាសសិក្សាឱ្យកាន់តែរឹងមាំនិងកាន់តែមានភាពធន់ ការផ្តល់សម្ភារៈអនាម័យជាមូលដ្ឋានជូនសាលារៀន ការផ្តល់ថវិកាជំនួយដល់សាលារៀននិងសិស្សានុសិស្ស កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងការភ្ជាប់ទំនាក់ទំនងជាមួយនឹងកម្មវិធីអាហារូបករណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ការផ្តល់អាហារជូនកុមារមកពីគ្រួសារក្រីក្រ និងការត្រៀមរៀបចំសាលារៀន សម្រាប់ការបើកដំណើរការឡើងវិញប្រកបដោយសុវត្ថិភាព។ សកម្មភាពទាំងនេះអនុវត្តនៅគ្រប់អនុវិស័យទាំងអស់នៃវិស័យអប់រំដូចជា ការអប់រំកុមារ អប់រំបឋមសិក្សា និងមធ្យមសិក្សា អប់រំឧត្តមសិក្សា ការបណ្តុះបណ្តាលគ្រូ និងវិស័យអប់រំក្រៅប្រព័ន្ធ។[74] ការធានានិរន្តភាពនៃការសិក្សានៅពេលដែលសាលារៀនត្រូវបិទទ្វារ បានក្លាយជាអាទិភាពមួយរបស់រដ្ឋាភិបាលនៅទូទាំងប្រទេស និងសកលលោក ដោយរដ្ឋាភិបាលជាច្រើនបានងាកប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT)។ បច្ចេកវិទ្យានេះតម្រូវឱ្យគ្រូបង្រៀនតាមប្រព័ន្ធអនឡាញ ហើយនៅ

[70] សេចក្តីណែនាំលេខ ២៨៥១ របស់ក្រសួងអប់រំ យុវជន និងកីឡា

[71] សេចក្តីណែនាំលេខ ២៨៥២ របស់ក្រសួងអប់រំ យុវជន និងកីឡា

[72] Telegram គឺជាកម្មវិធីផ្ញើសារដ៏ពេញនិយម ស្រដៀងទៅនឹង WhatsApp, Line និង WeChat។ កម្មវិធីនេះភ្ជាប់ទៅលេខទូរស័ព្ទដៃរបស់អ្នកប្រើដើម្បីបង្កើតគណនីហើយទំនាក់ទំនងត្រូវបាននាំចូលដោយស្វ័យប្រវត្តិក្នុងស្មាតហ្វូន។

[73] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី២៧

[74] មើលការសិក្សាពីចម្ងាយក្នុងអំឡុងនៃការរាតត្បាតជាសកល នៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី២៧

កម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តសកម្មភាព និងវិធានការបន្ទាន់ជាការឆ្លើយតបចំពោះការគំរាមកំហែងនៃកូវីដ-១៩ ដោយផ្តោតការយកចិត្តទុកដាក់លើការជួយឱ្យកុមារបានបន្តការសិក្សារបស់ពួកគេ។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជួយឱ្យកុមារបានបន្តទទួលបានការសិក្សាពីចម្ងាយ ត្រូវបានអនុវត្តតាមថ្នាលបច្ចេកវិទ្យាចម្រុះជាច្រើន។ កម្មវិធីគាំទ្រដល់ការបន្តការសិក្សា ដែលអនុវត្តដំបូងៗចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សាទុតិយភូមិ អាចចូលមើលតែតាមរយៈប្រព័ន្ធអនឡាញតែប៉ុណ្ណោះ ដូចជា តាមរយៈថ្នាលបច្ចេកវិទ្យានានា ដូចជាគេហទំព័រសិក្សាពីចម្ងាយ ទំព័រហ្វេសប៊ុក ប៉ុស្តិ៍យូធូបរបស់ក្រសួងអប់រំ យុវជន និងកីឡា, គេហទំព័រ Krou Cambodia និងកុមាររៀន កុមារចេះ (Komar Rien Koma Cheh), ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងសម្រាប់ការសិក្សាថ្នាក់ដំបូងជាដើម។

ការស្នើឱ្យមានការប្រើប្រាស់វិធីសាស្រ្តសិក្សាពីចម្ងាយបែបនវានុវត្តន៍ ដើម្បីជំរុញការចូលរួម និងលើកទឹកចិត្តដល់កុមារ ជាពិសេសកុមារតូចៗ និងត្រូវរៀបចំរចនាសម្ព័ន្ធឱ្យបានកាន់តែប្រសើរសម្រាប់តាមដានកម្រិតនៃការសិក្សារបស់សិស្ស។ តាមរយៈការសង្កេតឃើញពីភាពរីកចម្រើនមួយចំនួន ដោយសារតែលទ្ធផលនៃការអង្កេតបង្ហាញថា ក្នុងចំណោមអ្នកឆ្លើយតបចំពោះការអង្កេត ៨៧% បានលើកឡើងថា ពួកគេបានទទួលលំហាត់ ឬកិច្ចការសម្រាប់ធ្វើនៅផ្ទះ ហើយលោកគ្រូអ្នកគ្រូបានដាក់ឱ្យអនុវត្តន៍នូវយន្តការសម្រាប់ការតាមដានការបញ្ចប់កិច្ចការដែលកុមារត្រូវធ្វើនៅផ្ទះ។[75]

### ២.១.២.៥. បរិវត្តកម្មឌីជីថលនៃការអប់រំ

ការអប់រំបែបឌីជីថល គឺជាការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល ក្នុងការរៀននិងការបង្រៀន ក៏ដូចជាការគ្រប់គ្រងដែរ។ ចាប់តាំងពីដើមសប្តាហ៍ទី២ នៃមីនា ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានផ្អាកដំណើរការគ្រឹះស្ថានសិក្សាជាបណ្តោះអាសន្ន និងបានរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក រួមទាំងការផ្តល់សេវារៀនពីចម្ងាយដោយបានដាក់ចេញវិធានការជា ៣ ដំណាក់កាលរួមមាន៖

- ដំណាក់កាលបន្ទាន់៖ ការបង្កើតគណៈកម្មការពិសេសមួយសម្រាប់ផលិតវីដេអូ បង្រៀនសម្រាប់មុខវិជ្ជាគោល និងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះ និងផ្សព្វផ្សាយ លើវេទិកាឌីជីថលដែលមានស្រាប់
- ដំណាក់កាលមធ្យម៖ ការកែលម្អវេទិកាឌីជីថលដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានកាន់តែប្រសើរ និងផលិតវីដេអូបង្រៀនដែលចាំបាច់ បន្ថែមទៀត
- ដំណាក់កាលវែង៖ ការរៀបចំកែលម្អ និងអភិវឌ្ឍវេទិកាឌីជីថលសម្រាប់ផ្តល់សេវាអប់រំ តាមប្រព័ន្ធអេឡិចត្រូនិកដែលមានលក្ខណៈសមរម្យ និងគ្រប់ជ្រុងជ្រោយ។

[75] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៣០

ក្នុងអំឡុងពេលនៃវិស្សមកាលមុនពេលកំណត់ ដើម្បីជាជំនួយដល់ការសិក្សារបស់សិស្សនុសិស្សទាំងអស់នៅថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ក្រសួងអប់រំយុវជននិងកីឡាបានរៀបចំវិធានការមួយចំនួយជាបន្តបន្ទាប់ ដូចជាការបង្កើតកម្មវិធីសិក្សា "ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកដែលទទួលបានការគាំទ្រ និងការចូលរួមពីសំណាក់សិស្សានុសិស្សជាច្រើន ដោយមានការសហការ និងការចូលរួមពីសំណាក់វិស័យឯកជន និងអ្នកជំនាញបច្ចេកវិទ្យាមួយចំនួន ដែលកុមារអាចទទួលបានឱកាសពីការរៀនតាមប្រព័ន្ធអេឡិចត្រូវនិកនេះកាន់តែសម្បូរបែប។[76] ក្រសួងបានចេញសេចក្តីណែនាំស្តីពីការលើកកម្ពស់បង្រៀននិងរៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិកដល់គ្រឹះស្ថានសិក្សាចំណេះដឹងទូទៅ មាតាបិតា អាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមជំរុញការអនុវត្ត និងធានាបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន និងការវាយតម្លៃ។ សកម្មភាពសំខាន់នៅក្នុងដំណាក់នីមួយៗរួមមាន៖

**ក. ដំណាក់កាលទី១** ៖ ការផ្តោតលើសិស្សថ្នាក់ទី ៩ និងទី១២ ដែលក្រសួងបានបង្កើតវេទិកាឌីជីថលចំនួន ៣ ដើម្បីរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិកគឺ៖

- បណ្តាញ YouTube ផ្លូវការរបស់ក្រសួង៖ youtube.com/moeyscambodia ដែលមានវីដេអូបង្រៀនទាំងអស់ សម្រាបសិស្សនុសិស្សអាចសិក្សាបានទៅតាមពេលវេលាជាក់ស្តែងរបស់ខ្លួន។
- ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង៖ www.facebook.com/moeys.gov.kh ដែលធ្វើការផ្សព្វផ្សាយជារៀងរាល់ថ្ងៃ នៅពេលព្រឹកសម្រាប់ថ្នាក់ទី៩ និងពេលរសៀលសម្រាប់ថ្នាក់ទី១២។
- មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង៖ www.elearning.moeys.gov.kh ដោយសិស្សានុសិស្សអាចចូលទៅសិក្សាតាមរយៈការជ្រើសរើសវគ្គសិក្សា ឬមេរៀនដែលត្រូវសិក្សាដោយឥតគិតថ្លៃ និងមិនចាំបាច់ចុះឈ្មោះ។

**ខ. ដំណាក់កាលទី២** ៖ ការថតមេរៀនសម្រាប់សិស្សគ្រប់កម្រិត

- មត្តេយ្យសិក្សា៖ ក្រសួងអប់រំ យុវជន និងកីឡាក៏បានផលិតខ្សែវីដេអូបង្រៀនសម្រាប់កុមារតូច នៅថ្នាក់មត្តេយ្យសិក្សា។ មុខវិជ្ជាចំនួន៥ ត្រូវបានផលិតជាខ្សែវីដេអូសម្រាប់កុមារតូចនៅថ្នាក់មត្តេយ្យសិក្សា។
- បឋមសិក្សា៖ ក្រសួងបានដាក់ឲ្យមានការអនុវត្តជាផ្លូវការនូវកម្មវិធី "កុមាររៀនកុមារចេះ" ដែលរួមមានកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យានៅកម្រិតថ្នាក់ដំបូងនៅបឋមសិក្សា ដូចជាសៀវភៅណែនាំសម្រាប់គ្រូ និងឯកសារបង្រៀននិងរៀនសម្រាប់

---

[76] សៀវភៅ បរិវត្តកម្មឌីជីថលនៃការអប់រំ ដោយបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ទំព័រទី២១

ប្រើប្រាស់ក្នុងមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាសម្រាប់សិស្សថ្នាក់ទី១ និងទី២ ដែលនឹងបំពេញបន្ថែមទៅលើសៀវភៅសិក្សាគោលភាសាខ្មែរអានសរសេរដែលមានស្រាប់សម្រាប់កុមារថ្នាក់ទី៤ ដល់ទី៦ ក្រសួងបានផលិតវីដេអូបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។

- ❖ មធ្យមសិក្សា៖ ក្រសួងបានផលិតខ្សែវីដេអូបង្រៀន សម្រាប់ថ្នាក់ទី៧ ដល់១២ និងបានជំរុញឱ្យសាលារៀនផ្តល់លទ្ធភាពឱ្យសិស្សបានខ្ចីសៀវភៅសិក្សាគោល ដើម្បីស្វ័យសិក្សាបន្ថែមរៀងៗខ្លួន។
- ❖ ការអប់រំក្រៅប្រព័ន្ធ៖ ក្រសួងបានដាក់ឱ្យប្រើប្រាស់កម្មវិធីសមមូលអប់រំកម្រិតមូល-ដ្ឋានតាមអ៊ីនធឺណិត (BEEP) ដែលជាការផ្តួចផ្តើមរួមគ្នារវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងអង្គការយូណេស្កូ។ កម្មវិធីនេះនឹងជួយឱ្យយុវជនកម្ពុជាបញ្ចប់ការអប់រំមូលដ្ឋានតាមរយៈការរៀនដោយខ្លួនឯង តាមប្រព័ន្ធពីរបញ្ចូលគ្នា ដែលមានភាពបត់បែន និងទន់ភ្លន់។
- ❖ ការអប់រំពិសេស ៖ ក្រសួងបានរៀបចំផ្សាយផ្ទាល់ការបង្រៀនកម្មវិធីអប់រំពហុភាសាតាមស្ថានីយវិទ្យុផ្សាយសំឡេងរបស់ខេត្តរតនគិរី និងមណ្ឌលគិរី សម្រាប់កម្រិតមត្តេ-យ្យសិក្សា និងបឋមសិក្សាថ្នាក់ទី១ ដល់ទី៣ជាភាសាទំពួន និងគ្រឹងក្នុងខេត្តរតនគិរី និងជាភាសាព្នងក្នុងខេត្តមណ្ឌលគិរី។
- ❖ ការអប់រំបច្ចេកទេស ៖ ក្រសួងបានណែនាំគ្រូជំនាញបច្ចេកទេសឲ្យរៀបចំមេរៀនសង្ខេបបែកជូនសិស្សថតវីដេអូបង្រៀនរៀបចំការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក។ គ្រូជំនាញបានរៀបចំក្រុមសិស្សតាមជំនាញ និងតាមកម្រិតសិក្សាដោយបានបង្កើតជាបណ្តាញសម្រាប់ទំនាក់ទំនងជាមួយសិស្ស និងក្លឹបសិក្សាតាមជំនាញ។
- ❖ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ៖ នៅវិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានបង្កើតបណ្តាញទំនាក់ទំនងរវាងគរុសិស្ស គរុនិស្សិតជាមួយនឹងគ្រូឧទ្ទេស។ គ្រូឧទ្ទេស អាចទម្លាក់ឯកសារមេរៀន ឬតំណរភ្ជាប់ឯកសារផ្សេងៗទៅឱ្យគរុសិស្ស គរុនិស្សិត ដើម្បីអាចសិក្សាតាមពេលម៉ោងក្នុងកាលវិភាគប្រចាំថ្ងៃដែលបានរៀបចំហើយគរុសិស្សគរុនិស្សិត និងគ្រូឧទ្ទេសអាចពិភាក្សា ឆ្លងឆ្លើយគ្នាអំពីខ្លឹម-សារមេរៀន ឬអំពីកិច្ចការគ្រូឧទ្ទេសដាក់ឱ្យធ្វើ។

❖ គ្រឹះស្ថានឧត្តមសិក្សា៖ គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនបានរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក រៀបចំបន្ទប់រៀន ផលិតមេរៀន និងបង្កើតបណ្តាញទំនាក់ទំនងសម្រាប់និស្សិត និងសាស្ត្រាចារ្យ។

**គ. ដំណាក់កាលទី ៣** ៖ ការជួយដល់សិស្សនៅជនបទ

ក្នុងស្មារតីធានាសេវាអប់រំប្រកបដោយសមធម៌ ជាពិសេសសិស្សានុសិស្សនៅជនបទអាចទទួលបានការអប់រំប្រកបដោយគុណភាព ដូចសិស្សានុសិស្សនៅក្រុង ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងព័ត៌មានបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ស្តីពីការរៀបចំផលិត និងផ្សព្វផ្សាយកម្មវិធីការសិក្សាពីចម្ងាយនិងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។ តាមស្មារតីនៃអនុស្សរណៈនេះ ក្រសួងអប់រំយុវជន និងកីឡានឹងផ្តល់មេរៀនគ្រប់មុខវិជ្ជា និងគ្រប់ថ្នាក់ឱ្យទៅក្រសួងព័ត៌មានសម្រាប់ផ្សាយកម្មវិធីតាមប្រព័ន្ធទូរទស្សន៍ផ្កាយរណប «តេជោធីវី» ដែលជាប៉ុស្តិ៍ទូរទស្សន៍អប់រំថ្មី «ទទក២»។[77]

## ២.២.កត្តាដែលជំរុញនិងផលវិបាកនៃការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ (អនឡាញ)

### ២.២.១ លទ្ធភាពរកឃើញ និងការវាយតម្លៃ

ការវាយតម្លៃនៃគម្រោងការអប់រំនៃកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩នេះ បានវាស់វែងពីលទ្ធភាពអាចចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់សិស្សនិងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ក៏ដូចជា លើឧបសគ្គដែលពួកគេជួបប្រទះក្នុងការចូលរួមក្នុងកម្មវិធីទាំងនេះ ក៏ដូចជា ប្រភេទនៃការសិក្សាតាមប្រព័ន្ធអនឡាញ ដែលជាជម្រើសមួយកុមារបានប្រើប្រាស់កន្លងមក។ ខណៈពេលដែលសិស្សមកពីគ្រួសារដែលមិនមែនជាគ្រួសារក្រីក្រ ៧២% បានរាយការណ៍ថាបានប្រើប្រាស់វិធីសាស្ត្រសិក្សាពីចម្ងាយដែលជាជម្រើសក្នុងបរិបទនៃជំងឺកូវីដ-១៩ ហើយមានសិស្សមកពីគ្រួសារក្រីក្រ ត្រឹមតែ ៥៧% ប៉ុណ្ណោះដែលរាយការណ៍ថាបានចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ។[78]

#### ២.២.១.១.លទ្ធភាពចូលរួមនិងការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា

កុមារបានប្រើប្រាស់ក្រដាស់កិច្ចការ និងឯកសារសិក្សាដទៃទៀត ដែលសាលាបានផ្តល់ឱ្យហើយប្រើប្រាស់វីដេអូអប់រំអនឡាញដោយមិនគិតថ្លៃនៅលើបណ្តាញទំនាក់ទំនងសង្គមជាផ្លូវរបស់ក្រសួងអប់រំ យុវជន និងកីឡា និងថ្នាលបច្ចេកវិទ្យាដទៃទៀត សម្រាប់ការបន្តការរៀនសូត្ររបស់កុមារ, ៣៥% បានប្រើប្រាស់ម៉ូឌុល

[77] សៀវភៅ បរិវត្តកម្មឌីជីផលនៃការអប់រំ ដោយបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ទំព័រ២៤

[78] ការវាយតម្លៃមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៦៩

សិក្សាអនឡាញ ដែលរៀបចំដោយសាលារៀនរបស់ពួកគេ និង ៣០%បានរាយការណ៍ថាបានចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ តាមរយៈការមើលការផ្សព្វផ្សាយមេរៀនតាមទូរទស្សន៍ជាតិ។ ក្រៅតែពីវិធីសាស្ត្រសិក្សាពីចម្ងាយជាជម្រើស ដែលត្រូវបានលើកឡើងញឹកញាប់ជាងគេទាំងបួន សិស្ស ១៤% បានទទួលការបង្រៀនពីសមាជិកម្នាក់នៅក្នុងគ្រួសារ, ១១% បានទទួលការបង្រៀនគួរ, ៨% បានចូលរួមនៅក្នុងការចុះបង្រៀន ដែលរៀបចំនៅតាមសគមន៍ និងមានសិស្សក្នុងភាគរយតិចតួចបំផុតដែលរាយការណ៍ថាបានប្រើប្រាស់កម្មវិធីតាមវិទ្យុជាតិ ៤% និងកម្មវិធីអប់រំពហុភាសាតាមវិទ្យុ ១%។[79] លទ្ធផលរកឃើញនេះអាចមានទំនាក់ទំនងជាមួយនឹងការមានមាតិកាគ្រប់គ្រាន់សម្រាប់ការសិក្សា និងការខ្វះសម្ភារ និងឯកសារសិក្សាសម្រាប់កុមារដែលមានកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា ជាពិសេសនៅតាមថ្នាលអនឡាញ។វិធីសាស្ត្រដែលកុមារប្រើប្រាស់ក្នុងការសិក្សាត្រូវបានរាយការណ៍ញឹកញាប់ជាងគេគឺការប្រើប្រាស់ក្រដាសលំហាត់ និងឯកសារជាក្រដាសស្នាមដទៃទៀត។ កុមារដែលសិក្សាក្នុងមធ្យមសិក្សាបានរកឃើញថារៀនច្រើនជាមួយនឹងវីដេអូអនឡាញនៅតាមបណ្តាញទំនាក់ទំនងសង្គម និងថ្នាលបច្ចេកវិទ្យាសម្រាប់ការសិក្សាតាមប្រព័ន្ធអនឡាញរបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយក្រៅពីនេះមានកុមារសិក្សាដោយផ្អែកលើម៉ូឌុលសិក្សាតាមប្រព័ន្ធអនឡាញដែលរៀបចំដោយគ្រឹះស្ថានបណ្តុះបណ្តាលរបស់ពួកគេ។ លើសពីនេះ កុមារដែលសិក្សានៅក្នុងកម្រិតមត្តេយ្យ និងកម្រិតបឋមសិក្សាបានបន្តការសិក្សាដោយមានសមាជិកក្នុងគ្រួសារជួយបង្រៀនពួកគេបន្ថែម។ ដោយសារកុមារក្នុងកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា ត្រូវពឹងផ្អែកខ្លាំងលើសមាជិកគ្រួសារ ឬការបង្រៀនតាមសហគមន៍ ដើម្បីជួយដល់ការសិក្សាពីចម្ងាយរបស់ពួកគេ កុមារដែលស្ថិតនៅកម្រិតថ្នាក់នេះត្រូវការការគាំទ្រពិសេស និងត្រូវការឯកសារអប់រំពីចម្ងាយក្នុងទម្រង់ផ្តល់ភាពងាយស្រួលដល់ពួកគេ។ កុមារដែលនៅកម្រិតបឋមសិក្សា និងមត្តេយ្យសិក្សាមានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ហើយការប្រើប្រាស់ការសិក្សាពីចម្ងាយតាមប្រព័ន្ធអនឡាញក៏មិនសូវជាញឹកជាប់នេះទេ ហើយសិស្សបឋមសិក្សាមានកម្រិតខ្ពស់ជាងសិស្សមត្តេយ្យសិក្សាតិចតួច ដោយសារតែឯកសារសម្រាប់កុមារសិក្សាថ្នាក់បឋមច្រើនជាងតាមប្រព័ន្ធអនឡាញ។

#### ២.២.១.២. ការគាំទ្រដល់ការសិក្សាពីចម្ងាយ

ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូបានធ្វើការងារដោយមិនខ្លាចនឿយហត់ ដើម្បីធ្វើការឆ្លើយតបចំពោះផលប៉ះពាល់អវិជ្ជមានដែលបានបង្កឡើងដោយសារវិបត្តិសុខភាពជាសាកល កាបិទទ្វារសាលារៀន និងការថមថយសកម្មភាពសេដ្ឋកិច្ច។ ការស្វែងយល់ពីការយល់ឃើញរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំពីកម្រិតនៃការគាំទ្រដែលពួកគេបានទទួលក្នុងអំឡុងពេលនៃវិបត្តិនេះនឹងជួយវាស់វែងគម្លាតរវាងការគាំទ្រដែល

[79] វិធីសាស្ត្រសិក្សាពីចម្ងាយដែលកុមារបានលើលឡើងក្នុងគម្រោងនៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៧០

ត្រូវបានផ្តល់ និងចំណុចដែលតួអង្គពាក់ព័ន្ធនានាត្រូវផ្តោតការយកចិត្តទុកដាក់នៅក្នុងការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល និងវិស័យឯកជន។ កត្តាដែលមានសារៈសំខាន់សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូក្នុងការកាត់បន្ថយផលប៉ះពាល់នៃការបិទទ្វារសាលារៀន គឺត្រូវដឹងពីប្រភេទនៃការគាំទ្រដល់ការសិក្សាពីចម្ងាយដែលតួអង្គពាក់ព័ន្ធទាំងអស់គិតថាមានសារៈសំខាន់ជាងគេ។ ហើយដើម្បីស្វែងយល់ឱ្យបានកាន់តែប្រសើរពីអាទិភាពសម្រាប់ផ្តល់ការគាំទ្រនៅខាងផ្នែកតម្រូវការរបស់កុមារ និងអាណាព្យាបាលដែលជាអ្នកឆ្លើយតបចំពោះការអង្កេតនៃគម្រោងនេះ ជាលទ្ធផលយើងនៃការស្រាវជ្រាវយើងឃើញមានផ្នែកសំខាន់ៗចំនួន ៦ សម្រាប់ផ្តល់ការគាំទ្រដល់ការសិក្សាពីចម្ងាយរួមមាន៖

- ការគាំទ្រដើម្បីឱ្យកុមារកាន់តែងាយស្រួលរៀនសូត្រនៅផ្ទះ
- គោលការណ៍ណែនាំ និងការណែនាំជាក់ស្តែងដល់មាតាបិតា/អាណាព្យាបាលអំពីរបៀបជួយ និងផ្តល់ការសិក្សាបីចម្ងាយ
- ឯកសារបង្កើនការយល់ដឹងអំពីឧបករណ៍ និងធនធានដែលគ្រួសារអាចយកមកប្រើប្រាស់សម្រាប់ការសិក្សាពីចម្ងាយ
- ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រួសារ ដើម្បីបំពេញការថយចុះប្រាក់ចំណូល
- កន្លែងផ្តល់ការថែទាំកូនប្រកបដោយសុវត្ថិភាពសម្រាប់កុមារដែលអាណាព្យាបាលមិនអាចមើលថែបាន
- ការគាំទ្រថវិកាសម្រាប់បង់ថ្លៃសេវាថែទាំកូនឯកជន។[80]

ផ្នែកសំខាន់ៗ ៣ ក្នុងចំណោមផ្នែកសំខាន់ៗចំនួន ៦ខាងលើសម្រាប់ផ្តល់ការគាំទ្រដល់ការសិក្សាពីចម្ងាយរួមមាន៖ (i) ផ្តល់ការគាំទ្រដើម្បីឱ្យកុមារសិក្សាកាន់តែងាយស្រួលរៀនសូត្រនៅផ្ទះមាន ៦៤%, (ii) ផ្តល់គោលការណ៍ណែនាំ និងការណែនាំជាក់ស្តែងដល់ឪពុកម្តាយ ឬអាណាព្យាបាលអំពីរបៀបជួយកូនក្នុងការសិក្សាពីចម្ងាយឱ្យបានល្អបំផុត មាន៥៥% និង (iii) ផ្តល់ឯកសារបង្កើនការយល់ដឹងអំពីឧបករណ៍ និងធនធានដែលគ្រួសារអាចយកមកប្រើប្រាស់សម្រាប់ជួយការសិក្សាពីចម្ងាយ មាន៤៨%។[81]

### ២.២.១.៣. ការចូលរួមរបស់ឪពុកម្តាយក្នុងការជួយឱ្យកូនបានបន្តការសិក្សា

តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា ការចូលរួមរបស់ឪពុកម្តាយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការសិក្សារបស់សិស្ស និងអាចមានឥទ្ធិពលជាវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្ស ដែលធ្វើឱ្យពួកគេអាចឡើងថ្នាក់ និងបញ្ចប់ការសិក្សាដែលធ្វើឱ្យអត្រាបញ្ចប់ការសិក្សាមានការកើនឡើង កាត់បន្ថយអត្រាបោះបង់ចោល

[80] ទិន្នន័យបង្ហាញពីផ្នែកគាំទ្រសំខាន់ៗសម្រាប់ការសិក្សាពីចម្ងាយនៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៧៨

[81] ទិន្នន័យបង្ហាញពីផ្នែកគាំទ្រសំខាន់ៗសម្រាប់ការសិក្សាពីចម្ងាយនៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៧៧

ការសិក្សា និងជួយដល់ការអភិវឌ្ឍរបស់កុមារ ក៏ដូចជាការបង្កើតមូលធនសង្គម ប្រសិទ្ធភាពនៃការសិក្សា និងធ្វើឱ្យឥរិយាបថរបស់សិស្សកាន់តែប្រសើរ។ ការចូលរួម និងការគាំទ្រពីឪពុកម្តាយរឹតតែមានសារៈសំខាន់ទៅទៀតនៅពេលដែលកុមារភាគច្រើនត្រូវបានសិក្សាពីផ្ទះជាមួយនឹងការត្រួតពិនិត្យតិចតួចពីគ្រូបង្រៀន និងពុំមានការទៅរៀនក្នុងថ្នាក់ឱ្យបានជាប់លាប់ដូចមុន។ ក្នុងការវាយតម្លៃនេះមានគោលបំណងវាស់វែងកម្រិតនៃការគាំទ្រដែលកុមារបានទទួលពីឪពុកម្តាយ ឬអាណាព្យាបាល។ លទ្ធផលជារួមបានបង្ហាញពីការឆ្លើយតបជាមធ្យមពីអាណាព្យាបាលកុមារដែលរៀននៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សាអំពីពេលវេលាដែលពួកគេមានសម្រាប់ជួយកូនៗក្នុងការសិក្សាពីចម្ងាយនៅផ្ទះ និងការចំណាយពេលវេលា ដើម្បីជួយកុមារសិក្សាពីចម្ងាយ។ តាមរយៈការស្រាវជ្រាវ យើងទទួលបានទិន្នន័យអំពីអាណាព្យាបាល ៤២% អាចជួយដល់ការសិក្សាពីចម្ងាយបានខ្លះ,មាន ២៣% អាចផ្តល់ការគាំទ្រគ្រប់ពេលវេលាទាំងអស់ និង ៩% មិនដែលមានជួយកូនៗក្នុងការសិក្សាពីចម្ងាយនោះឡើយ។ ក្នុងចំណោមអាណាព្យាបាល ២៣% ដែលបានផ្តល់ការគាំទ្រគ្រប់ពេលវេលាទាំងអស់ដល់កូនៗ ក៏បានលើកឡើងអំពីឧបសគ្គដែលរាំងដល់ការសិក្សារបស់កូនៗដែរ ដូចជាអាណាព្យាបាលពុំមានចំណេះដឹងគ្រប់គ្រាន់អំពីខ្លឹមសារមេរៀនរបស់កុមារជាដើម។[82] ការគាំទ្រកម្រិតខ្ពស់របស់អាណាព្យាបាល ដើម្បីជួយឱ្យកូននៅបន្តការសិក្សាសម្រាប់កុមារ នឹងអានមានទំនាក់ទំនងជាមួយនឹងការយល់ដឹងអំពីសារៈសំខាន់នៃការសិក្សា រួមទាំងការយល់ឃើញជុំវិញផលប៉ះពាល់រយៈពេលវែងមកលើអនាគតរបស់កុមារ។

### ២.២.២. ផលវិបាកនៃការចូលរួមក្នុងវិធីសិក្សាពីចម្ងាយ (អនឡាញ)

#### ២.២.២.១.ផលវិបាកដល់ការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា

ទន្ទឹមនឹងការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះក៏មានឧបសគ្គដែលធ្វើការរាំងដល់ការចូលរួមក្នុងកម្មវិធីពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា មានដូចជា៖

- ឧបសគ្គហិរញ្ញវត្ថុដែលធ្វើឱ្យគ្រួសារមិនអាចបង់ថ្លៃអ៊ីនធឺណេត ទូរទសន្ស៍ខ្សែកាប និងបរិក្ខារដែលចាំបាច់ដទៃទៀតដើម្បីមូលរួមក្នុងកម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញ
- បញ្ហាក្នុងការតភ្ជាប់អ៊ីនធឺណេត
- អាណាព្យាបាលពុំអាចផ្តល់ការគាំទ្រដល់កូនបាន ដោយសារតែមិនមានចំណេះដឹងខ្លឹមសារគ្រប់គ្រាន់
- អាណាព្យាបាលពុំមានពេលវេលាជួយកូនដោយសារតែការងារ និងកិច្ចការផ្ទះ
- កង្វះការគាំទ្រ និងការពិនិត្យតាមដានពីគ្រូបង្រៀននិងតាមសាលារៀន

[82] ទិន្នន័យបង្ហាញពីកម្រិតដែលឪពុកម្តាយ/អាណាព្យាបាលអាចផ្តល់ការគាំទ្រដល់កូនក្នុងការសិក្សាពីចម្ងាយនៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៧៩

- កុមារបាត់បង់ចំណង់ចំណូលចិត្ត និងការលើកទឹកចិត្តក្នុងការសិក្សា
- កុមារត្រូវរ៉ាប់រងការទទួលខុសត្រូវផ្សេងទៀតនៅផ្ទះ។

ដោយក្នុងចំណោមឧបសគ្គទាំងអស់នេះ មានឧបសគ្គចំនួន ៤ ដែលត្រូវបានលើកឡើងញឹកញាប់ជាងគេ ដែលជាកត្តារារាំងដល់ការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ ដែលក្នុងនោះរួមមានឧបសគ្គផ្នែកហិរញ្ញវត្ថុដែលធ្វើឱ្យគ្រួសារពុំមានលទ្ធភាពបង់ថ្លៃអ៊ីនធឺណេត ខ្សែកាប និងបរិក្ខារដែលចាំបាច់ដទៃទៀតដើម្បីអាចទទួលបានការសិក្សាតាមប្រព័ន្ធអនឡាញមាន ៥១% បញ្ហាក្នុងការតភ្ជាប់អ៊ីនធឺណេតមាន ៤១% និងការខ្វះចំណេះដឹងអំពីខ្លឹមសារមេរៀនរបស់អាណាព្យាបាលមាន ២២% ឬអាណាព្យាបាលមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីជួយដល់ការសិក្សារបស់កូននៅផ្ទះ។[83] ស្ថានភាពក្រីក្ររបស់គ្រួសារមានផលប៉ះពាល់លើប្រភេទឧបសគ្គដែលសិស្សជួបប្រទះក្នុងការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ។ សិស្សដែលមកពីគ្រួសារក្រីក្រច្រើនតែជួបប្រទះនឹងឧបសគ្គច្រើនជាងសិស្សមកពីគ្រួសារមានជីវភាពល្អ ដោយសារតែបញ្ហាខ្វះខាតថវិកាសម្រាប់បង់ថ្លៃអ៊ីនធឺ-ណេត ខ្វះការគាំទ្រ និងការតាមដានពីគ្រូឬសាលារៀន និងការបាត់បង់ចំណាប់អារម្មណ៍របស់កុមារក្នុងការសិក្សា។ ដោយសារកត្តាទាំងអស់នេះហើយ បានធ្វើឱ្យមានការរារាំងទៅលើការរីកចម្រើនក្នុងកម្មវិធីសិក្សាពីចម្ងាយដែលជាផលវិបាកសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា។

**២.២.២.២.ផលវិបាកដល់ការចូលរួមរបស់អាណាព្យាបាលក្នុងកម្មវិធីសិក្សាពីចម្ងាយ**

ក្នុងចំណោមអ្នកឆ្លើយតបចំពោះការអង្កេតដែលរាយការណ៍ថាឪពុកម្តាយ ឬអាណាព្យាបាលមិនបានជួយដល់ការសិក្សាពីចម្ងាយរបស់កុមារបានជិតដល់ ហើយត្រូវបានស្នើរឱ្យជ្រើសរើសឧបសគ្គសំខាន់មួយចំនួនដែលធ្វើឱ្យឪពុកម្តាយមិនអាចចូលរួមនៅក្នុងការសិក្សាពីចម្ងាយបាន។ លទ្ធផលរកឃើញទាំងនេះគឺបានបង្ហាញថាឪពុកម្តាយចាំបាច់ត្រូវយល់ឱ្យកាន់តែច្បាស់ពីអ្វីដែលកុមាររបស់ខ្លួនកំពុងរៀននៅសាលា ក្នុងនោះមានឧបសគ្គធំសំខាន់ៗដូចជា៖

- អាណាព្យាបាលពុំមានពេលវេលាដោយសារត្រូវធ្វើការឬបំពេញការទទួលខុសត្រូវផ្សេងទៀត
- អាណាព្យាបាលខ្វះចំណេះដឹងពីខ្លឹមសារមេរៀន និងឯកសាររៀន
- អាណាព្យាបាលពុំមានចំណេះដឹងគ្រប់គ្រាន់ និងពុំមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា ឬឧបករណ៍មួយចំនួនក្នុងការសិក្សាពីចម្ងាយ
- អាណាព្យាបាលពុំបានទទួលការណែនាំ និងការគាំទ្រឱ្យបានគ្រប់គ្រាន់ពីរបៀបជួយកូនក្នុងការសិក្សាពីចម្ងាយ (អនឡាញ)។

[83] ទិន្នន័យបង្ហាញពីឧបសគ្គរាំងដល់ការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជននិងកីឡានៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៧៦

ក្នុងចំណោមឧបសគ្គទាំងអស់ដែលបានលើកឡើងខាងលើ គឺមានឧបសគ្គធំៗចំនួន ៣ ដែលបានរាំងដល់ការចូលរួមរបស់ឳពុកម្តាយក្នុងការសិក្សាពីចម្ងាយ រួមមាន៖ (i) កត្តាខ្វះចំណេះដឹងពីខ្លឹមសារ និងឯកសាររៀនមាន៥៥%, (ii) ឳពុកម្តាយឬអាណាព្យាបាលពុំមានពេលវេលាគ្រប់គ្រាន់ដោយសារត្រូវធ្វើការ និងបំពេញការទទួលខុសត្រូវផ្សេងទៀតមាន ៥៥% និង (iii) ការខ្វះចំណេះដឹង ឬការពុំមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗមាន ៥៨%។[84]

## ២.៣. គោលនយោបាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ

### ២.៣.១ ការអភិវឌ្ឍដើម្បីការអប់រំប្រកបដោយនិរន្តរភាព

ការអភិវឌ្ឍដើម្បីការអប់រំប្រកបដោយនិរន្តភាព (ESD : Education for Sustainable Development) គឺហើយមនុស្សម្នាក់ៗត្រូវតែដើម្បីរៀនពីរបៀបរស់នៅ រៀនអំពី ESD បង្កើតឡើងសម្រាប់មនុស្សគ្រប់ៗជាថាមពលដ៏ទូលំទូលាយនៃកិច្ចការដែលជាការគ្រោងទុកមុននៃពិភពលោកមានសំណាងទទួលបានប្រយោជន៍អំពីកាលានុវត្តភាពនៃការអប់រំអាកប្បកិរិយា និងតម្លៃចាំបាច់ទៅអនាគតប្រកបដោយនិរន្តភាព។ ESD បង្កើតឡើងសម្រាប់មនុស្សគ្រប់ៗគ្នានៅគ្រប់ស្រទាប់នៃជីវិតនិងនៅគ្រប់បរិបទនៃលទ្ធភាពសិក្សាដែលដូចគ្នាទៅនឹងការអប់រំសម្រាប់ទាំងអស់គ្នាផងដែរ។ ESD គឺផ្តោតសំខាន់ទៅលើសសរស្តម្ភបី ក្នុងការធ្វើឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តភាព រួមមាន៖ សង្គម (Society) បរិស្ថាន (Environment) និង សេដ្ឋកិច្ច (Economic)។ ក្នុងនេះ គេក៏រាប់បញ្ចូលនូវវប្បធម៌ (Culture) ផងដែរ ដែលជាទំហំមួយដ៏មានសារសំខាន់សម្រាប់ ESD។ ផ្អែកលើទ្រឹស្តីខាងលើការអប់រំ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តភាពផ្តោតទៅលើការសិក្សាពីបំណិនប្រសប់ ទស្សនៈវិស័យ និងតម្លៃនានាដែលដឹកនាំ និងជំរុញចិត្តប្រជាជនឱ្យស្វែងរកនូវនិរន្តភាពនៃការចិញ្ចឹមជីវិតការចូលរួមនៅក្នុងប្រជាធិប្បតេយ្យនៃសង្គម និងរស់នៅក្នុងលក្ខណៈនិរន្តភាព។ ទស្សនវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ច ការប្រកួតប្រជែង និងនិរន្តភាពចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាគឺកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាពស្ថិរភាពនយោបាយសន្តិសុខ សណ្តាប់ធ្នាប់សង្គមកំណើនសេដ្ឋកិច្ចរយៈវែង ការអភិវឌ្ឍប្រកបដោយចីរភាពនិងសមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនការការពារបរិស្ថានការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិប្បតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងមានកោសិការផ្សារភ្ជាប់គ្នាមានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និង មានការរស់រកបដោយសុខដុមរមនាទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ។ កម្ពុជាសង្ឃឹមថា

[84] ទិន្នន័យបង្ហាញពីឧបសគ្គរាំងដល់ការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយរបស់អាណាព្យាបាលនៃការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ទំព័រទី៨០

នឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ហើយឈានទៅជាប្រទេសអភិវឌ្ឍន៍ មានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅយុទ្ធសាស្ត្រ៤រួមមាន៖

១. ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព។

២. បង្កើតការងារឱ្យបានកាន់តែច្រើនជូនដល់ប្រជាជនពិសេស សម្រាប់ស្រទាប់យុវជន។

៣. សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១% ក្នុងមួយឆ្នាំ។

៤. បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើវិស័យអភិវឌ្ឍន៍ធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្ម ក្នុងតំបន់ដែលកាន់តែបើកចំហរតាមរយៈ៖

១. ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់

២. ការរៀបចំក្របខ័ណ្ឌគតិយុត្ត និងកសាងស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣. លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ

៤. ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។[85]

### ២.៣.២. ទស្សនវិស័យនៃការអភិវឌ្ឍធនធានមនុស្ស និងគោលនយោបាយអប់រំ

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងពេលចំពោះមុខ និងសម្រាប់អនាគត។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្ស គឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើសហគ្រិនភាព ជំនាញការច្នៃប្រឌិត និងនវានុវត្តន៍ លើគ្រប់ផ្នែក គ្រប់វិស័យ ពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ។ ទន្ទឹមនឹងនេះ ការលើកស្ទួយគុណភាពផ្នែកសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវ និងមនសិការស្នេហាជាតិ និងវិជ្ជាជីវៈដោយគ្មានការរើសអើងយេនឌ័ររួមជាមួយនឹងប្រព័ន្ធសុវត្ថិភាពសង្គម។ ប្រទេសកម្ពុជាបានឈានចូលក្នុងដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើការពង្រឹងការអប់រំមូលដ្ឋាន និងគុណភាពសិក្សានៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចជាតិដែលមានលក្ខណៈជាប្រព័ន្ធដ៏ទូលំទូលាយ។ ចក្ខុវិស័យអប់រំ សម្រាប់រយៈពេលវែងរបស់កម្ពុជាគឺយកចិត្តទុកដាក់ផ្តល់សេវាអប់រំចាប់ពីកុមារតូចតាមគ្រប់រូបភាពដែលជាមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ការអប់រំនៅកម្រិតបន្តបន្ទាប់ទៀត និងចិត្តទុកដាក់ដល់សិស្សានុសិស្សនៅកម្រិតដំបូងនៃបឋមសិក្សាលើបំណិន

[85] ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា ដោយឯកឧត្តម កង ឱម បណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំ នៃទំព័រទី១៨

អំណាន និងលេខនព្វន្ត។ វិស័យអប់រំនឹងពង្រីកវិសាលភាពនៃការអប់រំសម្រាប់ទាំងអស់គ្នាពីបឋមសិក្សា៦ឆ្នាំទៅដល់អប់រំមូលដ្ឋាន៩ឆ្នាំ។ សិស្សានុសិស្សដែលបញ្ចប់ការសិក្សាអប់រំមូលដ្ឋាន នឹងត្រូវពិនិត្យមើលឧបនិស្ស័យក្នុងការជ្រើសរើសបន្តការសិក្សានៅមធ្យមសិក្សាចំណេះទូទៅឬក៏ជ្រើសរើសផ្នែកអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ ការលើកកម្ពស់គុណភាពនៃការអប់រំក៏ត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការរៀន និងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គោលនយោបាយអប់រំរយៈពេលមធ្យមចំនួន ៣ កំពុងត្រូវបានអនុវត្តមានដូចជា៖

- **គោលនយោបាយទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌**

កុមារកម្ពុជាគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាពឱ្យបានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធជម្រើសផ្សេងៗទៀតនឹងត្រូវផ្តល់លទ្ធភាពឱ្យអ្នកទាំងនោះទទួលបានការអប់រំ។ ការបង្កើនចំនួនកុមារ និងយុវជនឱ្យទទួលបានការអប់រំនៅគ្រប់កម្រិតដោយផ្តោតលើ សីលធម៌ និង តំបន់ និង ក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី១២ឱ្យទទួលបានចំណេះដឹង និងជំនាញក្នុងការគិតនិងវិភាគហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

- **គោលនយោបាយទី២៖ លើកកម្ពស់គុណភាព និងភាពឆ្លើយតប**

កុមារ និងយុវជនគ្រប់រូបមានបទពិសោធន៍ក្នុងការសិក្សាប្រកបដោយគុណភាព និងភាពឆ្លើយតបដែលអាចឱ្យពួកគេចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខ័ណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រងជាមួយនឹងស្តង់ដារនៃការសម្រេចពិនិត្យតាមដាន និងរបាយការណ៍។

- **គោលនយោបាយទី៣៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

ការផ្តល់សេវាអប់រំនឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាពនិងភាពទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលាការពិនិត្យតាមដានរបាយការណ៍លទ្ធផល យោបល់ត្រឡប់នៃវិធានការប្រកបដោយគណនេយ្យភាព យន្តការសម្រាប់កែលម្អគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ក្រោមជាតិ។

ការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនឹងអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការជាក់ស្តែងនៅកម្រិតសាលារៀន។[86]

[86] ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា ដោយឯកឧត្តម កង ឱម បណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំ នៃទំព័រទី២១

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយយោងតាមការបកស្រាយខាងលើ នាងខ្ញុំបានសង្កេតឃើញថា ការរីកចម្រើននៃប្រទេសជាតិមួយគឺចាំបាច់មិនអាចខ្វះបាននូវកត្តាសំខាន់នៃការចូលរួមពីធនធានមនុស្សដែលមានចំណេះដឹង ជំនាញច្បាស់លាស់ និងសេចក្តីថ្លៃថ្នូរ ព្រមទាំងមានស្មារតីចូលរួមអភិវឌ្ឍន៍ប្រទេសជាតិផងដែរ។ នៅក្នុងកត្តារីកចម្រើនទាំងនេះ កុមារដើរតួនាទីយ៉ាងសំខាន់ ដែលជាទំពាំងស្នងឬស្សី ជាអ្នកបន្តវេនក្នុងការអភិវឌ្ឍប្រទេសជាតិ យ៉ាងដូច្នេះ ហើយការសិទ្ធិក្នុងការទទួលបានការអប់រំរបស់កុមារគឺពិតជាសំខាន់ណាស់ ដោយកត្តានេះមានឥទ្ធិពលក្នុងការកំណត់អំពីគុណភាពនៃធនធានមនុស្សនៅក្នុងប្រទេសនាពេលអនាគត។ តួយ៉ាងកុមារ គឺជាធនធានមនុស្សក៏សំខាន់ និងជាសសរទ្រូងនៃប្រទេសជាតិ ហើយដើម្បីឱ្យធនធានមនុស្សប្រកបដោយសក្តានុពល កុមារចាំបាច់ត្រូវទទួលបានការយកចិត្តទុកដាក់ពីសំណាក់គ្រួសារ សង្គមជាតិ និងការលើកកម្ពស់ការសិក្សាអប់រំដល់កុមារ ដើម្បីឱ្យពួកគាត់មានសមត្ថភាព កសាងគ្រួសារ និងសង្គមជាតិឱ្យបានរីកចម្រើននាពេលអនាគត។

យ៉ាងណាមិញសិទ្ធិទទួលបានការអប់រំរបស់កុមារ បានជួបនូវផលលំបាកមួយចំនួនដែលបានរាំងកុមារមិនអាចទទួលបានការអប់រំពេញលេញ ហើយការជះឥទ្ធិពដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏បានក្លាយជាឧបសគ្គដែលក្រសួងអប់រំ យុជន និងកីឡា ព្រមទាំងអាណាព្យាបាលបានជួបប្រទះក្នុងការសម្របសម្រួលដល់កុមារឱ្យទទួលបានការអប់រំពីចម្ងាយ(អនឡាញ)ផងដែរ។ ប៉ុន្តែយ៉ាងណាក៏ដោយ បញ្ហាទាំងអស់នេះត្រូវបានត្រូវបានដោះស្រាយដោយផែនការយុទ្ធសាស្ត្រនៃការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឱ្យកុមារនៅតែទទួលបានការអប់រំក្នុងបរិបទនៃជំងឺកូវីដ-១៩ ដូចជាការដាក់វិធានការក្នុងការសិក្សាពីចម្ងាយ ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនឱ្យស្របទៅតាមសម័យបដិវត្តន៍ឧស្សាហកម្ម៤.០ និងបន្តគោលដៅអភិវឌ្ឍន៍ការអប់រំប្រកបដោយចីរភាព។

សរុបមកទោះបីជាការរីករាតត្បាតនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលទៅលើវិស័យអប់រំ និងមានផលរំខានដល់ការសិក្សារបស់កុមារក៏ពិតមែន ប៉ុន្តែក្រសួងអប់រំ យុវជន និងកីឡា រួមនឹងអង្គការដែលជាដៃគូសហការក្រុមការងារវិស័យអប់រំ អង្គការក្រៅរដ្ឋាភិបាល និងអាណាព្យាបាល បានចូលរួមដោះស្រាយនូវបញ្ហានេះ ក៏ដូចជាធ្វើការសម្របសម្រួលដល់លទ្ធភាពដែលកុមារអាចទទួលបានការសិក្សាក្នុងបរិបទជំងឺកូវីដ-១៩ នេះ ព្រមទាំងភាពងាយស្រួល សុវត្ថិភាពក្នុងការសិក្សាពីចម្ងាយផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងតាមបកស្រាយខាងលើឃើញថា ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ នេះ ត្រូវបានធ្វើឡើងដើម្បីប្រមូលទិន្នន័យ និងធ្វើការរៀបចំផែនការក្នុងការឆ្លើយតបក្នុងការទទួលបានការអប់រំរបស់កុមារ និងស្តារឡើងវិញនាពេលអនាគតក្នុងការរៀបចំគោលវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រប្រើប្រាស់ធនធានដែលមានឱ្យចំគោលដៅ។ ទន្ទឹងនឹងការឆ្លើយតបនេះ ក្រសួងអប់រំ យុវជន និងកីឡា រួមទាំងដៃសហការបានធ្វើការយ៉ាងសកម្ម ហេតុនេះដើម្បីជំនួយដល់សិទ្ធិទទួលការអប់រំរបស់កុមារកម្ពុជានៃបរិបទកូវីដ-១៩ សូមធ្វើការបញ្ចេញមតិយោបល់ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

- ដើម្បីកាន់តែមានប្រសិទ្ធភាព និងភាពងាយស្រួលក្រសួងអប់រំ យុវជន និងកីឡា គួរតែបន្តការផ្តល់ការសិក្សាតាមរយៈមធ្យោបាយចម្រុះតាមប្រព័ន្ធអនឡាញ ឯកសារសិក្សាដែលអាចមើលនៅផ្ទះបានជាដើម។ ដោយសារតែការសិក្សាពីចម្ងាយរបស់កុមារមានការប្រែប្រួលខុសៗគ្នា ក្រសួងអប់រំ យុវជន និងកីឡាអាចពិចារណាបំពេញបន្ថែមការសិក្សាតាមប្រព័ន្ធអនឡាញជាមួយនឹងការបង្រៀនដោយមានការកំណត់ស្តង់ដារច្បាស់លាស់ ដូចជាការរៀនជាក្រុមតូចជាមួយនឹងគ្រូបង្រៀន ឬការរៀនពីគ្នាទៅវិញទៅមក។
- ការសិក្សាពីចម្ងាយនឹងនៅបន្តបំពេញតួនាទីសំខាន់ក្នុងវិស័យអប់រំ ដូច្នេះក្រសួងអប់រំ យុវជន និងកីឡា អាចពិចារណាក្នុងការអនុវត្តតាមដានវត្តមានសិស្សដែលចូលរួមសិក្សាពីចម្ងាយបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពនៃកម្មវិធីពីចម្ងាយកាន់តែខ្ពស់។
- បន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់មាតាបិតាក្នុងការជួយឱ្យកូនរបស់ពួកគេបានទទួលការអប់រំពីចម្ងាយឱ្យស្របទៅតាមកម្មវិធីសាលា និងចូលរួមលើកទឹកចិត្តឱ្យកុមារបន្តការសិក្សាប្រកបដោយគុណភាព។
- បន្តលើកកម្ពស់ភាពជាដៃគូប្រកបដោយគុណតម្លៃរួមគ្នា ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យការអប់រំតាមប្រព័ន្ធអនឡាញកាន់តែផ្តល់ភាពងាយស្រួលបន្ថែមទៀតខណៈពេលដែលក្រសួងអប់រំ យុវជន និងកីឡា បានបន្តកិច្ចសហការជាមួយនឹងក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ ដើម្បីបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់មាតិកាឌីជីថល។ បន្ថែមពីនេះអាចមានការឧបត្ថម្ភពីក្រុមហ៊ុនសេវាអ៊ីនធឺណេតជាដើម ដើម្បីឱ្យកុមារចូលប្រើប្រាស់មើលមាតិកាអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាសម្រួលដល់កុមារដែលរស់នៅតាមតំបន់ដាច់ស្រយាល។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រឹត្យលេខ នស/រកម/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា គឺឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុន
- ច្បាប់ស្តីពីការអប់រំ ខែធ្នូ ឆ្នាំ២០០៧, ព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករាឆ្នាំ១៩៩៦
- អនុក្រឹត្យ លេខ៨៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង អប់រំ យុវជន និងកីឡា ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៩។
- អនុសញ្ញាស្តីពីសិទ្ធិកុមារ បានអនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងចូលរួមជាសមាជិកតាមសេចក្តីសម្រេចលេខ ៤៤/២៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ១៩៨៩

### សេចក្តីសម្រេច/សេចក្តីណែនាំ/សារាចរណែនាំ

- សេចក្តីប្រកាសលេខ ២៥២៤ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ "ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន"
- សេចក្តីប្រកាសលេខ ៣៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីកាលបរិច្ឆេទបញ្ចប់ការផ្សាយផ្ទាល់វីដេអូបង្រៀនថ្នាក់ទី១ដល់ទី៣
- សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២០ខែវិច្ឆិការដែរ តែក្នុងឆ្នាំ១៩៥៩។
- សេចក្តីសម្រេច ស្តីពីការដាក់ចេញនូវវិធានការរដ្ឋបាល ដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន នៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញសម្រាប់រយៈពេល១៤ថ្ងៃ
- សារាចរណែនាំលេខ ២៣ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពី កម្មវិធីសិក្សាពីចម្ងាយ និងកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់សិស្សនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ចេញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០
- សេចក្តីណែនាំប្រតិបត្តិលេខ ២៩ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការអនុវត្តការសិក្សាពីចម្ងាយ
- សេចក្តីណែនាំលេខ ២៨៥១ របស់ក្រសួងអប់រំ យុវជន និងកីឡា

- សេចក្តីណែនាំលេខ ២៨៥២ របស់ក្រសួងអប់រំ យុវជន និងកីឡា

## សៀវភៅ

- សន្ធានុក្រមនៃក្រមនីតិរដ្ឋប្បវេណី
- វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជំនាន់ ១.២.២
- សៀវភៅ បរិវត្តកម្មឌីជីថលនៃការអប់រំ ដោយបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា ឆ្នាំ២០២១
- សៀវភៅគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី បោះផ្សាយដោយ ក្រសួងអប់រំ យុវជន និងកីឡា (ខែកញ្ញា ឆ្នាំ២០១៦)
- អត្ថបទបង្រៀនប្រវត្តិ ទសន្សៈ ទ្រឹស្តី នៃនីតិសិទ្ធិមនុស្ស ដោយលោកស្រីសាស្ត្រាចារ្យ ម៉ឹង វ៉ាន់ឌី (ឆ្នាំសិក្សា ២០២១-២០២២)
- អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម បោះផ្សាយដោយ អង្គការសហប្រជាជាតិសិទ្ធិមនុស្ស UNICEF (ខែមិថុនា ២០០៩)
- សៀវភៅផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០២៣០ បោះផ្សាយដោយ ក្រសួងអប់រំ យុវជន និងកីឡា (ខែកុម្ភៈ ឆ្នាំ២០១៩)
- អត្ថបទជំនួយស្មារតីនៃ ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា ដោយឯកឧត្តម កង ឱម (បណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំ) ជំនួយការនៃរាជបណ្ឌិត្យសភាកម្ពុជា
- សៀវភៅដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ បោះផ្សាយដោយ ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០២០)
- សេចក្តីថ្លែងការណ៍ ស្តីពីម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលត្រូវតែដាក់សិទ្ធិកុមារជាបេះដូងនៃការឆ្លើយតបគ្រោះអាសន្នជំងឺកូវីដ-១៩ របស់អង្គការសម្ព័ន្ធសិទ្ធិកម្ពុជា(ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២)
- ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ដោយក្រសួងអប់រំ យុវជន និងកីឡា (ខែមីនា ឆ្នាំ២០២១)

## គេហទំព័រ

- កិច្ចការពារកុមារ ដកស្រង់ចេញពី https://www.unicef.org/cambodia/km/
- អនុសញ្ញាស្តីពីសិទ្ធិកុមារ ដកស្រង់ពី https://www.unicef.org/cambodia/km/
- អំពីក្រសួងអប់រំ យុវជន និងកីឡា ដកស្រង់ចេញពី https://www.moeys.gov.kh/
- អត្ថបទនៃការអប់រំនៅកម្ពុជា ដកស្រង់https://contessa-project.eu/

- អត្ថបទនៃកម្មវិធីសុខភាពនិងអាហារូបត្ថម្ភ ដកស្រង់ចេញពី https://www.unicef.org/cambodia/healthandnutritin
- ការលើកកម្ពស់ការចូលរួមរបស់កុមារគឺផ្ដល់ឱកាសឱ្យកុមារបានចូលរួមធ្វើការសម្រេចចិត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់កុមារ ដកស្រង់ចេញពី https://www.information.gov.kh/articles/24082
- អត្ថបទអំពីបញ្ហាកូវីដ-១៩ របស់អង្គការក្រៅរាជរដ្ឋាភិបាល Hesperian Health Guides https://km.hesperian.org/hhg/New
- អត្ថបទស្ដីពីការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា (ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១) ដកស្រង់ចេញពី https://opendevelopmentcambodia.net/km/topics/primary-and-secondary-education/
- ប្រវិត្តនៃវិស័យការអប់រំនៅកម្ពុជា (ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥) ដកស្រង់ចេញពី https://web.facebook.com/edu.preychhor/photos/a.%201668552140047652/1671006183135581/
- អត្ថបទស្ដីអំពីប្រព័ន្ធអប់រំនៅកម្ពុជា ដោយអង្គការក្រៅរាជរដ្ឋាភិបាល Book Ridge ដកស្រង់ចេញពី https://www.bookbridge.org/post/the-education-system-in-cambodia
- វិស័យអប់រំនៅកម្ពុជា ដកស្រង់ចេញពី https://km.wikipedia.org
- វិស័យអប់រំឯកជនមានការរីកចម្រើនទាំងបរិមាណ និងគុណភាពគួរឱ្យកត់សម្គាល់ ដកស្រង់ចេញពី https://www.khmertimeskh.com
- អត្ថបទស្ដីអំពីសាលាអន្តរជាតិឯកជន ជួយពង្រឹងការអប់រំប្រកបដោយគុណភាព (ចុះផ្សាយថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០) ដកស្រង់ចេញពី https://www.postkhmer.com
- ក្រសួងអប់រំផ្អាកដំណើរការគ្រឹះស្ថានសិក្សារដ្ឋ-និងឯកជនគ្រប់កម្រិតនៅទូទាំងប្រទេសដកស្រង់ចេញពី https://www.postkhmer.com
- រដ្ឋមន្ត្រីក្រសួងអប់រំប្ដេជ្ញាកាត់បន្ថយជំងឺកូវីដ-១៩ក្នុងប្រព័ន្ធអប់រំ ដកស្រង់ចេញពី https://www.khmertimeskh.com/501012865
- ប្រសាសន៍លោកបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ ដកស្រង់ចេញពី http://moeys.gov.kh/news-updates/

- ការប្រើបច្ចេកវិទ្យាក្នុងបរិបទកូវីដ-១៩ ធ្វើឱ្យវិស័យអប់រំកម្ពុជា"ដើរលឿនមុនពេលកំណត់ដល់ទៅ១០ឆ្នាំ" ដកស្រង់ចេញពី https://thmeythmey.com/?page=detail&id=114716
- ផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមនៃជំងឺកូវីដ-១៩ មកលើប្រទេសកម្ពុជា ដកស្រង់ចេញពី https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/
- Impact of COVID-19 on informal workers by FOA ដកស្រង់ចេញពី https://www.fao.org/3/ca8560en/CA8560EN.pdf
- សិស្សជួបការលំបាកនឹងអ៊ីនធឺណេតក្នុងការសិក្សាពីចម្ងាយ ដកស្រង់ចេញពី https://web.facebook.com/ThmeyThmey/posts/3991062024324327/

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៧ អនក្រ.បក
ចុះថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៦ ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

# អង្គការលេខរបស់ក្រសួងអប់រំ យុវជន និងកីឡា



# អនុសញ្ញាអន្តរជាតិ

# ស្តីពី

# សិទ្ធិកុមារ

# អនុសញ្ញាស្តីពីសិទ្ធិកុមារ

បានអនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលរួមជាសមាជិក
តាមសេចក្តីសម្រេចចិត្តលេខ ៤៤/២៥ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ១៩៨៩ របស់មហាសន្និបាតអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី ២ ខែកញ្ញា ១៩៩០ ស្របតាមមាត្រា ៤៩

## បុព្វកថា

***រដ្ឋភាគីនានាទាំងអស់នៃអនុសញ្ញានេះ***

*យល់ឃើញថា* យោងតាមគោលការណ៍នានា ដែលប្រកាសក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពនិងមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន របស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ចងចាំថា* ប្រជាជាតិនៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួនទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់មនុស្ស ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ក្នុងសេរីភាពកាន់តែទូលំទូលាយ ។

*ទទួលស្គាល់ថា* ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាស និងយល់ស្របថា មនុស្សគ្រប់រូបត្រូវមានសិទ្ធិ និងសេរីភាពទាំងអស់ ដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរ ជាតិស្តីអំពីសិទ្ធិមនុស្ស ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀតឡើយ ។

*រំលឹកឡើងវិញថា* ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាសថា កុមារមានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស ។

*ជឿជាក់ថា* គ្រួសារជាអង្គភាពគ្រឹះនៃសង្គម និងជាមជ្ឈដ្ឋានធម្មជាតិ សម្រាប់ការរីកលូតលាស់ និងសុខុមាលភាពនៃសមាជិកទាំងអស់របស់សង្គម និងជាពិសេសកុមារ ត្រូវទទួលនូវការការពារ និងជំនួយឧបត្ថម្ភចាំបាច់ ដើម្បីឱ្យគ្រួសារអាចបំពេញតួនាទីរបស់ខ្លួនពេញលេញនៅក្នុងសហគមន៍។

*ទទួលស្គាល់ថា* ដើម្បីឱ្យមានការអភិវឌ្ឍន៍ពេញលេញ និងសមស្របតាមបុគ្គលិកលក្ខណៈរបស់កុមារ កុមារត្រូវធំលូតលាស់ក្នុងមជ្ឈដ្ឋានគ្រួសារ ក្នុងបរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់។

*យល់ឃើញថា* កុមារត្រូវហ្វឹកហាត់ឱ្យមានជីវភាពឯកត្តជនក្នុងសង្គម និងអប់រំក្នុងស្មារតីនៃឧត្តមគតិ ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ និងជាពិសេសក្នុងស្មារតីនៃសន្តិភាព សេចក្តីថ្លៃថ្នូរ ការអត់ឱនឱ្យគ្នា សេរីភាព សមភាព និងសាមគ្គីភាព។

*ចងចាំថា* ភាពចាំបាច់ដើម្បីផ្តល់ការការពារពិសេសដល់កុមារ ត្រូវបានថ្លែងក្នុងសេចក្តីប្រកាសនាក្រុងហ្សឺណែវ ឆ្នាំ១៩២៤ ស្តីពីសិទ្ធិកុមារ និងក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារដែលបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយភាពចាំបាច់នេះ ត្រូវបានទទួលស្គាល់នៅក្នុង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ជាពិសេសក្នុងមាត្រា ២៣ និងមាត្រា ២៤) ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ជាពិសេសក្នុងមាត្រា ១០) និងក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍ពាក់ព័ន្ធនានារបស់ស្ថាប័នឯកទេស និងអង្គការអន្តរជាតិ ដែលមានកិច្ចការទាក់ទិននឹងសុខុមាលភាពរបស់កុមារ។

*ចងចាំថា* ដូចបានបញ្ជាក់ក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារ "ដោយសារភាពខ្ចីខាងផ្នែករាងកាយ និងសតិបញ្ញា កុមារត្រូវការនូវកិច្ចការពារ និងការថែទាំជាពិសេស រួមទាំងការការពារសមស្របតាមផ្លូវច្បាប់ ទាំងមុននិងបន្ទាប់ពីកំណើត"។

*រំលឹកឡើងវិញថា* បទបញ្ញត្តិនៃសេចក្តីប្រកាសស្តីពីគោលការណ៍ខាងសង្គមកិច្ច និងខាងផ្លូវច្បាប់ទាក់ទងនឹងកិច្ចការពារ និងសុខុមាលភាពរបស់កុមារ សំដៅជាពិសេសទៅរកការប្រគល់កូនឱ្យគេចិញ្ចឹម និងការសុំកូន លើថ្នាក់ជាតិ និងអន្តរជាតិ វិធានជាបទដ្ឋានអប្បបរមារបស់សហប្រជាជាតិដើម្បីគ្រប់គ្រងវិស័យយុត្តិធម៌សម្រាប់កុមារ (វិធានក្រុងប៉េកាំង) និងសេចក្តីប្រកាសស្តីពីការការពារស្ត្រី និងកុមារ ក្នុងពេលមានអាសន្ន និងជម្លោះប្រដាប់អាវុធ។

*ទទួលស្គាល់ថា* នៅក្នុងប្រទេសទាំងអស់ក្នុងពិភពលោក មានកុមារកំពុងរស់នៅក្នុងស្ថានភាពដ៏សែនលំបាក ហើយកុមារទាំងនោះ ត្រូវការនូវការយកចិត្តទុកដាក់ពិសេស។

*យកមកគិតទូវ* សារសំខាន់នៃប្រពៃណី និងតម្លៃវប្បធម៌របស់ ប្រជាជាតិនីមួយៗ ក្នុងការការពារ និងការរីកចម្រើនដោយសុខដុមរបស់កុមារ ។

*ទទួលស្គាល់* សារសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកំពស់លក្ខខ័ណ្ឌជីវភាពរបស់កុមារនៅគ្រប់ប្រទេស ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

***បានព្រមព្រៀងគ្នាដូចតទៅ :***

## ផ្នែកទី ១

### មាត្រា ១

សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ ។

### មាត្រា ២

១. រដ្ឋភាគី ត្រូវគោរព និងធានាសិទ្ធិដូចចែងក្នុងអនុសញ្ញានេះ ដល់កុមារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ របស់ឪពុកម្តាយកុមារ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ ។

២. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីធានាឱ្យកុមារបាននូវការពារប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើង ឬទណ្ឌកម្ម ដែលផ្អែកលើមូលដ្ឋានស្ថានភាព សកម្មភាព ការបញ្ចេញមតិ ឬជំនឿរបស់ឪពុកម្តាយ របស់អាណាព្យាបាលស្របច្បាប់ ឬសមាជិកគ្រួសាររបស់កុមារ ។

## មាត្រា ៣

១. នៅក្នុងវិធានការទាំងអស់ ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈ ទទួលភារៈខាងសុខុមាលភាពសង្គម ឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ផលប្រយោជន៍ល្អបំផុតរបស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាចម្បង ។

២. រដ្ឋភាគី សន្យាធានាដល់កុមារនូវការការពារ និងការថែទាំចាំបាច់ ដើម្បីសុខុមាលភាពរបស់កុមារ ដោយយកមកគិតនូវសិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវស្របច្បាប់ចំពោះកុមារ និងដើម្បីសម្រេចទិសដៅនេះ រដ្ឋភាគី ត្រូវចាត់វិធានការខាងនីតិបញ្ញត្តិ និងរដ្ឋបាលដែលសមស្របទាំងអស់ ។

៣. រដ្ឋភាគី ត្រូវធានាថា ស្ថាប័ន ទីភ្នាក់ងារ និងគ្រឹះស្ថានដែលមានបន្ទុកថែទាំ ឬការពារកុមារ ត្រូវធ្វើតាមបទដ្ឋានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសនៅក្នុងវិស័យនៃសុវត្ថិភាព សុខភាព អំពីចំនួន និងភាពសមស្របនៃបុគ្គលិក ព្រមទាំងសមត្ថកិច្ចគ្រប់គ្រង ។

## មាត្រា ៤

រដ្ឋភាគីសន្យាចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីអនុវត្តសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ ។ ចំពោះសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគី ត្រូវចាត់វិធានការក្នុងកម្រិតអតិបរមានៃធនធានដែលខ្លួនមាន និងបើចាំបាច់ ក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការអន្តរជាតិ ។

## មាត្រា ៥

រដ្ឋភាគី ត្រូវគោរពតួនាទី សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្ដាយ ឬបើសមស្រប ត្រូវគោរពតួនាទីសិទ្ធិ និងករណីយកិច្ចរបស់សមាជិកគ្រួសារជាសាច់ញាតិ ឬសហគមន៍ អាស្រ័យតាមទំនៀមទម្លាប់នៅមូលដ្ឋាន អាណាព្យាបាលស្របច្បាប់ ឬជនផ្សេងទៀត ដែលមាននាទីស្របច្បាប់លើកុមារ ក្នុងការតម្រង់ទិស និងការណែនាំសមស្របតាមសមត្ថភាពរបស់កុមារ ដើម្បីឱ្យកុមារប្រើប្រាស់សិទ្ធិទាំងឡាយ ដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ ។

## មាត្រា ៦

១. រដ្ឋភាគី ទទួលស្គាល់ថា កុមារគ្រប់រូបមានសិទ្ធិរស់រានមានជីវិតជាប់ពីកំណើត ។

២. រដ្ឋភាគី ត្រូវធានាក្នុងកម្រិតអតិបរមា តាមដែលអាចធ្វើទៅបាន ចំពោះការរស់រាន និងការលូតលាស់របស់កុមារ ។

## មាត្រា ៧

១. កុមារ ត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋានភ្លាម បន្ទាប់ពីពេលកើត និងត្រូវមានសិទ្ធិមានឈ្មោះមួយពីពេលកើតមក មានសិទ្ធិទទួលបានសញ្ជាតិមួយ និងតាមដែលអាចធ្វើទៅបាន កុមារត្រូវមានសិទ្ធិស្គាល់ឪពុកម្តាយ និងទទួលការថែទាំពីឪពុកម្តាយ ។

២. រដ្ឋភាគី ត្រូវធានាការអនុវត្តសិទ្ធិទាំងនេះ ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ច ក្រោមលិខិតុបករណ៍អន្តរជាតិក្នុងវិស័យនេះ ពិសេសក្នុងករណីដែលកុមារ នឹងក្លាយជាជនឥតស្រុកទេស បើគ្មានការអនុវត្តនោះទេ ។

## មាត្រា ៨

១. រដ្ឋភាគី សន្យាគោរពសិទ្ធិរក្សាអត្តសញ្ញាណរបស់កុមារ រួមមានសញ្ជាតិ ឈ្មោះ និងទំនាក់ទំនងគ្រួសារផង ដូចបានទទួលស្គាល់ក្នុងច្បាប់ ដោយគ្មានការជ្រៀតជ្រែកដោយខុសច្បាប់ឡើយ ។

២. បើកុមារម្នាក់ត្រូវរងការដកហូតដោយខុសច្បាប់ នូវធាតុមួយចំនួន ឬទាំងអស់ នៃអត្តសញ្ញាណរបស់ខ្លួន នោះរដ្ឋភាគី ត្រូវផ្តល់ជំនួយ និងការការពារសមស្រប ដើម្បីស្តារអត្តសញ្ញាណរបស់កុមារឡើងវិញឱ្យបានឆាប់រហ័ស ។

## មាត្រា ៩

១. រដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយ ផ្ទុយពីឆន្ទៈរបស់កុមារឡើយលើកលែងតែអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតក្រោមការពិនិត្យរបស់តុលាការ សម្រេចស្របតាមច្បាប់និងនីតិវិធីថា ការបំបែកនេះ គឺចាំបាច់សម្រាប់ផលប្រយោជន៍ល្អបំផុតរបស់កុមារ ។ សេចក្តីសម្រេចនេះអាចចាំបាច់តែក្នុងករណីពិសេស មានជាអាទិ៍ ឪពុកម្តាយធ្វើបាប ឬទុកចោល ឬឪពុកម្តាយលែងរស់នៅជាមួយគ្នា ហើយសេចក្តីសម្រេចនេះ ត្រូវធ្វើដោយគិតពីកន្លែងស្នាក់នៅរបស់កុមារ ។

២. នៅគ្រប់នីតិវិធីស្របតាមកថាខណ្ឌ ១ នៃមាត្រានេះ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានផ្ដល់ឱកាសឱ្យចូលរួមក្នុងនីតិវិធីទាំងនោះ និងឱ្យបង្ហាញពីទស្សនៈរបស់ខ្លួន។

៣. រដ្ឋភាគី ត្រូវគោរពសិទ្ធិរបស់កុមារដែលត្រូវបំបែកពីឪពុកឬម្ដាយ ឬឪពុកម្ដាយទាំងពីរ ក្នុងការរក្សាជាទៀងទាត់ នូវទំនាក់ទំនងផ្ទាល់ខ្លួន និងការទាក់ទងដោយផ្ទាល់ជាមួយឪពុកម្ដាយ លើកលែងតែប្រការនេះផ្ទុយនឹងផលប្រយោជន៍ល្អបំផុតរបស់កុមារ។

៤. បើការរស់នៅបែកគ្នាបណ្ដាលមកពីវិធានការណាមួយផ្ដើមដោយរដ្ឋភាគី មានជាអាទិ៍ ការឃុំខ្លួន ការដាក់ពន្ធនាគារ ការនិរទេស ការបំបរបង់ ឬមរណភាព (រួមទាំងមរណភាពបណ្ដាលមកពីបុព្វហេតុណាមួយ នៅពេលរដ្ឋឃុំខ្លួន) ឪពុកឬម្ដាយ ឬឪពុកម្ដាយទាំងពីរ ឬកុមារ នោះរដ្ឋភាគី ដោយយោងតាមការស្នើសុំ ត្រូវជូនដំណឹងទៅឪពុកម្ដាយ ឬកុមារ ឬបើសមស្រប ត្រូវជូនដំណឹងទៅសមាជិកគ្រួសារណាម្នាក់ផ្សេងទៀត នូវព័ត៌មានសំខាន់អំពីទីកន្លែងនៃសមាជិកគ្រួសារណាម្នាក់ ឬច្រើននាក់ ដែលអវត្តមាន លើកលែងតែការជូនដំណឹងនេះ ប៉ះពាល់ដល់ផាសុខភាពរបស់កុមារ។ ម្យ៉ាងទៀត រដ្ឋភាគី ត្រូវធានាថា ការដាក់សេចក្ដីស្នើសុំមួយបែបនេះ នឹងមិននាំឱ្យមានផលជាអវិភូត សម្រាប់បុគ្គលពាក់ព័ន្ធឡើយ។

## មាត្រា ១០

១. ស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា ៩ កថាខណ្ឌ ១ គ្រប់ សេចក្ដីស្នើសុំរបស់កុមារ ឬឪពុក ឬម្ដាយរបស់កុមារ ដើម្បីចូល ឬចាកចេញពីរដ្ឋភាគី ក្នុងគោលបំណងជួបជុំគ្រួសារ ត្រូវតែដោះស្រាយក្នុងស្មារតីវិជ្ជមាន មនុស្សធម៌ និងដោយយកចិត្តទុកដាក់។ ក្រៅពីនេះ រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្ដីស្នើសុំនេះ នឹងមិនបង្កឱ្យមានផលអវិភូតដល់អ្នកសុំ និងដល់សមាជិកគ្រួសាររបស់អ្នកសុំឡើយ។

២. កុមារដែលមានឪពុកម្ដាយរស់នៅក្នុងរដ្ឋផ្សេង មានសិទ្ធិរក្សាជាទៀងទាត់នូវទំនាក់ទំនងផ្ទាល់ និងការទាក់ទងដោយផ្ទាល់ជាមួយឪពុកម្ដាយទាំងពីរ លើកលែងតែក្នុងកាលៈទេសៈពិសេស។ ក្នុងទិសដៅនេះ និងស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា ៩ កថាខណ្ឌ ១ រដ្ឋភាគីត្រូវគោរពសិទ្ធិរបស់កុមារ និងសិទ្ធិឪពុកម្ដាយរបស់កុមារក្នុងការចាកចេញពីប្រទេស រួមមានប្រទេសរបស់ខ្លួនផង និងវិលចូលមកក្នុងប្រទេសរបស់ខ្លួនវិញ។ សិទ្ធិចាកចេញពីប្រទេសណាមួយ អាចស្ថិតក្រោមការរឹតត្បិតបាន លុះត្រាតែការរឹតត្បិតនោះបញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ

សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ ហើយស្របនឹងសិទ្ធិផ្សេងទៀត ដែលទទួលស្គាល់ដោយអនុសញ្ញានេះ ។

## មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការផ្ទេរកុមារចេញក្រៅប្រទេស ដោយខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅប្រទេសមកវិញ ។

២. ក្នុងទិសដៅនេះ រដ្ឋភាគីត្រូវសម្រួលដល់ការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់ ។

## មាត្រា ១២

១. រដ្ឋភាគី ត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែង ដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ ។

២. ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេស នូវឱកាសស្តាប់នីតិវិធីតុលាការ និងរដ្ឋបាល ដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬតាមរយៈតំណាងម្នាក់ ឬស្ថាប័នសមស្របមួយ ស្របតាមបទបញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ ។

## មាត្រា ១៣

១. កុមារមានសិទ្ធិសម្តែងមតិដោយសេរី ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវ ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយគ្មានគិតពីព្រំដែន ទោះជាតាមទម្រង់ផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈ ឬតាមគ្រប់គ្រឿងផ្សាយព័ត៌មានផ្សេងទៀត តាមការជ្រើសរើសរបស់កុមារ ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចស្ថិតក្រោមការរិតត្បិតខ្លះបាន លុះត្រាតែការរិតត្បិតទាំងនេះត្រូវបានអនុញ្ញាតដោយច្បាប់ និងមានលក្ខណៈចាំបាច់ដូចខាងក្រោម ៖

(ក) ដើម្បីគោរពសិទ្ធិនិងកិត្តិនាមរបស់អ្នកដទៃ ឬ

(ខ) ដើម្បីការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ សុខភាព ឬសីលធម៌សាធារណៈ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៧៨ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## "ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" សម្រាប់កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ

ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ ក្រសួងបានបន្តពន្យារពេលបើកដំណើរការសាលារៀនឡើងវិញក្រោយវិស្សមកាលតូចនៅទូទាំងប្រទេស។ ដើម្បីធានាថាអ្នករៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធអាចបន្តរៀនបាននៅតាមផ្ទះ ក្រោមការជួយសម្របសម្រួលពីមន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំការផលិតវីដេអូសម្រាប់ការបង្រៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិច (E-Learning) សម្រាប់កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ដើម្បីពង្រីកការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ។

ដើម្បីឱ្យការសិក្សាពីចម្ងាយកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមានប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ គណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងដៃគូអភិវឌ្ឍ ដូចខាងក្រោម ៖

**១- អាសយដ្ឋានគេហទំព័រ និងទំព័រហ្វេសប៊ុក សម្រាប់បម្រើឱ្យការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិច៖**

- Facebook: https://www.facebook.com/krou.moeys.gov.kh/
- YouTube: https://www.youtube.com/moeys
- វេទិកាសិក្សាតាមអេឡិចត្រូនិច (E-Learning) ផ្លូវការរបស់ក្រសួង៖
    - កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ https://elearning.moeys.gov.kh

**២- ការរៀបចំចងក្រង និងបង្កើតក្រុម Telegram ឬ Messenger ឬ WhatsApp ៖**

- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ រៀបចំបង្កើតក្រុមជាមួយថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យអប់រំក្រៅប្រព័ន្ធនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ
- ការិយាល័យអប់រំក្រៅប្រព័ន្ធរបស់មន្ទីរ រៀបចំបង្កើតក្រុមជាមួយថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- មន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រៀបចំបង្កើតក្រុមជាមួយមន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងអ្នកទទួលបន្ទុកកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់ដៃគូអភិវឌ្ឍ
- គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងដៃគូអភិវឌ្ឍដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ បង្កើតក្រុមជាមួយមន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាល និងអ្នករៀនតាមកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- អាចបង្កើតក្រុមផ្សេងៗទៀតតាមការចាំបាច់របស់កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- ឈ្មោះរបស់ក្រុមនីមួយៗចាប់ផ្ដើមដោយ E-learning បន្ទាប់មកឈ្មោះរាជធានី ខេត្ត ឬឈ្មោះក្រុង ស្រុក ខណ្ឌ និងបន្ថែមឈ្មោះកម្មវិធីអក្ខរកម្ម ឬកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ។

**៣- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៖**

- ត្រួតពិនិត្យការផ្ដល់សៀវភៅសិក្សាគោលនៃកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ឱ្យបានដល់គ្រប់ថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- រៀបចំបង្កើតក្រុមការងារទទួលខុសត្រូវ ដើម្បីអនុវត្ត "ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"
- ផ្សព្វផ្សាយនិងជំរុញការអនុវត្ត "ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" ឱ្យបានទូលំទូលាយ
- សហការជាមួយមន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធសម្របសម្រួលគណៈគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងដៃគូអភិវឌ្ឍ
- ផ្ដល់ឯកសារ ឬ Copy Link មេរៀននៃកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ដែលបានផលិតនិងផ្សព្វផ្សាយ ទាំងឯកសាររឹង (Hardcopy) និងឯកសារទន់ (Softcopy) ទៅអ្នកពាក់ព័ន្ធតាមឋានានុក្រម
- ដោះស្រាយនូវសំណូមពរ និងសំណើសុំរបស់ថ្នាក់រៀនកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ តាមសមត្ថភាព និងលទ្ធភាព
- រក្សាវិធានការអនាម័យសិក្សាជាប្រចាំ និងអនុវត្តតាមការណែនាំស្ដីពីការបង្ការ និងទប់ស្កាត់ជំងឺកូវីដ ១៩របស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក។

**៤- មន្ត្រីអប់រំក្រៅប្រព័ន្ធអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដៃគូអភិវឌ្ឍដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ និងគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ៖**

- ផ្សព្វផ្សាយ និងជំរុញការអនុវត្ត "ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"ឱ្យបានទូលំទូលាយដល់មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ដៃគូអភិវឌ្ឍដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ មាតាបិតា អ្នកអាណាព្យាបាល និងអ្នករៀន

- ដឹកនាំ និងសហការជាមួយមន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ អាជ្ញាធរដែនដី គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងមាតាបិតា អ្នកអាណាព្យាបាល លើការអនុវត្ត "ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"
- ផ្តល់ឯកសារ ឬ Copy Link មេរៀននៃកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធដែលបានទទួលបានពីមន្ទីរ ឬការិយាល័យ ទាំងឯកសាររឹង (Hardcopy) និងឯកសារទន់ (Softcopy) ទៅអ្នកពាក់ព័ន្ធតាមឋានានុក្រម
- គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធបង្រៀនតាមកម្មវិធី ជួយបង្កើតគណនីហ្វេសប៊ុក ឬតេលេក្រាម ឬWhatsApp ដល់អាណាព្យាបាល អ្នករៀនដែលមានឧបករណ៍(កុំព្យូទ័រ អាយផេត ទូរស័ព្ទស្មាតហ្វូន...)
- គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ជួយណែនាំអ្នករៀនអំពីរបៀបសិក្សាពីចម្ងាយ ស្របតាមអាសយដ្ឋាន គេហទំព័រ និងទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា
- គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធបែងចែកពេលវេលា ដើម្បីចុះសម្របសម្រួល និងពិនិត្យតាមដានការរៀនរបស់អ្នករៀនតាមកម្មវិធីអក្ខរកម្ម ឬកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ និងលើកទឹកចិត្តឱ្យអ្នករៀនធ្វើស្វ័យសិក្សាជាប្រចាំ
- គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធបង្រៀនត្រូវធ្វើស្វ័យសិក្សា តាមរយៈ"ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" ដើម្បីបង្កើនសមត្ថភាពបន្ថែម។

**៥- មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងដៃគូអភិវឌ្ឍ ៖**

- ផ្សព្វផ្សាយនិងជំរុញការអនុវត្ត "ការសិក្សាពីចម្ងាយ" និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"ឱ្យបានទូលំទូលាយដល់មាតាបិតា អ្នកអាណាព្យាបាល និងអ្នករៀនកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- បញ្ចូលយុទ្ធនាការ "ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" ជាមួយវិធានការលើកកម្ពស់សុខភាព អនាម័យ និងអនុវត្តតាមការណែនាំស្តីពីការបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ក្នុងវេទិកាផ្សេងៗទៀត
- មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ សហការជាមួយអាជ្ញាធរដែនដី គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងដៃគូអភិវឌ្ឍ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ដើម្បីជំរុញនិងលើកកម្ពស់"ការសិក្សាពីចម្ងាយ" និង"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" របស់អ្នករៀនតាមកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- បង្កលក្ខណៈងាយស្រួលទាំងទីកន្លែង និងពេលវេលាដល់មាតាបិតា អ្នកអាណាព្យាបាល និងអ្នករៀនដែលអាចចូលរួម"ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច" ដោយរក្សាគម្លាតពីគ្នាយ៉ាងតិច ១,៥០ម៉ែត្រ។

**៦- មាតាបិតា អ្នកអាណាព្យាបាល និងអ្នករៀនកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ**

- ពិភាក្សា និងសហការជាមួយមាតាបិតា អ្នកអាណាព្យាបាល និងអ្នករៀនក្នុងកម្មវិធីជាមួយគ្នា ដើម្បីបង្កលក្ខណៈងាយស្រួលអ្នករៀនរបស់ខ្លួនបានរៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិច ដោយប្រសិទ្ធភាព
- ពិនិត្យលទ្ធភាពរៀបចំឧបករណ៍(កុំព្យូទ័រ អាយផេត ទូរស័ព្ទស្មាតហ្វូន...) សម្រាប់"ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច"
- ណែនាំ និងរំឭកអំពីពេលវេលា ឬកាលវិភាគដែលត្រូវចូលរួម"ការសិក្សាពីចម្ងាយ"
- ជួយលើកទឹកចិត្ត និងពន្យល់បន្ថែមដល់អ្នករៀនដែលជាសមាជិកគ្រួសាររបស់ខ្លួនពេលកំពុងទទួល "ការសិក្សាពីចម្ងាយ"
- ផ្តល់ព័ត៌មាន ឬស្នើសុំជំនួយទៅគ្រូបង្រៀនជួយពន្យល់បន្ថែមដល់សមាជិកគ្រួសាររបស់ខ្លួនតាមកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- ជួយអប់រំ និងណែនាំដល់អ្នករៀនដែលជាសមាជិកគ្រួសាររបស់ខ្លួន អំពីកន្លែងដែលមានហានិភ័យខ្ពស់នៃការឆ្លងជំងឺកូវីដ១៩ ថែរក្សាសុខភាព អនាម័យ លាងសម្អាតដៃនឹងសាប៊ូឱ្យបានញឹកញាប់ និងអនុវត្តតាមការណែនាំ។

**៧- ការពិនិត្យតាមដាននិងវាយតម្លៃ ៖**

- មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងដៃគូអភិវឌ្ឍ ដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវពិនិត្យតាមដានការសិក្សារបស់អ្នករៀន និងជួយជំរុញមាតាបិតា អ្នកអាណាព្យាបាលជួយបង្រៀនបន្ថែមដល់អ្នករៀនដែលជាសមាជិកគ្រួសាររបស់ខ្លួននៅផ្ទះ
- មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងដៃគូអភិវឌ្ឍដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវពិនិត្យតាមដានការបង្រៀន ការសម្របសម្រួលរបស់គ្រូបង្រៀនតាមកម្មវិធី និងធ្វើរបាយការណ៍ជូនតាមឋានានុក្រម
- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យតាមដានការសម្របសម្រួលរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដៃគូអភិវឌ្ឍដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ និងធ្វើរបាយការណ៍ជូនតាមឋានានុក្រម
- ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យអប់រំក្រៅប្រព័ន្ធរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិនិត្យតាមដានការសម្របសម្រួលរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធ និងធ្វើរបាយការណ៍ជូនតាមឋានានុក្រម
- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធត្រូវពិនិត្យតាមដានការបំពេញការងារ និងការអនុវត្តរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងថ្នាក់រៀនកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ លើការសម្របសម្រួល ជួយដល់គ្រូបង្រៀន និងអ្នករៀនលើការបង្រៀន និងរៀន។

**៨- ការរៀបចំនិងបញ្ជូនរបាយការណ៍ ៖**

- គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ត្រូវផ្តល់របាយការណ៍ស្តីពីការសម្របសម្រួលការរៀនរបស់អ្នករៀនរបស់ខ្លួន (តាមគំរូរបាយការណ៍) រួចបញ្ជូនទៅមន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ បន្ទាប់ពីការបង្រៀនបានមួយសប្តាហ៍
- មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ សង្កាត់ ត្រូវផ្តល់របាយការណ៍ស្តីពីការសម្របសម្រួលការរៀនរបស់អ្នករៀនរបស់ខ្លួន (តាមគំរូរបាយការណ៍) រួចបញ្ជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅថ្ងៃអង្គារ
- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវផ្តល់របាយការណ៍ស្តីពីការសម្របសម្រួលការរៀនពីចម្ងាយរបស់ខ្លួន (តាមគំរូរបាយការណ៍) រួចបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត នៅថ្ងៃព្រហស្បតិ៍នៃសប្តាហ៍បន្ទាប់
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្តល់របាយការណ៍ស្តីពីការសម្របសម្រួលការរៀនពីចម្ងាយរបស់ខ្លួន (តាមគំរូរបាយការណ៍) រួចបញ្ជូនទៅនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃពុធសប្តាហ៍បន្ទាប់។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដៃគូអភិវឌ្ឍដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងមាតាបិតា អ្នកអាណាព្យាបាល សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសូមមេត្តាតាមដានជាប្រចាំនូវការផ្សព្វផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។

ថ្ងៃ ច័ន្ទ ៣រោច ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល**

- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

  **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា

  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៦ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការបង្រៀន និងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១

ដើម្បីធានាបាននូវការបន្តការសិក្សារបស់សិស្សានុសិស្សនៅបឋមសិក្សា ក្នុងពេលដែលសាលារៀនផ្អាកដំណើរការ គ្រឹះស្ថានបឋមសិក្សាសាធារណៈនៅទូទាំងប្រទេស អាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀននិងរៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក ឬរៀនតាមបណ្តុំតូចៗ អាស្រ័យលើស្ថានភាព និងធនធាន ក្រោមការច្នៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូនៅតាមមូលដ្ឋាន។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តអាចចេញសេចក្តីណែនាំបន្ថែមស្តីពី ការអនុវត្តសេចក្តីណែនាំរួមនេះ ទៅតាមស្ថានភាពជាក់ស្តែង ។

ក្នុងន័យនេះ ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់សាលារៀន ស្តីពីការបន្តដំណើរការបង្រៀននិងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក ដូចខាងក្រោម៖

### ១- ការកែសម្រួលប្រតិទិនសិក្សា ឆ្នាំសិក្សា២០២០-២០២១

យោងសេចក្តីណែនាំលេខ ៥៩ អយក.សណន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ឆ្នាំសិក្សា២០២០-២០២១ ត្រូវបើកបវេសនកាលនាថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និងបញ្ចប់ទៅវិញនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។

ដើម្បីជាជំនួយដល់ការអនុវត្ត ក្រសួងសូមធ្វើការកែសម្រួលប្រតិទិនសិក្សា តាមកម្មវិធីដូចខាងក្រោម៖

- ឆ្នាំសិក្សា២០២០-២០២១ ត្រូវចាប់ផ្តើមនៅថ្ងៃទី១១ ខែមករា និងបញ្ចប់ទៅវិញនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១
- ឆមាសទី១ គិតចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២១ និងឆមាសទី២ គិតចាប់ពីខែសីហា ដល់ខែវិច្ឆិកា ឆ្នាំ២០២១
- វិស្សមកាលធំ ចាប់ពីថ្ងៃទី០១ ដល់ ៣១ ខែធ្នូ ឆ្នាំ២០២១។

### ២- ការអនុវត្តកម្មវិធីសិក្សាបង្រួញ

គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវបន្តដំណើរការបង្រៀននិងរៀន តាមរយៈការអនុវត្តកម្មវិធីសិក្សាបង្រួញ ដោយផ្តោតលើមុខវិជ្ជាកាតព្វកិច្ចពីរគឺ ភាសាខ្មែរ និងគណិតវិទ្យា។ គណៈគ្រប់គ្រងសាលា និង



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តដូចខាងក្រោម៖

- រៀបចំផែនការបង្រៀនប្រចាំសប្ដាហ៍ និងប្រចាំខែឡើងវិញ ដោយផ្ដោតលើខ្លឹមសារមេរៀនសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការបន្តការសិក្សានៅថ្នាក់បន្តបន្ទាប់ទៀត
- សង្ខេបខ្លឹមសារមេរៀនដោយផ្ដោតលើបញ្ញត្តិ ដែលធ្វើឱ្យសិស្សងាយយល់ និងអាចយកទៅអនុវត្តបាន
- លើកទឹកចិត្តនិងជួយសិស្សឱ្យអនុវត្តលំហាត់ ឬ ធ្វើការហ្វឹកហាត់នានាបន្ថែមទៀតនៅផ្ទះ
- មុខវិជ្ជាផ្សេងទៀតត្រូវល្បូរសិន ដោយនឹងត្រូវរៀនបំពេញបន្ថែម នៅដើមឆ្នាំសិក្សាបន្ទាប់។

## ៣- ការបង្រៀននិងរៀនជាក្រុមតូចៗនៅតាមផ្ទះ ឬ ទីកន្លែងសមស្របណាមួយ

អាជ្ញាធរដែនដី ជាពិសេសអភិបាលនៃគណៈអភិបាលខេត្ត ឬក្រុង ស្រុក ត្រូវធ្វើការកំណត់តំបន់ដែលមានហានិភ័យទាប (ពណ៌លឿង) ហានិភ័យមធ្យម (ពណ៌លឿងទុំ) និងហានិភ័យខ្ពស់ (ពណ៌ក្រហម) ទៅតាមទំហំនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

រាជធានីភ្នំពេញ និងតំបន់ ដែលត្រូវបានកំណត់ជាតំបន់មានហានិភ័យខ្ពស់ និងមធ្យម (ពណ៌ក្រហម និងពណ៌លឿងទុំ) ត្រូវអនុវត្តការបង្រៀននិងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកទាំងស្រុង។

តំបន់ដែលមានហានិភ័យទាប (ពណ៌លឿង) គណៈគ្រប់គ្រងសាលាអាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀននិងរៀនជាក្រុមតូចៗ (សិស្សមិនលើសពី១០នាក់ ក្នុង១បណ្ដុំ) នៅតាមផ្ទះ ឬទីតាំងសមស្របណាមួយ សម្រាប់សិស្សដែលមានលំនៅដ្ឋាននៅជិតៗគ្នា និងធ្លាប់មានទំនាក់ទំនងគ្នាជាប្រចាំ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្រូវរៀបចំសំណើ ដាក់ឆ្លងយោបល់សម្រេចពីគណៈអភិបាលក្រុង ស្រុក និងគណៈអភិបាលខេត្ត ព្រមទាំងផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា។

គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តដូចខាងក្រោម៖

- រៀបចំចងក្រងបញ្ជីឈ្មោះសិស្សតាមបណ្ដុំ និងតាមកម្រិតថ្នាក់ (បើតាមកម្រិតថ្នាក់នីមួយៗមានសិស្សតិចពេក អាចបង្កើតជាកម្រិតថ្នាក់គួប ១+២, ៣+៤ ឬ ៥+៦ ជាដើម)
- ធ្វើការបែងចែកគ្រូបង្រៀនឱ្យទទួលខុសត្រូវតាមបណ្ដុំ ឬ តាមកម្រិតថ្នាក់នីមួយៗ (បើគ្រូបង្រៀនមិនអាចទៅសម្របសម្រួលបាន ត្រូវឱ្យសិស្សធំនៅបណ្ដុំជាមួយគ្នា ឬមាតាបិតាជួយសិស្សតូចៗ)
- រៀបចំបំណែងចែកកាលវិភាគប្រចាំសប្ដាហ៍ ចែកជូនដល់គ្រូបង្រៀនម្នាក់ៗ និងសិស្សនៅតាមបណ្ដុំ
- សហការជាមួយអាជ្ញាធរដែនដី (រដ្ឋបាលក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់) និងមាតាបិតា អ្នកអាណាព្យាបាលសិស្ស ក្នុងការរៀបចំទីតាំងសមស្រប សម្រាប់ការបង្រៀននិងរៀនជាបណ្ដុំ និងពិនិត្យស្ថានភាពជាក់ស្ដែង នៅមូលដ្ឋានថាប្រាកដជាអាចបង្រៀនតាមបណ្ដុំបាន ក៏ដូចជាជួយរៀបចំក្ដារខៀន តុ កៅអី គ្រែ កន្ទេល...
- ថតចម្លងវីដេអូនៃការបង្រៀនទុកក្នុងកុំព្យូទ័រឬទូរស័ព្ទដៃ (អាចថតចម្លងសម្រាប់មួយសប្ដាហ៍ មួយខែ មួយឆមាស ឬវីដេអូទាំងអស់សម្រាប់មួយឆ្នាំ) ដើម្បីសម្រួលដល់លោកគ្រូ អ្នកគ្រូ ក្នុងការបង្រៀនសិស្សនៅតាមបណ្ដុំ
- គណៈគ្រប់គ្រងសាលាត្រូវផ្ដល់សម្ភារៈគាំទ្រសមស្រប សម្រាប់បម្រើឱ្យការបង្រៀននិងរៀនតាមបណ្ដុំ
- ការចុះបង្រៀនតាមបណ្ដុំត្រូវអនុវត្តកម្មវិធីសិក្សាបង្រួម ដូចចំណុចទី១ខាងលើ។

## ៤- ការបង្រៀននិងរៀនពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក

### ៤.១- ការបង្រៀននិងរៀនពីចម្ងាយ តាមរយៈការផ្តល់សន្លឹកកិច្ចការ

ក្នុងករណីសាលាបឋមសិក្សាស្ថិតក្នុងតំបន់ដែលមានហានិភ័យមធ្យម និងហានិភ័យទាប នៃការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រឹះស្ថានបឋមសិក្សាសាធារណៈ អាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀន និងរៀនពីចម្ងាយ តាមរយៈការផ្តល់សន្លឹកកិច្ចការឱ្យសិស្សយកទៅអនុវត្តនៅផ្ទះ។ គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តដូចខាងក្រោម៖

- រៀបចំសន្លឹកកិច្ចការរៀងៗខ្លួន ឬប្រើប្រាស់សន្លឹកកិច្ចការដែលក្រសួង (នាយកដ្ឋានបឋមសិក្សា) បានផលិតនិងផ្តល់ជូននាពេលកន្លងមក
- រៀបចំការសង្ខេបមេរៀន និងសន្លឹកកិច្ចការជាជំនួយដល់ការសិក្សារបស់សិស្ស ដោយផ្តោតលើមុខវិជ្ជាកាតព្វកិច្ច
- កៀរគរថវិកាពីប្រភពនានារួមមាន ថវិកាដំណើរការសាលារៀន ថវិការបស់អង្គការដៃគូនានា ថវិកាដែលបានមកពីការចូលរួមរបស់សហគមន៍ សប្បុរសជន និងមាតាបិតា អ្នកអាណាព្យាបាលសិស្ស ជាដើម ដើម្បីគាំទ្រដល់ការថតចម្លងសន្លឹកកិច្ចការចែកជូនសិស្សានុសិស្ស
- ថតចម្លងសន្លឹកកិច្ចការទាំងនោះ រួចបែងចែកឱ្យសិស្សានុសិស្សទាំងអស់
- ធ្វើការបែងចែកវេនឱ្យសិស្សមកទទួលសន្លឹកកិច្ចការ ផ្តល់សន្លឹកកិច្ចការមកវិញនៅសប្តាហ៍បន្ទាប់ ជាមួយនឹងការប្តូរសន្លឹកកិច្ចការថ្មីនៅសាលារៀន ដោយលៃពេលវេលាខុសៗគ្នា ដើម្បីកាត់បន្ថយឱ្យបានជាអប្បបរមានូវចំនួននៃការជួបជុំ (គ្រូប្រចាំថ្នាក់ ត្រូវមានវត្តមាននៅសាលារៀនជាប្រចាំ)
- គ្រូប្រចាំថ្នាក់ ត្រូវពិនិត្យនិងផ្តល់យោបល់កែសម្រួលលើសន្លឹកកិច្ចការដែលសិស្សប្រគល់ជូន និងធ្វើការពន្យល់បន្ថែមដល់សិស្ស នៅពេលពួកគេយកសន្លឹកកិច្ចការចាស់មកប្រគល់ និងទទួលសន្លឹកកិច្ចការថ្មី នៅសប្តាហ៍បន្ទាប់។

### ៤.២- ការបង្រៀននិងរៀនពីចម្ងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក

ក្នុងករណីសាលាបឋមសិក្សាស្ថិតក្នុងតំបន់ដែលមានហានិភ័យខ្ពស់ នៃការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តការបង្រៀននិងរៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក។ គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តដូចខាងក្រោម៖

- ជំរុញការរៀនពីចម្ងាយតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការ ដូចជា Facebook, YouTube, ទូរទស្សន៍ និងតាមរយៈ App ផ្លូវការនានា
- រៀបចំការបង្រៀនតាមកម្មវិធី Zoom, Google Meet និងតាមកម្មវិធីផ្សេងៗទៀតទៅតាមលទ្ធភាព និងសមត្ថភាព
- ផ្តល់និងកែសន្លឹកកិច្ចការ ក៏ដូចជាវីដេអូការបង្រៀន មេរៀនសង្ខេប... តាមក្រុម Telegram ឬ Messenger
- ធ្វើការពន្យល់ និងបកស្រាយនូវចម្ងល់នានារបស់សិស្សតាមរយៈទូរស័ព្ទដោយផ្ទាល់ ឬក្រុម Telegram ឬ Messenger ជាដើម
- រៀបចំទិញ External Hard Drive ដើម្បីថតចម្លងវីដេអូការបង្រៀនពីការិយាល័យ អ.យ.ក. ក្រុង

ស្រុក ខណ្ឌ យកទៅបម្រើឱ្យការបង្រៀននៅតាមសាលារៀន ដោយប្រើប្រាស់ថវិកាដំណើរការសាលារៀន ឬ ថវិកាដែលបានពីប្រភពផ្សេងៗទៀត។

## ៤.៣- ការជួយបង្រៀនកូននៅផ្ទះ ដោយប្រើប្រាស់កញ្ចប់សម្ភារសិក្សាថ្នាក់ទី១ និងទី២

ក្រសួងអប់រំ យុវជន និងកីឡានឹងផ្ដល់កញ្ចប់សម្ភារសិក្សា ក្រោមការឧបត្ថម្ភរបស់មូលនិធិភាពជាដៃគូ សកលសម្រាប់ការអប់រំដំណាក់កាលទី៣ (CDPFIII) ទៅដល់សិស្សានុសិស្សថ្នាក់ទី១ និងទី២ នៅទូទាំងប្រទេស។ គណៈគ្រប់គ្រងសាលាសហការជាមួយលោកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដី ដើម្បីបែងចែកសម្ភារសិក្សាទាំងនោះ ឱ្យដល់ដៃសិស្ស និង/ឬ មាតាបិតា អ្នកអាណាព្យាបាល យ៉ាងយូរ៣ថ្ងៃ បន្ទាប់ពីទទួលបានពីក្រុមហ៊ុនផ្គត់ផ្គង់។ សម្ភារសិក្សាដែលសិស្សថ្នាក់ទី១ និងទី២ ម្នាក់ៗត្រូវទទួលបាន (លើកលែងខេត្តមួយចំនួនដែលសិស្សបានទទួលតាមរយៈគម្រោងរួចហើយ) រួមមាន៖

**ថ្នាក់ទី១៖**

- សៀវភៅជំនួយសិស្សមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១ ភាគ១ និងភាគ២
- សៀវភៅហ្វឹកហាត់អាន សរសេរ របស់សិស្សថ្នាក់ទី១ ឆមាសទី១ និងឆមាសទី២
- សៀវភៅលំហាត់គណិតវិទ្យាសម្រាប់សិស្សថ្នាក់ទី១ (៤ក្បាល)
- សៀវភៅហ្វឹកហាត់សរសេរថ្នាក់ទី១ (កូនស្វាឆ្លាត) ឆមាសទី១ (៤ក្បាល)
- សៀវភៅរឿងខ្លីៗ ចំនួន២ក្បាល (៣០ចំណេះដឹង)
- សេចក្ដីណែនាំបន្ថែមសម្រាប់មាតាបិតា អ្នកអាណាព្យាបាលជួយបង្រៀន និងសម្របសម្រួលដល់ការរៀនរបស់កូន នៅតាមផ្ទះ។

**ថ្នាក់ទី២៖**

- សៀវភៅជំនួយសិស្សមុខវិជ្ជាភាសាខ្មែរថ្នាក់ទី២ ឆមាសទី១
- សៀវភៅហ្វឹកហាត់អាន សរសេរ របស់សិស្សថ្នាក់ទី២ ឆមាសទី១ និងឆមាសទី២
- សៀវភៅលំហាត់គណិតវិទ្យាសម្រាប់សិស្សថ្នាក់ទី២ (៤ក្បាល)
- សៀវភៅរឿងខ្លីៗ ចំនួន១ក្បាល (១៥ចំណេះដឹង)។
- សេចក្ដីណែនាំបន្ថែមសម្រាប់មាតាបិតា អ្នកអាណាព្យាបាលជួយបង្រៀន និងសម្របសម្រួលដល់ការរៀនរបស់កូន នៅតាមផ្ទះ។

ដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃការសិក្សារបស់កូននៅផ្ទះ តាមរយៈកញ្ចប់សម្ភារសិក្សានេះ ក្រសួងសូមធ្វើការណែនាំដល់មាតាបិតា អ្នកអាណាព្យាបាល និងសិស្សានុសិស្សដូចខាងក្រោម៖

- អង្គុយរៀនជាមួយកូនៗ រួចនាំកូនអាន សរសេរ និងធ្វើលំហាត់ ដោយធ្វើជាគំរូជាមុន បន្ទាប់មកឱ្យពួកគេអនុវត្តដោយខ្លួនឯង។ បើការអនុវត្តមានការខុសឆ្គង សូមជួយកែតម្រូវ (ចំពោះមាតាបិតា អ្នកអាណាព្យាបាលដែលមិនអាចបង្រៀនកូនបានសូមបន្តនៅអង្គុយក្បែរកូននិងឱ្យកូនអានឱ្យឮៗ)
- ផ្ដល់ការលើកទឹកចិត្តដល់កូនជាប្រចាំ តាមរយៈការព្យាយាមអត់ធ្មត់ ឧស្សាហ៍និយាយពាក្យល្អៗជាមួយកូន សរសើរនិងលើកទឹកចិត្ត បង្កើតបរិយាកាសសិក្សារីករាយ និងមេត្រីភាពសម្រាប់កូនៗ
- សូមទូរស័ព្ទទៅលោកគ្រូ អ្នកគ្រូប្រចាំថ្នាក់របស់កូន នៅពេលត្រូវការជំនួយ

តាមសន្លឹកកិច្ចការ ត្រូវរៀបចំតេស្តជាបៀបផ្តល់សន្លឹកតេស្តពីចម្ងាយ និងបើរៀនតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវធ្វើតេស្តតាមប្រព័ន្ធអេឡិចត្រូនិក។ ម្យ៉ាងទៀត បើសាលារៀនដែលបានរៀបចំការប្រឡងឆមាសទី១ រួចហើយ មិនចាំបាច់អនុវត្តតាមការណែនាំនេះទេ។

## ៦- ការគាំទ្រនិងអន្តរាគមន៍ផ្សេងៗ

- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូ ដូចជាផ្តល់ការរៀនសូត្រពីចម្ងាយ តាមរយៈវីដេអូការបង្រៀនដែលបានផ្សព្វផ្សាយនាពេលកន្លងមក
- អាជ្ញាធរដែនដី(រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់) គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ ត្រូវលើកទឹកចិត្តសិស្សឱ្យបានចូលរៀន និងចូលរួមរៀនសូត្រ តាមគ្រប់រូបភាព
- អាជ្ញាធរដែនដី(រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់) ជួយបង្កលក្ខណៈងាយស្រួលដល់ការចុះបំពេញការងាររបស់លោកគ្រូ អ្នកគ្រូ ជាពិសេសការបង្រៀនតាមបណ្តុំ និងការបង្រៀនតាមរយៈសិស្សមកទទួលសន្លឹកកិច្ចការដោយផ្ទាល់នៅសាលារៀន
- វាយតម្លៃលើផលប៉ះពាល់នៃការសិក្សា និងកំណត់ចំណុចខ្វះខាតដែលសិស្សជួបប្រទះក្នុងការរៀនសូត្រ ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមកុមារងាយរងគ្រោះ
- បន្តលើកទឹកចិត្តសិស្សដែលងាយរងគ្រោះតាមរយៈការផ្តល់ការគាំទ្រជាសម្ភារសិក្សា សម្លៀកបំពាក់ និងសម្ភារៈចាំបាច់ផ្សេងទៀត
- បន្តគាំទ្រដល់សិស្សរៀនយឺត ផ្អែកតាមលទ្ធផលតេស្តវាយតម្លៃ និងរៀបចំក្រុមសិស្សរៀនយឺតសម្រាប់ការបង្រៀនបន្ថែម
- បន្តទំនាក់ទំនងល្អជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស ដោយផ្តល់ព័ត៌មានអំពីការសិក្សារបស់កូនទៅពួកគាត់ជាប្រចាំ។

## ៧- ការពិនិត្យតាមដាន អធិការកិច្ច និងរបាយការណ៍

### ៧.១- ការធ្វើអធិការកិច្ច

- ការិយាល័យ អ.យ.ក. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចជារួម តាមលទ្ធភាព
- ថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានជំនាញ មន្ទីរ អ.យ.ក. រាជធានី ខេត្ត និងការិយាល័យ អ.យ.ក. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យតាមដាន និងធ្វើអធិការកិច្ច ដើម្បីផ្តល់ការគាំទ្រនិងកែលម្អជាប្រចាំនៅតាមគ្រឹះស្ថានបឋមសិក្សា តាមលទ្ធភាព។

### ៧.២- ការធ្វើរបាយការណ៍

- "**គណៈគ្រប់គ្រងសាលារៀន**" ត្រូវរៀបចំ និងធ្វើរបាយការណ៍ប្រចាំខែ ស្តីពីដំណើរការបង្រៀននិងរៀនពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់រូបភាព ឱ្យបានទៀងទាត់តាមឋានានុក្រម។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈ បុគ្គលិកអប់រំ អាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  **"ដើម្បីជ្រាបជាព័ត៌មាន"**
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានបឋមសិក្សា